# សង្វេតការណ៍ ៨

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែមីនា ឆ្នាំ២០១២



## មាតិកា


ការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ ១
សវនាការស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ២២
ការសួរដេញដោលបញ្ជីឯកសារ ៤០



ក្រុមសង្កេតការណ៍ ៖
ឆាយ ឈុនលី, ឌី សុជាតា,
លឹម ជ័យទត្ត និង ចាន ប្រាថ្នា


លោក ឆាំង យុ កំពុងរៀបរាប់អំពីសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដល់លោកស្រី ហ៊ីលឡារី គ្លីនតុន (រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក) និងលោកស្រី ខារ៉ូល រ៉ដលី (ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា) កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ។

(រូបថត ៖ រីល បេក្សទើ/ភ្នំពេញប៉ុស្តិ៍)


មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំ និងយុត្តិធម៌ ◆ www.dccam.org


នួន ជា ក្នុងបន្ទប់សវនាការ ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)

# ការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

## ថ្ងៃទី១-២ និងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១២

*ឆាយ ឈុនលី, ឌី សុដាតា, ចាន ប្រាថ្នា និង លឹម ជ័យទ័ត្ត*

### សេចក្តីផ្តើម

*ថ្ងៃទី១-២ និង ៦ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តកិច្ចដំណើរការសវនាការលើកសំណុំរឿងនៅក្នុងដំណាក់កាលទី១ ដោយបានកោះអញ្ជើញសាក្សី លោក ឆាំង យុ (នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា) មកផ្តល់សក្ខីកម្មទាក់ទងនឹងការរៀបចំ និងថែរក្សាឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សវនាការនេះបានចាប់ផ្តើមដោយប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន ធ្វើការសាកសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងប្រវត្តិសាវតាររបស់លោក ឆាំង យុ ។ លោក ឆាំង យុ បានបញ្ជាក់ជូនទៅអង្គជំនុំជម្រះថា លោកមានស្រុកកំណើត និងទីលំនៅបច្ចុប្បន្ននៅទីក្រុងភ្នំពេញ ។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត នៅសកលវិទ្យាល័យមួយនៅរដ្ឋតិចសាស (Texas) សហរដ្ឋអាមេរិក ។ លោកអាចប្រើប្រាស់ភាសាបរទេសបានច្រើនភាសាដូចជា បារាំង ថៃ ឡាវ និងភាសាអង់គ្លេស លោកអាចប្រើប្រាស់ជាផ្លូវការបាន ។ បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះ បានផ្តល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីធ្វើការសាកសួរដេញដោលបន្ត ។*

### ១) ការសាកសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

### ក) ប្រវត្តិ និងគោលបំណងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*លោក ច័ន្ទ តារាវស្មី សហព្រះរាជអាជ្ញារងជាតិបានសាកសួរលោក ឆាំង យុ ទាក់ទងនឹងការបង្កើតគោលបំណង និងកិច្ចការផ្សេងៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានឆ្លើយតបថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាអង្គការទី១ ដែលបង្កើតឡើងដើម្បីស្រាវជ្រាវឯកសារទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ការសិក្សា និងប្រមែប្រមូលឯកសារទាំងនេះករកើតឡើងដោយសារមាននិស្សិតច្បាប់ម្នាក់នៅសាកលវិទ្យាល័យយែល (Yale University) ឈ្មោះ ហ្គ្រេកគ្រី ស្តេនតុន (Gregory Stanton) បានមកធ្វើការជាមួយអង្គការអន្តរជាតិមួយចំនួននៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ ។ ពេលនោះគាត់បានឃើញរណ្តៅសាកសពដែលនៅសេសសល់ និងឃើញពីភាពលំបាកវេទនារបស់ប្រជាជនកម្ពុជា ។ នៅពេលត្រឡប់ទៅសហរដ្ឋអាមេរិកវិញ លោក ហ្គ្រេកគ្រី ស្តេនតុន បានបង្កើតឲ្យមានកម្មវិធីមួយឈ្មោះថា គម្រោងស្តីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា (Cambodian Genocide Project) នៅឆ្នាំ១៩៨០ ប៉ុន្តែគម្រោងនេះពុំទទួលបានការគាំទ្រឡើយនាពេលនោះ ។ ក្រោយមកទៀតមានគណៈកម្មការឯកសារកម្ពុជាដែលដឹកនាំដោយលោក ដេវីដ ហក (David Hawk) មកពីសាកលវិទ្យាល័យខូឡុំបៀ (Columbia) ដោយមានការឧបត្ថម្ភពីទាជ្ជទានជាតិប្រជាធិបតេយ្យ (National Endowment for Democracy) ហើយដែលការិយាល័យរបស់លោក ដេវីដ ហក នៅពេលនោះមានទីតាំងនៅឈៀងម៉ៃ ។ ក្រោពីនោះទៀតមានលោក ប្រវត្តិវិទូ ប៊ែន ឃៀរនិន*



*ច័ន្ទ តារាវស្មី សហព្រះរាជអាជ្ញារងជាតិ*

(Ben Kiernan), *លោកដេវីដ ឆេនដល័រ* (David Chandler) *លោកស្រី ប៊ូ ចន្ទូ*, *លោក ភីតធ័រ ម៉ាគ្វាយអឺ* (Peter Maguire) *ជាដើម ។ លោក ឆាំង យុ បានឮអំពី គម្រោងនោះនៅ ឆ្នាំ១៩៨៦-១៩៨៧ ដោយសារលោកមានមិត្តភក្តិជាជនជាតិអាមេរិកបានឲ្យឯកសារដែលមានឈ្មោះមេដឹកនាំខ្មែរក្រហម ។ នៅឆ្នាំ១៩៨៧ លោកបានទទួលសៀវភៅមួយក្បាលពីគ្រូបង្រៀនរបស់លោកដែលមានចំណងជើងថា «តើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា?» ដោយនៅក្នុងសៀវភៅនោះមានសរសេរថា «ថ្ងៃណាមួយលោកនឹងដឹងពីការពិតនូវមូលហេតុដែលនាំឲ្យលោកមករស់នៅសហរដ្ឋអាមេរិក» ។ ក្រោយមកទៀត នៅ ឆ្នាំ១៩៨៩-១៩៩០ មានយុទ្ធនាការមួយនៅរដ្ឋតិចសាស់ ដែលមានការចូលរួមពីច្រើនប្រទេសដើម្បីប្រឆាំងនឹងការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម ។ នៅពេលនោះលោក ឆាំង យុ ក៏បានស្ម័គ្រចិត្តចូលរួមយុទ្ធនាការនោះដំបូងរៀបចំឡើងដោយស្ត្រីស្ម័គ្រចិត្តម្នាក់ ឈ្មោះ* Ruth *ប៉ុន្តែក្រោយមកដែលស្ម័គ្រចិត្តដឹកនាំដោយលោក គ្រេក អេកឆេ សាន់ ។ ក្រោយមកទៀត លោក ឆាំង យុ បានទាក់ទងជាមួយ លោក បែន ឃៀរនិន ដើម្បីចាប់ផ្តើមគម្រោងមួយ និងសុំជំនួយឧបត្ថម្ភសម្រាប់ការស្រាវជ្រាវពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ ក្រោយមកគម្រោងនោះបានចាប់ផ្តើមនៅឆ្នាំ១៩៩៤ ពេលដែលសភាអាមេរិកបានអនុម័តច្បាប់ស្តីពីយុត្តិធម៌លើអំពើប្រល័យពូជសាសន៍នៅកម្ពុជា* (Cambodian Genocide Justice Act) ។

*លោក ឆាំង យុ បានបញ្ជាក់ថាគោលបំណងនៃការបង្កើតឲ្យមានមជ្ឈមណ្ឌលឯកសារនេះឡើងគឺដើម្បីធ្វើការចងក្រងឯកសារ និងស្វែងរកការផ្សះផ្សានៅក្នុងប្រទេស ។ លោកបានបន្តថា ការចងក្រងឯកសារគឺជាគោលបំណងចម្បងរបស់មជ្ឈមណ្ឌល ហើយដើម្បីធ្វើការចងក្រងនេះបានត្រូវឲ្យមានវិធីសាស្ត្របីយ៉ាង ។ ទីមួយ គឺការបង្កើតឲ្យមានតុលាការឯករាជ្យមួយដើម្បីធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទី២ គឺធ្វើឲ្យក្មេងជំនាន់ក្រោយបានចងចាំនិងរៀនសូត្រពីប្រវត្តិសាស្ត្រដែលបានកើតឡើង និងទី៣ គឺបង្កើតឲ្យមានមជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយដើម្បីរៀបចំ និងរក្សាឯកសារសម្រាប់ការប្រើប្រាស់នៅថ្ងៃក្រោយ ។*


ឆាំង យុ
នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

### ១) ជំនួយផ្នែកហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

*លោកសហព្រះរាជអាជ្ញារងជាតិបានបន្តការសាកសួរលោក ឆាំង យុ ទាក់ទងទៅនឹងការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានថ្លែងបញ្ជាក់នៅក្នុងសវនាការថា ម្ចាស់ជំនួយធំរបស់មជ្ឈមណ្ឌល គឺបានមកពីសហរដ្ឋអាមេរិក ដែលរួមមានជំនួយពីរដ្ឋាភិបាល អង្គការមួយចំនួន និងមួយផ្នែកទៀតបានមកពីសភាអាមេរិកដែលផ្តល់ទាយជ្ជទានចំនួន៤លានដុល្លារសហរដ្ឋអាមេរិក ។ម្ចាស់ជំនួយផ្សេងទៀតមានដូចជា អង្គការអាស៊ីបាស៊ីហ្វិកខាងកើត ដែលបានផ្តល់ជំនួយដល់មជ្ឈមណ្ឌលឯកសារកម្ពុជាតាំងពីដំបូង, ជំនួយផ្តល់ដោយមូលនិធិរបស់លោក* Patrick Leahy, *ជំនួយពីភ្នាក់ងារ សហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ* (USAID) *ដែលមានចំនួន៤សែនដុល្លារសហរដ្ឋអាមេរិក ។ ម្ចាស់ជំនួយធំទី២របស់មជ្ឈមណ្ឌល គឺបានមកពីរដ្ឋាភិបាលប្រទេសស៊ុយអែត ដែលមានទឹកប្រាក់ប្រហែល៣សែនដុល្លារ ។ ក្រៅពីនេះមានជំនួយផ្សេងៗទៀតបានមកពីប្រទេសបែលហ្សិក ដែលផ្គត់ផ្គង់លើគម្រោងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, ប្រទេសណ័រវេ ផ្គត់ផ្គង់លើការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត, ប្រទេសដាណឺម៉ាក*

ផ្គត់ផ្គង់លើគម្រោងដែលធ្វើការជាមួយសហគមន៍ ចាម មូស្លីម និង មានប្រទេសមួយចំនួនដូចជាកាណាដា អូស្ត្រាលី អង់គ្លេស គុយវ៉េត និងអាល្លឺម៉ង់ ។ លោក ឆាំង យុ ក៏បានលើកឡើងពីប្រទេសបារាំង ដែលបានផ្តល់ជំនួយយ៉ាងច្រើនគាំទ្រចំពោះតុលាការកាត់ទោស មេដឹកនាំខ្មែរក្រហម ប៉ុន្តែមិនដែលផ្តល់ជំនួយលើការងារប្រមូល ឯកសារឡើយ ។

ចំពោះការគ្រប់គ្រងលើផ្នែកហិរញ្ញវត្ថុវិញ លោក ឆាំង យុ មានប្រសាសន៍ថា លោកសាស្ត្រាចារ្យ ហេង វ៉ាន់ដា ដែលមាន ជំនាញខាងផ្នែកគណនេយ្យ ជាអ្នកត្រួតពិនិត្យលើប្រព័ន្ធគណនេយ្យ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានបញ្ជាក់ថា ចំពោះជំនួយដែលបានពីសហរដ្ឋអាមេរិក គឺមានការត្រួតពិនិត្យ តឹងរឹងលើបញ្ហាពុករលួយនៅក្នុងមជ្ឈមណ្ឌល ហើយប្រទេស ស៊ុយអែតវិញ ក៏មានការត្រួតពិនិត្យយ៉ាងខ្លាំងក្លាលើការគ្រប់គ្រង និងយែនឌឺដែរ ។

### គ) ការប្រមូល និងប្រភពនៃឯកសារ

បន្ទាប់ពីបានបញ្ចប់ការសាកសួរទាក់ទងនឹងហិរញ្ញវត្ថុនៅ ក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកសហព្រះរាជអាជ្ញារងជាតិ ច័ន្ទតារា ស្រី បានបន្តសំណួរទៅកាន់លោកឆាំងយុទាក់ទិនទៅនឹង ការប្រមែប្រមូលឯកសារ ។ លោក ឆាំង យុ បានមានប្រសាសន៍ថា ការប្រមូលឯកសារគឺមានអត្ថន័យពីរយ៉ាង ។ ទីមួយ មជ្ឈមណ្ឌល ឯកសារកម្ពុជាបានធ្វើការប្រកាសជាសាធារណៈ និងស្នើសុំដល់ បុគ្គល ស្ថាប័ន ឬប្រទេសណា ដែលមានឯកសារទាក់ទងនឹងរបប កម្ពុជាប្រជាធិបតេយ្យឲ្យប្រគល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬប្រគល់ជូនតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក្រោយ ពេលតុលាការនេះត្រូវបានបង្កើតឡើង *«យើងអំពាវនាវឲ្យមាន ការផ្តល់ជូនឯកសារទៅតុលាការដោយផ្ទាល់ ដូច្នេះតុលាការនឹង មានឯកសារនៅក្នុងដៃ»* ។ តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ ថារីក អាប់ឌុលហាក់ (Tarik ABDULHAK) បានសាកសួរទាក់ទង នឹងប្រភពឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួល ។ លោក ឆាំង យុ បញ្ជាក់ថា ឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារ កម្ពុជាទទួលបានពីប្រភពជាច្រើនមានទាំងប្រភពមកពីក្នុងប្រទេស និងប្រភពមកពីក្រៅប្រទេស ។

### ក.១. ប្រភពឯកសារដែលទទួលបានពីក្នុងប្រទេស

ប្រភពឯកសារនៅក្នុងប្រទេស គឺបានមកពីស្ថាប័នរដ្ឋ មួយចំនួន ដូចជា ក្រសួងមហាផ្ទៃ ក្រសួងអប់រំ បណ្ណសារដ្ឋានជាតិ សារមន្ទីរទួលស្លែង ការិយាល័យឃោសនាមជ្ឈិមដែលជាផ្នែក មួយរបស់ក្រសួងព័ត៌មាន ការិយាល័យស្រុក ខេត្ត និងពីបុគ្គល មួយចំនួន ។

### ក.១.១. ឯកសារដែលទទួលបានពីក្រសួងមហាផ្ទៃ

លោក ឆាំង យុ បានរៀបរាប់ថា មជ្ឈមណ្ឌលឯកសារ កម្ពុជាទទួលបានឯកសារពីក្រសួងមហាផ្ទៃ តាមរយៈការិយាល័យ ផ្សេងៗ នៅចន្លោះពីឆ្នាំ១៩៩៦-៩៩ ដែលឯកសារទាំងនោះ មានត្រូវបានបែងចែកជាពីរប្រភេទ គឺប្រភេទឯកសារក្រដាស និងរូបថត ។ លោកបានបញ្ជាក់បន្ថែមថា ការប្រមូលឯកសារពី ក្រសួងមហាផ្ទៃនេះធ្វើឡើងជាច្រើនដង ដោយសារមានឯកសារ ខ្លះត្រូវបានគេយកទៅខ្ចប់ចេកចៀន អ្នកខ្លះ យកទៅមូរធ្វើបារីជក់ ហើយអ្នកខ្លះទៀតយកឯកសារទៅទុកនៅឯផ្ទះខ្លួនឯងតែម្តងក៏ មាន ។ នៅឆ្នាំ១៩៨០ មានបុគ្គលិករបស់ក្រសួងមហាផ្ទៃមួយ ក្រុមបានប្រមូលឯកសារដែលនៅរប៉ាត់រប៉ាយយកទៅដាក់នៅ ក្នុងផ្ទះដែលស្ថិតនៅម្តុំផ្សារស៊ីឡឹប ។

លោក ឆាំង យុ បានបន្ថែមថា ចំពោះឯកសារក្រដាស ត្រូវបានលោក ប៉ែន យៀវនិន សន្និដ្ឋានថា ជាប្រភេទឯកសារ សន្តិបាលដែលរួមមានជាងមួយពាន់សំណុំរឿង នៅក្នុងនោះរួម មាន រូបថត, ឯកសារ ជាសំណេរ,ប្រវត្តិរូប,សំបុត្រទាក់ទងគ្នា, និងចម្លើយសារភាព ។ ចំពោះឯកសារប្រវត្តិរូប លោកបានបញ្ជាក់ ថាមានពីរសណ្ឋាន គឺប្រវត្តិរូបរបស់កម្មាភិបាលខ្មែរក្រហម និង ប្រវត្តិរូបរបស់អ្នកទោសដែលត្រូវបានគេចាប់ខ្លួនពីមូលដ្ឋាន ប៉ុន្តែ មានឯកសារខ្លះទៀតជាជីវទស្សន៍របស់កម្មាភិបាល ដោយលោក បានលើកជា ឧទាហរណ៍ ដូចជាឯកសាររបស់ សួង ស៊ីគឿន និង សមមិត្តគង់ ដែលឯកសារទាំងនោះត្រូវបានដាក់នៅលាយឡំគ្នា ។ ចំពោះឯកសារចម្លើយសារភាពដែលទទួលបានមានប្រហែលជាង មួយពាន់ឯកសារ ។ លោក ឆាំង យុ បានអះអាងថា ចម្លើយ សារភាពដែលបានមកពីក្រសួងមហាផ្ទៃ គឺខុសពីចម្លើយសារភាព ដែលបានមកពីសារមន្ទីរទួលស្លែង ដោយសារវាមានកម្រាស់

ក្រាស់ វាហាក់ដូចជាឯកសារឆ្លងឆ្លើយ ហើយមានចំណារនៅលើក្របមុខដែលចំណារទាំងនោះគឺមានសរសេរឈ្មោះកាត់ដូចជា អ៊ីនួន,សមមិត្តវ៉ាន់ ហើយពេលខ្លះគេប្រើជាលេខ ដែលគេអាចមើលឃើញពីភាពខុសគ្នានៃឯកសារទាំងនោះ ។ តាមរយៈចំណារនេះ គេក៏អាចឲ្យស្គាល់អ្នកដែលសរសេរចំណារទាំងនោះ ដោយសារមានការបញ្ជាក់ពីទិសដៅនៃឯកសារដែលត្រូវបញ្ជូន ដូចជាឯកសារត្រូវបញ្ជូនទៅភូមិភាគណាមួយច្បាស់លាស់ ។ ក្នុងចំណោមឯកសារទាំងនោះ មានតែចំនួន ៥ ទៅ៦ ឯកសារប៉ុណ្ណោះ ដែលដូចគ្នានឹងចម្លើយសារភាពនៅទួលស្លែង ក៏ប៉ុន្តែវាមិនមែនជាឯកសារស្ទួនឡើយ ដោយសារ អត្ថន័យ កម្រាស់ និងចំណារនៅលើឯកសារនោះខុសគ្នា ។

### ក.១.២. ឯកសារទទួលបានពីបណ្ណសារដ្ឋានជាតិ

ទាក់ទងនឹងឯកសារដែលបានពីបណ្ណសារដ្ឋានជាតិ លោក ឆាំង យុ បានបញ្ជាក់ថា លោកបានដឹងថាមានឯកសារនៅបណ្ណសារដ្ឋានជាតិ ដោយសារលោកបានអានសៀវភៅមួយក្បាលរបស់ប្រវត្តិវិទូ លោក ប៊ែនឃៀរនិន ទាក់ទងនឹងវិស័យពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្រោយមកលោកមានការចាប់អារម្មណ៍ និងបានធ្វើការស្រាវជ្រាវ ។ លោកបានបន្តថា រដ្ឋាភិបាលកម្ពុជាបានផ្តល់ជាយោបល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការសហការជាមួយបណ្ណសារដ្ឋានជាតិ និងសារមន្ទីរទួលស្លែង ។ លោកបានបន្ថែមថា លោកមិនមានបំណងយកឯកសារពីទួលស្លែង ឬបណ្ណសារដ្ឋានជាតិមកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ពីព្រោះស្ថាប័ននេះជាស្ថាប័នជាតិ ដូច្នេះលោកមានបំណងសុំយកឯកសារនោះមកធ្វើការថតចម្លង ដើម្បីជាការងាយស្រួលក្នុងការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ ។ លោក ឆាំង យុ បានរៀបរាប់ទៀតថា លោក និងក្រុមការងារបានចុះទៅធ្វើការស្រាវជ្រាវនៅបណ្ណសារដ្ឋានជាតិ តាំងពីឆ្នាំ១៩៩៥មកម្ល៉េះ ដោយចុះទៅទីនោះច្រើនដង ហើយការងារដំបូង គឺពិនិត្យមើលទៅលើបញ្ជីឯកសារ ។ ការចុះទៅសិក្សាច្រើនដង នេះគឺដើម្បីស្រាវជ្រាវរកឯកសារដែលនៅសេសសល់ដែលនៅរប៉ាត់រប៉ាយ ឬមិនទាន់បានរៀបចំជាដើម ។ លោកបានបញ្ជាក់ថា នៅពេលនោះប្រទេសយើងកំពុងមានការខ្វះខាត ប្រជាជនភាគច្រើនរវល់គិតគូរតែពី លើជីភាពរស់នៅ ជាជាងការយកចិត្តទុកដាក់ទៅលើឯកសារ ។ លោក ឆាំង យុ បានមានប្រសាសន៍ថា លោកធ្លាប់បានសាកសួរលោកស្រី លីម គី ដែលមានតួនាទីជាអនុប្រធាន និងលោក ស៊ិន ឃិន ជាប្រធានបណ្ណសារដ្ឋានជាតិទាក់ទងនឹងការប្រមូលចងក្រងឯកសារមកដាក់នៅបណ្ណសារដ្ឋានជាតិ ។ ឯកសារទាំងនោះ គឺត្រូវបានតម្កល់ទុកនៅក្រសួងវប្បធម៌ និងឃោសនាការ ដែលមានទីតាំងនៅជិតផ្សារអូរឬស្សី គ្រប់គ្រងដោយលោក កែវ ចិន្តា ដែលនៅពេលនោះ


គំនរឯកសារនៅសារមន្ទីរទួលស្លែង

លោកជាប្រធានតុលាការប្រជាជនបដិវត្តន៍ឆ្នាំ១៩៧៩ ។ ក្រោយមកឯកសារទាំងនោះត្រូវបានបញ្ជូនមកដាក់នៅបណ្ណសារដ្ឋានជាតិ ដែលជាកន្លែងតម្កល់ ឯកសាររបស់ជាតិ ។

### ក.១.៣. ឯកសារទទួលបានពីសារមន្ទីរទួលស្លែង

ចំពោះឯកសារដែលយកពីសារមន្ទីរទួលស្លែង លោក ឆាំង យុ បានរៀបរាប់ថា រាល់ឯកសារដើមទាំងអស់របស់សារមន្ទីរទួលស្លែង គឺរក្សាទុកនៅទីនោះដដែល ។ សារមន្ទីរទួលស្លែងទទួលបានការសហការពីសាកលវិទ្យាល័យ ខុនណែល

(Conell University) តាំងពីឆ្នាំ១៩៩២ មកម្ល៉េះ ដើម្បីធ្វើការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងអស់នៅទីនោះទៅតាមបទដ្ឋានត្រឹមត្រូវ ។ ក្រោយមកសាកលវិទ្យាល័យ យ៉េល និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅថតចម្លងឯកសារពីសារមន្ទីរទួលស្លែង ដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវ និងដោយមានការអនុញ្ញាតិពីរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយ ។ លោកបានបញ្ជាក់បន្ថែមថា លោកតែងតែចុះទៅស្រាវជ្រាវឯកសារនៅទីនោះជា



ច្រើនដង ដោយលោកមានការងឿងឆ្ងល់ថានៅសារមន្ទីរទួលស្លែងមានមនុស្សស្លាប់ជាងមួយម៉ឺននាក់ ប៉ុន្តែចម្លើយសារភាពមានតែជាងមួយពាន់ ហើយរូបថតអ្នកទោសមានតែជាង៥,០០០ ប៉ុណ្ណោះ ។ លោកបានសាកសួរលោក ជ័យ សុភារ៉ា ដែលជាប្រធានសារមន្ទីរទួលស្លែងអំពីថាតើបន្ទប់ណាមួយដែលមិនទាន់ត្រូវបានបោសសំអាត ។ លោក ឆាំង យុ បានរៀបរាប់បន្តថា លោកបានធ្វើការបោសសំអាតបន្ទប់ជាច្រើនដែលមិនដែលត្រូវបានប៉ះពាល់តាំងពីឆ្នាំ១៩៨០មក ។ នៅទីនោះ លោកបានរកឃើញឯកសារកំណត់ហេតុរបស់កម្មាភិបាលជាង៤០០ ដែលអ្នកទាំងនោះត្រូវបានចាប់ខ្លួនមក មន្ទីរស-២១ ។ ក្រៅពីនោះលោកបានរកឃើញសៀវភៅរូបថតអាពាហ៍ពិពាហ៍របស់ប្រធានគុកព្រៃសនៃ របបកម្ពុជាប្រជាធិបតេយ្យ ។ លោកបានធ្វើការពន្យល់ថាឯកសារមួយចំនួនដែលមានអក្សរ ធី.អេស.អិល (T.S.L) ឬធី.អិល (T.L) គឺជាប្រភេទឯកសារដែលត្រូវបានរកឃើញក្រោយពេលដែលឯកសារទាំងនោះ ត្រូវបានថតចម្លងដោយសាកលវិទ្យាល័យខុនណែលធ្វើម៉ៃក្រូហ្វីម (MicroFilm) រួចហើយ ។ ឯកសារមួយចំនួនបានបាត់បង់ ដោយសារមានអ្នកមកខ្ចីហើយមិនយកត្រឡប់មកវិញ និងការយកទៅដាក់តាមផ្ទះដោយលោកបានលើកឧទាហរណ៍ចំពោះឯកសារគំនូរបច្ចង់សាងសង់ជើងឯកដែលលោកបានរកឃើញនៅផ្ទះរបស់លោក អ៊ីង ប៊ិច ជាអតីតប្រធានសារមន្ទីរទួលស្លែង ហើយក្រោយមកត្រូវបានប្រគល់មកឲ្យលោក ។

### ក.១.៤. ឯកសារទទួលបានពីបុគ្គល

លោក ឆាំង យុ បានបញ្ជាក់ថា មានឯកសារមួយចំនួនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺទទួលបានពីបុគ្គល រួមមានឯកសារដែលទទួលបានពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន, លោកខៀវ កាញ៉ារិទ្ធ, លោក ស៊ូ ភិរិន្ទ ជាដើម ។ លោកបានបន្តថាឯកសារដែលមានដាក់អក្សរ អេក.អេស (H.S) គឺជាឯកសារដែលទទួលបានពីលោកនាយករដ្ឋមន្ត្រីហ៊ុនសែន ។ លោកបានបញ្ជាក់ថាលោកមិនបានដឹងថាឯកសារទាំងនោះ ត្រូវបានរកឃើញនៅក្នុងឆ្នាំណានោះទេ ប៉ុន្តែលោកទទួលបានឯកសារនេះក្នុងអំឡុងឆ្នាំ១៩៩៥ ឬ១៩៩៦ នៅពេលដែលលោកចាប់ផ្តើមអានសំណេររបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន នៅបណ្ណាល័យជាតិ ។ បន្ទាប់មកលោកបានទៅស្នើសុំឯកសារទាំងអស់នោះការិយាល័យរបស់លោកនាយករដ្ឋមន្ត្រី ដើម្បីតម្កល់ទុកនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយសារឯកសារទាំងនោះ គឺជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ ការិយាល័យរបស់លោកនាយករដ្ឋមន្ត្រីក៏បានប្រគល់ឯកសារទាំងនោះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ រីឯ ឯកសារមួយចំនួនទៀត គឺបានមកពីបុគ្គលិករបស់លោកដែលចុះទៅបំពេញការងារនៅតាមខេត្តក៏បានប្រមែប្រមូលឯកសារចាស់ៗរួមទាំងរូបថតជាដើម ។

### គ.២. ប្រភពឯកសារដែលទទួលបានពីក្រៅប្រទេស

លោក ឆាំង យុ បានបញ្ជាក់ថា ចំពោះឯកសារដែលបានមកពីបរទេសដូចជាឯកសារបានមកពីប្រទេសស៊ុយអែត គឺលោកបានទៅប្រមូលឯកសារនោះដោយផ្ទាល់ជាមួយបុគ្គលិកដែលទៅសិក្សានៅទីនោះ ។ លោកបានបញ្ជាក់ថា ដោយសារលោកមានបុគ្គលិកសិក្សានៅច្រើនប្រទេស ដូច្នេះរាល់ការប្រមូលឯកសារ គឺតែងតែមានការចូលរួមពីអ្នកទាំងនោះដែរ ។ លោកបានបន្ថែមថា មានបុគ្គលខ្លះបានប្រគល់ឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ ហើយមជ្ឈមណ្ឌលអាចយកឯកសារ នោះទៅប្រើប្រាស់តាមការចាំបាច់ ហើយក៏មានបុគ្គលមួយចំនួនផ្តល់ឯកសារដោយមានកំណត់លក្ខខណ្ឌមួយចំនួនរួមមានទាំងអ្នកផលិតខ្សែភាពយន្តឯកសារដែលបានផ្តល់ឯកសារសម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ លោកថារីកទាក់ទងនឹងឯកសារ ដែលផ្តល់ដោយលោក ដេវីដ ហក និងគណៈកម្មការប្រមូលឯកសារកម្ពុជា លោក ឆាំង យុ បានបញ្ជាក់ ថាឯកសារទាំងនោះមានដូចជា ទី១ រូបថតដែលមានពីរសណ្ឋាន គឺរូបថតមកពីសារមន្ទីរទួលស្លែង និងរូបថត ដែលលោក ដេវីដ ហក ថតដោយខ្លួនឯង រួមមានទីតាំងគុក រណ្តៅសាកសព វត្តអារាមបាក់បែក ។ ទីពីរ គឺឯកសារជាខ្សែអាត់ថតសម្ភាសន៍ បទសម្ភាសន៍ជាមួយចាម ឬស្លាម ឬព្រះសង្ឃ ឬជនភៀសខ្លួន ដែលមានជារបៀបបទសម្ភាសន៍ មានជាកាសែត និងអក្សរ លិខិតឆ្លើយឆ្លងរបស់លោកដែលបានស្នើសុំទៅ លោក អ៊ីង ប៊ិច ដើម្បីអនុញ្ញាតយកឯកសារ ដូចជានិក្ខេបបទ ហើយនិក្ខេបបទទាំងនោះមាននិយាយពីព្រះពុទ្ធ សាសនា ជនជាតិចិន និក្ខេបបទដែលគាត់រៀបចំដោយខ្លួនឯង បញ្ជីអ្នកទោសដែលស្លាប់ និងឯកសាររបស់អ្នកស្រាវជ្រាវមួយចំនួន ។ ឯកសារទាំងនោះត្រូវបានដឹកតាមកប៉ាល់មកពីរដ្ឋញូវជឺស៊ី (New Jersey) ជារដ្ឋដែលលោក ដេវីដ ហក រស់នៅ ។ ចំពោះឯកសារជារូបថត លោក ឆាំង យុ យកមកដោយខ្លួនឯងតាមយន្តហោះ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងឯកសារដែលទទួលបានពីប្រទេសស៊ុយអែត លោក ឆាំង យុ បានអះអាងថា ឯកសារទាំងនោះគឺលោកទទួលបានជាងប្រាំមួយទៅប្រាំពីរម៉ឺនទំព័រ ។ ឯកសារទាំងនោះត្រូវបានប្រមូលដោយគណៈកម្មាធិការមិត្តភាពកម្ពុជា វៀតណាម ឡាវ និងស៊ុយអែត ជាអង្គការមួយ ដែលគាំទ្រចលនាកម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩ ។ ឯកសារ មួយចំនួនទៀត គឺបានមកពីលោក អ៊ីហ្សី យ៉ាំង ជាជនជាតិអាមេរិកដែលទៅរស់នៅប្រទេស ស៊ុយអែត ចាប់តាំងពីពេលដែលមានសង្គ្រាមនៅប្រទេសវៀតណាម ។ លោក អ៊ីហ្សី យ៉ាំង បានផ្តល់ឯកសារដែលប្រមូលបានទៅឲ្យលោក ហ៊ុនណា គ្រប់គ្រង ហើយក្រោយមកលោក ហ៊ុនណា ក៏បានផ្តល់ឯកសារទាំងនោះ រួមទាំងឯកសារ ដែលគាត់មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលសុទ្ធសឹងជាឯកសារដើមទាំងអស់ ។ ចំណែកឯកសារ មួយចំនួនទៀត គឺបានទទួលពីសកលវិទ្យាល័យលូន (LUND University) ដែលជាប្រភេទឯកសារថតចម្លង ។ ចំណែកឯកសារមួយចំនួនទៀត គឺទទួលបានពីលោកស្រីសាស្ត្រាចារ្យ ឡូរ៉ា សាំមឺ (Laura Summer) ដែលសុទ្ធសឹងតែជាឯកសារដើម រួមទាំងឯកសារម៉ៃក្រូហ្វីមផង ។

### ឃ) ការរៀបចំឯកសារ

ទាក់ទងនឹងការរៀបចំចងក្រងឯកសារលោក ឆាំង យុ បានពន្យល់ថា លោកតែងតែអាន និងពិនិត្យរាល់ឯកសារដែលប្រមូលបានជាងមួយលានឯកសារ ដោយលោកបានធ្វើការប្រៀបធៀបថា ការអានឯកសារ គឺដូចជាអាហារពេលព្រឹករបស់លោក ។ លោកបានបញ្ជាក់ថា “គ្រប់ឯកសារទាំងអស់ដំបូងឡើង គឺខ្ញុំអានដូចខ្ញុំជម្រាបលោកអ៊ីចឹង គឺដូចជាអាហារពេលព្រឹករបស់ខ្ញុំអ៊ីចឹង ខ្ញុំអានឯកសាររាល់ថ្ងៃ” ។ លោកបានបន្ថែមថា “ចំពោះខ្ញុំ ការអានឯកសារប្រៀបដូចនឹងការរើសគ្រាប់បាយមួយគ្រាប់ពីសម័យ ប៉ុល ពត” ឯកសារខ្លះ លោកអានដល់ទៅពីរទៅបីដងឯណោះ បន្ទាប់ពីលោកបានអាន និងពិនិត្យរួចរាល់ហើយ ឯកសារទាំងនោះត្រូវបានបញ្ជូនទៅឲ្យអនុប្រធានរបស់លោកដើម្បីចាត់ចែង ដែលមានឲ្យបុគ្គលិករៀបចំ រហូតដល់ទៅ១២ជំហានមុននឹងបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រដូចជាការសង្ខេបសាច់រឿងដាក់នៅលើក្រដាសកិច្ចការ (worksheet) ការពិនិត្យ បកប្រែ និងមានការផ្ទៀងផ្ទាត់ជាមួយឯកសារដែលយើងបានថតចម្លងដើម្បីធានាឲ្យបាននូវភាពសុក្រិតតាមដែលអាចធ្វើទៅបាន ។ ការរៀបចំឯកសារ គឺត្រូវធ្វើ

ទៅតាមក្បួនខ្នាតដូចៗគ្នា ទោះបីជាឯកសារមកពីប្រភពណាក៏ដោយ ។ ការចុះលេខ មិនត្រូវបានធ្វើនៅលើឯកសារដើមទេ គឺធ្វើតែនៅលើឯកសារថតចម្លងតែប៉ុណ្ណោះ ដើម្បីរក្សានូវយថាភាពនៃឯកសារដើមទាំងអស់នោះ ។

## ខ) ការបញ្ជាក់យថាភាពនៃឯកសារ

ទាក់ទងនឹងយថាភាពនៃឯកសារ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក ថារីក បានស្នើលោក ឆាំង យុ ឲ្យធ្វើការបញ្ជាក់អំពីឯកសារមួយចំនួនដែលខ្លួនបានបង្ហាញនៅលើអេក្រង់កុំព្យូទ័រ ។ ឯកសារដែលត្រូវបានដាក់បង្ហាញនោះរួមមាន ឯកសាររបស់ក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ, ឯកសារទស្សនាវដ្ដីទង់បដិវត្ត, ឯកសារសន្តិបាល, ឯកសារប្រវត្តិរូប និងចម្លើយសារភាព, ឯកសារដែលជាសំបុត្រសរសេរដោយដៃឈ្មោះ សែ, ឯកសារចម្លើយសារភាពរបស់គិញ វៀតណាម, ឯកសារទូរលេខទំនាក់ទំនងរវាងភូមិភាគ និងមន្ទីរ៨៧០, ឯកសារប្រភេទឆ្លើយឆ្លងពីមន្ទីរទៅបុគ្គលម្នាក់ទៀត, ឯកសាររបស់ របប លន់ នល់, ឯកសារសេចក្ដីរាយការណ៍របស់គណៈកម្មាការតំបន់៥ ប្រចាំអាទិត្យ ។ល ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលសួរទាក់ទងនឹងឯកសាររបស់ក្រសួងដែលមាននៅក្នុងមន្ទីរ ស-២១ ឬ គុកទួលស្លែង លោក ឆាំង យុ បានអះអាងថា មិនមែនជាការចម្លែកទេដែលឯកសារមួយចំនួនចេញពីក្រសួង ទៅគុកទួលស្លែង ដោយសារតែសារឯកសារដទៃទៀត ដែលចេញមកពីភូមិឃុំ និងរូបថត ក៏បានចូលមកដល់គុកនេះដែរ ។ ចំពោះឯកសាររបស់របប លន់ នល់ ដែលមានការផ្លាស់ប្ដូរអក្សរសម្គាល់នោះ ត្រូវបានលោក ឆាំង យុ ពន្យល់ថា គឺដោយសារតែកាលពីពេលមុនឯកសាររបស់របប លន់ នល់ ត្រូវបានដាក់លេខសម្គាល់អក្សរ អិន (N) ប៉ុន្តែក្រោយមកអក្សរនេះត្រូវបានប្ដូរមកជាអក្សរ អិល (L) វិញ ដោយសារអក្សរ អិន ធ្លាប់ត្រូវបានប្រើប្រាស់ម្ដងរួចមកហើយ នៅក្នុងឯកសារផ្សេងៗ ។ ចំពោះឯកសារទាក់ទងនឹងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ លោក ឆាំង យុ បានបញ្ជាក់ថា ឯកសារទាំងនោះលោកទទួលបានពីលោក ប្រវត្តិវិទូ ប៉ែន យៀវនិន ។ ឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារងជាតិ លោក ច័ន្ទ តារាស្មី ដែលសួរថា តើលោកមានវិធីសាស្ត្រណាដើម្បីអាចដឹងថាឯកសារមួយជាឯកសារដើមរបស់របបកម្ពុជា ប្រជាធិបតេយ្យ? លោក ឆាំង យុ បានអះអាងថា លោកពិតជាជឿជាក់ថាឯកសារទាំងនោះគឺជាឯកសារដើមរបស់របបកម្ពុជាប្រជាធិបតេយ្យ ដោយបានផ្ដល់ហេតុផលថា ការជឿជាក់នេះ គឺដោយសារទី១ លោកមើលលើពណ៌នៃឯកសារ ព្រោះមនុស្សសំដៅដំបូងបំផុតលើពណ៌ ហើយលោកបានលើកឡើងពីសម្ដីរបស់វិចិត្រករម្នាក់ឈ្មោះ អាសាសាស្ត្រ ដែលថា បើគ្មានពណ៌មនុស្សនឹងស្លាប់, ទី២ មើលលើកាលបរិច្ឆេទនៃឯកសារ ទី៣ គឺមើលទៅលើអ្នកនិពន្ធឯកសារនៃឯកសារ ព្រោះជាទូទៅឯកសារខ្លះមានអ្នកនិពន្ធ ឯកសារខ្លះមិនមានអ្នកនិពន្ធទេ ទី៤ គឺមើលលើខ្លឹមសារ ឬសាច់រឿង ព្រោះឯកសាររបបកម្ពុជាប្រជាធិបតេយ្យមិនអាចនិយាយពីរឿងទ្រព្យសម្បត្តិ ឬក៏អ្នកចម្រៀងទេ ហើយភាសាដែលប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺខុសប្លែកគ្នាពីភាសាដែលប្រើប្រាស់នៅក្នុងពេលបច្ចុប្បន្ន ។ បន្ថែមលើនេះទៀត ឯកសារទាំងនោះ គឺមានមនុស្សច្រើនបានអានហើយបានទទួលថាពិតជាឯកសារមកពីរបបកម្ពុជាប្រជាធិបតេយ្យ ។

## ច) ការផ្ដល់ឯកសារ

ពាក់ព័ន្ធនឹងការផ្ដល់ឯកសារ លោក ឆាំង យុ បានបញ្ជាក់ថា ចាប់តាំងពីឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកជំហរសម្រាប់ឲ្យមន្ត្រីតុលាការទាំងអស់អាចចុះទៅធ្វើការសិក្សាស្រាវជ្រាវនិងស្វែងរកឯកសារ ។ លោកបានបន្ថែមថា មជ្ឈមណ្ឌលឯកសារកម្ពុជាថែមទាំងបានត្រៀមនូវទីកន្លែងសម្រាប់ភាគីដែលចុះមកស្រាវជ្រាវទៀតផង ដោយនៅក្នុងនោះមជ្ឈមណ្ឌលបានផ្ដល់ពេលវេលាសម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតអាចចុះមកធ្វើការសិក្សាបាននៅក្នុងថ្ងៃច័ន្ទ និងថ្ងៃអង្គារ រីឯក្រុមខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចចុះមកស្រាវជ្រាវនៅថ្ងៃពុធ ហើយថ្ងៃព្រហស្បតិ៍គឺសម្រាប់ខាងសហព្រះរាជអាជ្ញា និងថ្ងៃសុក្រ សម្រាប់ក្រុមមេធាវីការពារក្ដីឲ្យជនជាប់ចោទទាំងអស់ ។ លោកបានបញ្ជាក់ថា គ្រប់ឯកសារទាំងអស់ភាគីណាក៏អាចសុំបានដែរ ដោយមិនមានលាក់ទុកឯកសារណាមួយឡើយ សូម្បីគណបក្សប្រឆាំងក៏មជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានផ្ដល់ជូននូវឯកសារជាងមួយពាន់ទំព័រទៅតាមការស្នើសុំដែរ ។

### ២) ការសាកសួរដេញដោលសាក្សីដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

### ក) សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

រសៀលថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២ បន្ទាប់ពីការបញ្ចប់ការតាំងសំណួររបស់សហព្រះរាជអាជ្ញា លោកប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសាកសួរសាក្សីលោក ឆាំង យុ ។ សំណួរដំបូងរបស់លោកមេធាវី ពេជ អង្គ គឺទាក់ទងនឹងបេសកកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកឆាំងយុ បានពន្យល់ថាមជ្ឈមណ្ឌល



ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ឯកសារកម្ពុជាគឺមានបេសកកម្មក្នុងការស្វែងរកការពិត ដើម្បីការផ្សះផ្សារជាតិមួយពីអតីតកាល ។ នៅក្នុងសេចក្តីពន្យល់របស់លោកដើម្បីផ្សះផ្សារជាតិ យើងត្រូវធ្វើការងារបីគឺ ទីមួយ ត្រូវធ្វើឲ្យមានតុលាការមួយដើម្បីស្វែងរកជនណាមួយដែលបានប្រព្រឹត្តបទល្មើស និងដែលបានធ្វើឲ្យប្រជាជនខ្មែរស្លាប់អស់រាប់លាននាក់ ។ ទីពីរ លោកយល់ថាជាការចាំបាច់ណាស់គឺត្រូវមានការចងចាំ គឺសិស្សានុសិស្សក្មេងជំនាន់ក្រោយត្រូវរៀនសូត្រពីប្រវត្តិសាស្ត្រនេះ ។ ទីបីគឺចាំបាច់ត្រូវមានកន្លែងជាអចិន្ត្រៃយ៍មួយ ដើម្បីបន្តការស្រាវជ្រាវ និងដើម្បីជាវិធីមួយក្នុងការទប់ស្កាត់ អំពើនេះកុំឲ្យត្រឡប់មកវិញ ។ ដូចនេះជារួម មានគោលដៅតែមួយគឺការផ្សះផ្សារ ។ ប៉ុន្តែសំណួរខាងលើត្រូវបានលោក ខាណាវ៉ាស់ មេការពារក្តីឲ្យជនជាប់ចោទ អៀង សារី បានធ្វើការជំទាស់ ដោយផ្តល់ហេតុផលថា សំណួរនេះមិនមែនជាគោលបំណងនៃសវនាការ ។ លោកប្រធានអង្គជំនុំជម្រះសាលាដំបូងបានយល់ស្របចំពោះការជំទាស់ ដោយមានប្រសាសន៍ថា "ជំទាស់មានប្រសិទ្ធភាព" ។

បន្ទាប់មក លោកមេធាវី ពេជ អង្គ បានសាកសួរពីមុខងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានចោទជាសំណួរថា តើមជ្ឈមណ្ឌលឯកសាម្ពុជាធ្លាប់បានគិតថាខ្លួនជាស្ថាប័នស៊ើបអង្កេតលើបទឧក្រិដ្ឋដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? លោក ឆាំង យុ បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាស្ថាប័នច្បាប់ទេ ។ ឆ្លើយតបទៅនឹងសំណួរដែលទាក់ទងទៅនឹងការវិភាគឯកសារ លោក ឆាំង យុ បានលើកឡើងថា "យើងយកឯកសារមកអាន និងសរសេរ ។ អញ្ចឹង លោកថាវិភាគក៏ដោយ យើងចង់ថាអានក៏បាន សិក្សាស្រាវជ្រាវក៏បាន ។ ភាសាខ្មែរមានលក្ខណៈសម្បូរបែប ។ យើងចង់ប្រើពាក្យថាវិភាគក៏បាន និយាយក៏បាន សរសេរក៏បាន បានដូចៗគ្នា ។ អ៊ីចឹងត្រឡប់មកវិញគ្មានច្បាប់ណាមួយផ្តាច់មុខលើពាក្យហ្នឹងទេ" ។

លោក ឆាំង យុ បានពន្យល់ពីការងារមួយចំនួនទាក់ទងនឹងការប្រមូលឯកសារ ការធ្វើចំណាត់ថ្នាក់ ជាកាតាឡុក ការប្រើប្រាស់ឯកសារ និងការរក្សាឯកសារ ។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាមាន ឯកសារចំនួនប្រាំប្រភេទ ហើយការប្រមូលឯកសារគឺធ្វើឡើងតាមវិធីខុសៗគ្នា ប៉ុន្តែនៅពេលដាក់បញ្ចូលទៅក្នុងកាតាឡុកគឺធ្វើឡើងដោយមានក្បួនខ្នាតដូចៗគ្នា វិធីសាស្ត្រនេះនៅក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺអាចរកឃើញនៅក្នុងភាសាអង់គ្លេសថា "Manual" ។ បុគ្គលិកទាំងអស់ត្រូវបានពន្យល់ពីរបៀបធ្វើកាតាឡុក របៀបធ្វើតារាងការងារ របៀបបញ្ចូលទិន្នន័យរហូតដល់របៀបសរសេរឈ្មោះអ្នកដែលស្លាប់នៅក្នុងសម័យខ្មែរក្រហម ។ ការសរសេរឈ្មោះនេះ មជ្ឈមណ្ឌលឯកសាកម្ពុជាបានសាកសួរពីអ្នកជំនាញជាន់ខ្ពស់ពីរបៀបសរសេរនេះទៀតផង ។

លោក ឆាំង យុ បានបញ្ជាក់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការបែងចែកថាឯកសារណាមួយសំខាន់ជាងនោះទេ ឲ្យតែជាឯកសារទាក់ទងនឹងអំឡុងឆ្នាំ១៩៧៥-៧៩ គឺមានសារសំខាន់ដូចគ្នា ទោះបីជាឯកសារដែលលើកសរសើរពីរបប

កម្ពុជាប្រជាធិបតេយ្យ ដូចជាចំរៀងក៏ដោយ ។ លើកលែងតែឯកសារណាដែលមានការរៀបចំទុកដាក់ជាស្រេចហើយ ដូចជានៅទួលស្លែងជាដើម គឺលោកមិនធ្វើការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទេ ។ លោក ឆាំង យុ ក៏បានបញ្ជាក់ដែរថា ឯកសារខ្មែរក្រហមដែលចូលមកមជ្ឈមណ្ឌលរបស់លោកគឺត្រូវតែឆ្លងកាត់តុរបស់លោកជានិច្ច ហើយលោកតែងតែអានគ្រប់ឯកសារទាំងអស់លើកលែងតែឯកសារគណនេយ្យ ឬឯកសាររដ្ឋបាលដែលប្រើប្រាស់ប្រចាំថ្ងៃនៅការិយាល័យ ។

លោកមេធាវី ពេជ អង្គ បានសាកសួរពីភាពលាក់បាំងឯកសារចំពោះមេធាវីការពារក្តីឲ្យ ជនជាប់ចោទ ។ លោក ឆាំង យុ បានបដិសេធនឹងសំណួរនេះ ដោយពន្យល់ថា ការិយាល័យលោកត្រូវបានរៀបចំយ៉ាងស្អាតសម្រាប់ក្រុមមេធាវីការពារក្តីរៀងរាល់ថ្ងៃសុក្រ ។ គាត់ចង់មើលកន្លែងណាក៏បានគ្រប់សំណើទាំងអស់លោកតែងផ្តល់ជូនមួយរយភាគរយ លើកលែងតែគាត់មិនសុំ ។ លោកបានបន្តទៀតថា គ្រប់ភាគីទាំងអស់ គឺផ្តល់ជូនដូចៗគ្នា ។

### ១) សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីលោក ពេជ អង្គ បានបញ្ចប់សំណួររបស់ខ្លួនសហភាគីរបស់លោក គឺលោកស្រីមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត (Elisabeth SIMONNEAU FORT) បានបន្តការតាំងសំណួរទៅលោក សាក្សី ឆាំង យុ ។ លោកស្រីមេធាវី អេលីហ្សាប៊ែត បានធ្វើការតាំងសំណួរដំបូងដោយលើកយកសេចក្តីសម្រេចដែលលោក ឆាំង យុ បានជម្រាបជូនសហចៅក្រមស៊ើបអង្កេត ។ នៅក្នុងសេចក្តីសម្រេចនោះ បាននិយាយពីការគំរាមកំហែងពីបុគ្គលផ្សេងក្នុងគោលបំណងបញ្ឈប់ការស្រាវជ្រាវរបស់លោក ឆាំង យុ លើឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ។ ភ្លាមៗ លោក ខាណាវ៉ាស់ មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី បានធ្វើការជំទាស់ដោយផ្តល់ហេតុផលថា ការលើកយកឯកសាររបស់សហចៅក្រមស៊ើបអង្កេតមកប្រើនៅពេលនេះ គឺស្ថិតនៅក្រៅវិសាលភាពសវនាការ ដែលមិនទាក់ទងនឹងការប្រមូល និងការរៀបចំឯកសារជាដើម ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចច្រានចោលការជំទាស់របស់លោកមេធាវី ខាណាវ៉ាស់ ហើយផ្តល់ឱកាសឲ្យលោកស្រីមេធាវីបន្តការចោទសួរសំណួរនេះ ។ លោកស្រីបានសួរសាជាថ្មីដើម្បីឲ្យលោក ឆាំង យុ ធ្វើការបញ្ជាក់ពីការលើកឡើងដែលថាមានការគំរាមកំហែង ដើម្បីឲ្យលោក ឆាំង យុ ឈប់ធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ ។ លោក ឆាំង យុ បានបញ្ជាក់ជូនអង្គជំនុំជម្រះថា “មានការគំរាមកំហែងបងស្រីខ្ញុំមែន ដែលឲ្យបងស្រីខ្ញុំមកប្រាប់ខ្ញុំ ឲ្យខ្ញុំបញ្ឈប់ មិនមែនខ្ញុំចង់ឈប់ទេ ព្រោះអ្នកគំរាមកំហែងបានប្រាប់បងស្រីខ្ញុំ ថាឲ្យខ្ញុំនេះបញ្ឈប់ការសិក្សាស្រាវជ្រាវទៅ ។ ហើយសូមបញ្ជាក់ថា ការសិក្សាស្រាវជ្រាវនោះ ដើម្បីផ្សះផ្សារ ។ នេះមិនមែនជារឿង ប្រលោមលោក គឺជារឿងសំខាន់សម្រាប់ប្រទេសកម្ពុជា” ។ លោកស្រីមេធាវីបានលើកឡើងនូវសំណួរមួយ ទាក់ទងនឹងជំហរដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការតស៊ូប្រឆាំងនឹងនិទ្ទណ្ឌភាពនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ សំណួរគឺចង់ឲ្យលោក ឆាំង យុ បញ្ជាក់ថាតើការប្តេជ្ញាបែបនេះ អាចជះឥទ្ធិពលណាមួយដល់យថាភាពនៃឯកសារដែលប្រមូលបានដែរឬទេ? លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានជម្រាបជូនសវនាការទាំងមូលដោយលោកគិតថា ការសម្រេចចិត្តក្នុងការទប់ស្កាត់អំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ អំពើផ្សេងៗនេះ គឺជាការសម្រេចចិត្តមួយដែលមជ្ឈមណ្ឌលនេះមិនបានកែប្រែទេ ។ ការធ្វើបែបនេះគឺឈានជួយដល់ការចងចាំការទប់ស្កាត់និងការផ្សះផ្សារជាតិ ។ លោកបន្តទៀតថា វាមិនអាចប៉ះពាល់ដល់ឯកសារទេ ដោយសារឯកសារដែលបានយកមកត្រូវបានរក្សាទុកធម្មតា



លោកស្រី អេលីហ្សាបែត ស៊ីម៉ូណូ ហ្វត

*ហើយបើកជូនសាធារណៈជនធ្វើការស្វែងយល់ទាំងអស់គ្នា ។ លោកស្រីបានបន្តសួរទាក់ទងនឹងការប្រគល់ឯកសារថតចម្លងទៅស្ថាប័នទីមួយៗ នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក ឆាំង យុ បានអះអាងចំពោះសំណួរនេះថា មិនមានភាគីណាមួយមិនសប្បាយចិត្ត ឬជំទាស់ចំពោះការផ្តល់ឲ្យឯកសារថតចម្លងទេ ។ កន្លងមក ទាំងខាងមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងអស់ ទាំងខាងសហព្រះរាជអាជ្ញាគឺធ្វើការងារជាមួយមជ្ឈមណ្ឌលរបស់លោកក្នុងលក្ខណៈជាមិត្តភក្តិ ។*

**៣) ការសាកសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី**

**ក) សហមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន**

*នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ លោកឆាំង យុ បានបន្តការផ្តល់សក្ខីកម្មទាក់ទងនឹងបញ្ហាឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមការពិតគឺក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ដែលត្រូវធ្វើការតាំងសំណួរ ។ ប៉ុន្តែ មានការផ្លាស់ប្តូរដោយសារមានភារៈចាំបាច់របស់លោកមេធាវីអន្តរជាតិ ការពារក្តីជនជាប់ចោទ ខៀវ សំផន ។ នៅពេលចាប់ផ្តើមសវនាការលោក អាកទួរ វ៉ែកកែន* (Arthur Vercken) *មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បានធ្វើការស្នើសុំទៅអង្គជំនុំជម្រះអនុញ្ញាត*



**អាកទួរ វ៉ែកកែន មេធាវីអន្តរជាតិ ការពារក្តី ខៀវ សំផន**

*រំលែករយៈពេលប្រហែលមួយម៉ោងពីក្រុមមេធាវីរបស់ជនជាប់ចោទ នួន ជា ដើម្បីឲ្យខ្លួនធ្វើការសាកសួរទៅសាក្សីនៅព្រឹកថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ។ ចំណែកសហភាតារបស់ខ្លួន លោកមេធាវីគង់សំអុនទឹងសួរដេញដោលលោក ឆាំង យុ នៅថ្ងៃច័ន្ទទី៦ ខែកុម្ភៈ ឆ្នាំ២០១២វិញ ។ ក្រោយពីទទួលបានសំណើ និងដោយសារភាពចាំបាច់នេះលោកប្រធានចៅក្រម និល ណុន បានសម្រេចយល់ព្រមតាមសំណើរបស់ក្រុមមេធាវីជនជាប់ចោទ ខៀវ សំផន សួរមុនក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ។*

***ក.១. សហមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន***

*លោកមេធាវីអន្តរជាតិ អាកទួរ វ៉ែកកែន បានចាប់ផ្តើមតាំងសំណួរចំពោះលោក ឆាំង យុ ដំបូងទាក់ទងនឹងសារសំខាន់នៃឯកសារដើម និងឯកសារថតចម្លង ។ សំណួរនេះត្រូវបាន លោក ថារីក ជំទាស់ដោយផ្តល់ហេតុផលថាជាសំណួរមិនទាក់ទងនឹងគុណវុឌ្ឍិរបស់សាក្សី ហើយសំណួរនេះ គួរតែត្រូវបានសួរដោយអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះបានយល់ស្របនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។ បន្ទាប់មកលោកមេធាវីបានសួរសំណួរអំពីកន្លែងតម្កល់ឯកសារដើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ បើទោះបីជាលោក ឆាំង យុ បានឆ្លើយតបថាឯកសារដើមគឺស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយប៉ុន្តែលោកមេធាវីនៅតែទទូចសួរពីកន្លែងរក្សាឯកសារដើមជាក់លាក់ដដែល ។ លោកសាក្សី ឆាំង យុ បានសុំការអនុញ្ញាតពីអង្គជំនុំជម្រះចំពោះការផ្តល់នូវព័ត៌មានអំពីទីកន្លែងជាក់លាក់នេះដោយសារលោកមានការព្រួយបារម្ភចំពោះសុវត្ថិភាពនៃឯកសារដែលបានរក្សាទុកដោយសុវត្ថិភាពអស់រយៈពេលប្រហែល១៥ឆ្នាំមកហើយ ។ ស្របជាមួយគ្នានោះ លោកសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ ក៏បានជំទាស់ទៅនឹងការសួររបស់លោកមេធាវីអន្តរជាតិអំពីសំណួរទាំងនោះដោយអះអាងថា វាមានលក្ខណៈទូលាយពេក មេធាវីគួរតែកម្រិតសំណួរឲ្យចំឯកសារណាមួយ ដោយសារតែឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានដល់ទៅរាប់លានឯកសារ ។សហព្រះរាជអាជ្ញាបានបន្តទៀតថា មានឯកសារមួយចំនួន គឺស្ថិតនៅកន្លែងផ្សេងគ្នា ដូចជានៅបណ្ណសារដ្ឋានជាតិជាដើម ។ ការណ៍ដែលសាក្សីឆ្លើយតបរឿងប្រភពឯកសារដើមគឺជាបញ្ហារសើបមួយ ដូច្នេះគួរតែធ្វើសវនាការជាអសាធារណៈវិញ ។ លោកមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោកម៉ៃឃើល ផេស្តមេន បានធ្វើការគាំទ្រឲ្យមាន*

ការបើកសវនាការជាអសាធារណៈ ។ ឆ្លើយតបនឹងបញ្ហានេះ លោកប្រធានអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមិនអនុញ្ញាតឲ្យលោក ឆាំង យុ ឆ្លើយតបសំណួរខាងលើនេះទេ ។ លោក ឆាំង យុ បានបន្ថែមថា បើសិនជាភាគីទាំងអស់ ចង់ផ្ទៀងផ្ទាត់ឯកសារថតចម្លងជាមួយឯកសារដើម មជ្ឈមណ្ឌលឯកសារកម្ពុជាធានាជួយគ្រប់ពេលវេលា ។

បន្ទាប់មកលោកមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បន្តសួរទៅលោក ឆាំង យុ អំពីគម្រោងកិច្ចព្រមព្រៀងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងតុលាការថាតើមានការទទួលស្គាល់យ៉ាងណាខ្លះ? លោក ឆាំង យុ បានជម្រាបជូនអង្គជំនុំជម្រះថា

«ពីដំបូងយើងមានការព្រួយបារម្ភពីការស្នើសុំពីតុលាការចំពោះឯកសារដែលយើងមាន ហើយយើងបានគិតទុកតាំងពីឆ្នាំ២០០៥ ។ ខ្ញុំបានសរសេរលិខិតជូនទៅរាជរដ្ឋាភិបាលបានទៅជួបនៅអគ្គការសហប្រជាជាតិដូចខ្ញុំបានជម្រាបពីម្សិលមិញអ៊ីចឹងខ្ញុំបានទៅជួបលោកស្រី មីសែល លី និងលោក ស៊ាន វិសុទ្ធ ។ ហើយយើងបានឲ្យធ្វើពង្រាង បានធ្វើជាពង្រាងអ្វីដែលយើងធ្វើអ្វីៗជាពង្រាងជូនជាយោបល់ថាតើដើម្បីទទួលបានឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ថាតើយើងគួរតែមានកិច្ចព្រមព្រៀងដែរឬក៏យ៉ាងណា? យើងបានព្យាយាមធ្វើនៅឆ្នាំ ២០០៥ ២០០៦ ២០០៧ ២០០៨ រហូតយើងបានស្នើសុំម្តងទៀតនៅក្រោយការលាលែងរបស់ លោក ស៊ាន វិសុទ្ធ ហើយនិងលោកស្រី មីសែល លី ។ យើងបានស្នើសុំជាថ្មីជូនលោក ឃុត និងលោក ក្រាញ់ តូនី ដើម្បីពិចារណាឡើងវិញ ។ ប៉ុន្តែ រហូតដល់ឆ្នាំ២០០៩ ហាក់ដូចជា គ្មានការឆ្លើយតបសោះ ។ យើងក៏បោះបង់គំនិតនេះ ពីព្រោះថានៅរយៈពេលឆ្នាំ២០០៦ដល់ឆ្នាំ២០០៩គ្រប់អង្គភាពទាំងអស់ធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងបានឆ្លើយតបគ្រប់សំណើទាំងអស់ ទាំងក្រុមការពារក្តីជនចុងចោទទាំងការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញា ហើយនឹងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ អ៊ីចឹង ក៏យើងអនុវត្តការស្នើសុំរវាងតុលាការ និងស្ថាប័នយើង ដែលគេចាត់ទុកថាជាកន្លែងបណ្ណសារដ្ឋាន ។ អ៊ីចឹងយើងគ្មានការព្រមព្រៀងអ្វីទាំងអស់ជាមួយតុលាការនេះជាផ្លូវការទេបាទ» ។

លោកមេធាវីអន្តរជាតិបានបន្តសួរអំពីរបៀបនៃការប្រគល់ឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជាជូនស្ថាប័ននីមួយៗនៅតុលាការ ។ ឆ្លើយតបនឹងសំណួរនេះ លោក ឆាំង យុ បានរៀបរាប់ថា ការបញ្ជូនឯកសារមកការិយាល័យសហព្រះរាជអាជ្ញាការិយាល័យសហចៅក្រមស៊ើបអង្កេត និងក្រុមមេធាវីការពារជនជាប់ចោទ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាមានបញ្ជីមួយសម្រាប់បង្ហាញថា ឯកសារនេះស្កេនចេញ ឬ ក៏ថតចម្លងចេញពីឯកសារដើម មានការចុះហត្ថលេខាមានការទទួលជាក់លាក់ពីភាគីដែលស្នើសុំ ។ លើកលែងតែការិយាល័យការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ដែលបានស្នើសុំធ្វើការស្កេនឯកសារចេញពីឯកសារដើមដោយខ្លួនឯងតែម្តង ។ ឆ្លើយតបទៅនឹងសំណួររបស់មេធាវី វ៉េកគែន មួយចំនួនកន្លងមក លោក ឆាំង យុ បានផ្តល់ព័ត៌មានខ្លះៗអំពីការប្រមូលឯកសារ ។ លោកបានជំទាស់យ៉ាងដាច់ខាតចំពោះការលើកឡើងរបស់មេធាវី វ៉េកគែន ដែលថាលោក ឆាំង យុ កាលពីម្សិលបានលើកឡើងថាលោកបានទទួលឯកសារពីអ្នកជំនាញការវៀតណាម ។ លោក ឆាំង យុ បានទាមទារឲ្យមេធាវីបង្ហាញភស្តុតាងណាមួយដែលច្បាស់ថា លោកផ្ទាល់ពិតជាបាននិយាយអ៊ីចឹងមែន ។ ដោយមិនមានភស្តុតាងក្នុងការបញ្ជាក់ លោកមេធាវីបានប្តូរសំណួរថ្មី ដោយបានសួរថាតើលោក ឆាំង យុ ចាំបានដែរឬទេថា ខ្លួនបាននិយាយពីអ្នកជំនាញការវៀតណាមប្រាប់ទៅសហចៅក្រមស៊ើបអង្កេត ។ លោក ឆាំង យុ បានឆ្លើយតបថា លោកមានការរីករាយនឹងឆ្លើយសំណួរនេះ ប៉ុន្តែលោកមានការសោកស្តាយ ការណ៍ដែលមេធាវីមិនបានទទួលស្គាល់ថា ខ្លួនមានចេតនាសួរសំណួរដែលគ្មានមូលដ្ឋានជាក់លាក់ដែលជាការបង្ខូតពេលវេលាមួយរបស់តុលាការ ។ លោកសាក្សីបានឆ្លើយតបថា ចំពោះអ្នកជំនាញការវៀតណាម គឺមានជនជាតិវៀតណាម ធ្វើការជាមួយនឹងបុគ្គលិកនៅក្រសួងមហាផ្ទៃកាលពីមុនពេលលោកទទួលបានឯកសារពីក្រសួងនេះ ។ លោកបានព្យាយាមសួរបុគ្គលិកនៅទីនោះពីជនជាតិវៀតណាមនោះដែរ ប៉ុន្តែក្រោយមកលោកបានទទួលដំណឹងថាគាត់ស្លាប់បាត់ទៅហើយ ។

ឆ្លើយតបនឹងលោកមេធាវីអន្តរជាតិ អំពីសំណួរទាក់ទងនឹងរយៈពេលនៃការប្រមូលឯកសារ លោក ឆាំង យុ បានរៀបរាប់យ៉ាងក្បោះក្បាយថា ការប្រមូលឯកសារ គឺធ្វើឡើងជាបន្តបន្ទាប់ មិនអាចថាមួយរយៈពេលក៏ចប់នោះទេ ។ ឯកសារមិនមែនសំដៅតែទៅលើតែក្រដាស វត្ថុតាង រូបថត ខ្សែភាពយន្តឡើយ មនុស្សក៏ជាឯកសារដែរ ។ លោក ឆាំង យុ បានរំឭកថា មានប្រជាជនខ្មែររាប់លាននាក់ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយលោកនឹងសាកសួររឿងរ៉ាវរបស់ពួកគាត់ដើម្បីចងក្រងជាឯកសារទុកឲ្យកូនខ្មែរជំនាន់ក្រោយបានដឹង ។ លោកមិនអាចឆ្លើយថាត្រូវការរយៈប៉ុន្មានទៀត ដើម្បីធ្វើការងារប្រមូលឯកសារនេះទេ វាមានលក្ខណៈអចិន្ត្រៃយ៍ ដើម្បីទប់ស្កាត់អំពើនេះ គឺត្រូវមានកន្លែងមួយជាអចិន្ត្រៃយ៍ ហើយបន្តសាកសួរអ្នកដែលរស់រានមានជីវិតទាំងអស់ ព្រោះរឿងនេះជារឿងប្រវត្តិសាស្ត្រ ។

### ក.២. សហមេធាវីជាតិការពារក្តី ខៀវ សំផន

បន្ទាប់ពីមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ធ្វើការតាំងសំណួរចប់ លោកមេធាវី ជាតិ គង់ សំអុន បានបន្តសំណួរពីសហភាគារបស់ខ្លួន ។ លោកមេធាវី គង់ សំអុន បានសួរសំណួរជាច្រើនទាក់ទងនឹងយថាភាពនៃឯកសារ ។ លោក ឆាំង យុ បានបញ្ជាក់ថា នៅមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមានអ្នកជំនាញធ្វើការទាក់ទងនឹងយថាភាពនៃឯកសារនេះទេ ។ លោកបានបន្តទៀតថាពាក្យអ្នកជំនាញ នោះវាមានន័យទូលាយពេកសម្រាប់លោក ព្រោះលោកមិនដឹងយកអ្វីមកកំណត់ជាអ្នកជំនាញនោះឡើយ ។ នៅមជ្ឈមណ្ឌលរបស់លោកមានតែបុគ្គលិកដែលធ្វើការទាក់ទងនឹងឯកសារអស់រយៈពេលប្រហែល១៧ឆ្នាំមកហើយ ។ លោក ឆាំង យុ បានបន្ថែមថា *“បើលោកមេធាវីយល់ថាបទពិសោធន៍១៧ឆ្នាំ នេះមិនគ្រប់គ្រាន់ក្នុងការធ្វើការងារនេះ ប្តូរតែទៅរៀនយកសញ្ញាប័ត្រទៀតនោះក៏លោកដឹងដែរ”* ។ បុគ្គលិករបស់លោកខ្លះធ្លាប់ទទួលការបណ្តុះបណ្តាលពីសាកលវិទ្យាល័យញ៉ូវសោវែល ប្រទេសអូស្ត្រាលី និងមួយចំនួនទៀត គឺបានទទួលការបណ្តុះបណ្តាលពីលោកស្រី ហេឡែន ចារីស និងជំនួយការ



របស់គាត់ ។ កាលនោះលោក ស្រី ចារីស ជាបណ្ណារក្ស អ្នកទទួលបន្ទុកក្នុងការបណ្តុះបណ្តាលការចងក្រងឯកសារនៅសាកលវិទ្យាល័យនោះ ។ គាត់បានមកបណ្តុះបណ្តាលបុគ្គលិកផ្សេងទៀតនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទាល់ជាមួយនឹងជំនួយការរបស់គាត់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលការណ៍ជាលាយលក្ខណ៍អក្សរក្នុងការផ្ទៀងផ្ទាត់ថាភាពនៃឯកសារ ។ ដោយមានជាកម្រងសំណួរមួយចំនួនសម្រាប់សួរនៅពេលដែលមានការផ្ទេរឯកសារចូលមកក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកផ្តល់ឯកសារខ្លះមិនចង់ឲ្យមានការសួរនាំអីច្រើនទេ ។ ដូចនេះលោក បានផ្តល់ព័ត៌មាន ដែលលោកទទួលបានពីអ្នកទាំងនោះទៅឲ្យសារព័ត៌មានដើម្បីចុះផ្សាយ ថាឯកសារនោះត្រូវបានផ្តល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបើកចំហរជូនសាធារណៈជន ។ លោក ឆាំង យុ បានបញ្ជាក់ថា រាល់ឯកសារដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា លោកតែងតែព្យាយាមសួរនាំពីប្រភពដើមបំផុតនៃឯកសារនោះតាមលទ្ធភាពដែលអាចសួរបានជានិច្ច ។ ប៉ុន្តែ លោកបានរំពឹកថា ចំពោះការពិនិត្យក្រដាសតាមលក្ខណៈវិទ្យាសាស្ត្រមជ្ឈមណ្ឌលរបស់លោកមិនដែលបានធ្វើទេ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់បង្ហោះឯកសាររបស់ខ្លួនដែលមានបួនប្រភេទ ដូចជា រូបថត ទីតាំងរណ្តៅសាកសព ឯកសារប្រវត្តិរូប និងឯកសាររួម ។ ប៉ុន្តែការដាក់បង្ហោះលើគេហទំព័រក្នុងប្រព័ន្ធអ៊ីនធឺណេត មិនត្រូវបានដាក់ឯកសារដែលមានទាំងស្រុងនៅឡើយទេ ដោយសារតែបញ្ហាប្រព័ន្ធអ៊ីនធឺណេតមានកម្រិត និងដោយសារមូលហេតុខ្វះធនធាន និងពេលវេលា ។ ពាក់ព័ន្ធនឹងការវាយតម្លៃទៅលើឯកសារ លោក ឆាំង យុ បានពន្យល់ថាលោក ប៉ែន យៀរនិន អ្នកប្រវត្តិវិទូបានធ្វើការវាយតម្លៃជាលក្ខណៈបុគ្គលទៅលើសំណុំឯកសារសន្តិបាលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលពីក្រសួងមហាផ្ទៃ ។ លោក ប៉ែន យៀរនិន ថែមទាំងបានសរសេរជាសេចក្តីសង្ខេបមួយអំពីការវាយតម្លៃថាតើឯកសារនោះមានលក្ខណៈយ៉ាងណាទៀតផង ។ ចំពោះឯកសារផ្សេងទៀតដូចជា ឯកសារមកពីបណ្ណសារដ្ឋានជាតិ ដោយសារជាស្ថាប័នជាតិដែលបានបង្កើតដោយអនុក្រិត្យដូចនេះលោកបានសួរអ្នកទទួលបន្ទុកផ្នែកឯកសារនៅទីនោះដោយផ្ទាល់ ។ លោកសាក្សីក៏បានបន្តទៀតថា "ឯកសារនេះតាមដែលខ្ញុំចាំ បាទ គឺមកពីក្រសួងព័ត៌មាន និងវប្បធម៌នៅក្នុងសតវត្សរ៍៨០ ដែលកាលនោះមានលោក កែវ ចិន្តា ជារដ្ឋមន្ត្រី ហើយជាប្រធានតុលាការកំពូលនៃការកាត់ក្តីឆ្នាំ១៩៧៩ ។ អ៊ីចឹង ឯកសារនោះ គឺនៅទីនោះ ហើយដោយសារថា បណ្ណសារដ្ឋានជាតិមានក្រឹត្យ មានគោលការណ៍ក្នុងការថែរក្សារបស់ជាតិ ក៏ត្រូវបាននាំយកមកទុកនៅបណ្ណសារដ្ឋានជាតិ ។ ត្រង់ថា លោកស្រី លីម គី អ្នកទទួលបន្ទុកផ្នែកឯកសារគាត់វិភាគ សរសេរ យ៉ាងម៉េច ខ្ញុំគិតថា ប្រហែលជាមិនមានការបោះពុម្ពវិភាគនេះទេ ។ ប៉ុន្តែ ខ្ញុំគិតថាអាចសួរគាត់បាន បើសិនចាំបាច់" ។

## ២) សហមេធាវីការពារក្តីជនជាប់ចោទ នួន ជា

បន្ទាប់ពីមេធាវីរបស់ជនជាប់ចោទ ខៀវ សំផន បានសួរលម្អិតអំពីប្រភពដើមនៃឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបានដើម្បីបញ្ជាក់ពីយថាភាពនៃឯកសារទាំងនោះ មេធាវីរបស់ជនជាប់ចោទ នួន ជា បានបន្តសួរដោយផ្តោតសំខាន់ទៅលើកម្មវត្ថុ និងភាពមិនលម្អៀងរបស់មជ្ឈមណ្ឌលឯកសារ កម្ពុជា ។

### ២.១. សហមេធាវីអន្តរជាតិការពារក្តី នួន ជា

ក្នុងការសួរដេញដោលលោក ឆាំង យុ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា លោកហ្សាស្ព៊ើ ប៉ៅ (Jasper PAUW) ផ្តោតសំខាន់លើបញ្ហាទូទៅមួយចំនួនពាក់ព័ន្ធនឹងការប្រមូល និងការផ្តល់ឯកសារ ការវិភាគឬវាយតម្លៃលើឯកសារ ។ ជាពិសេស មេធាវីផ្តោតលើបញ្ហាជាក់លាក់មួយចំនួនពាក់ព័ន្ធ


ហ្សាស្ព៊ើ ប៉ៅ មេធាវីអន្តរជាតិ
ការពារក្តី នួន ជា

នឹងអត្ថបទ និងគម្រោងមួយចំនួនដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ការកំណត់ឈ្មោះ និងការប្រមូលឯកសារជាក់លាក់ សម្រាប់បុគ្គលដែលនឹងត្រូវនាំមកកាត់ទោសការធ្វើកោសល្យវិច័យលើឯកសារ ការប្រមូលចងក្រងឯកសារដោយអ្នកជំនាញការវៀតណាមជាដើម ។

### ២.១.១. អំពីបញ្ហាទូទៅ

### ២.១.១.១. ការប្រមូលឯកសារ

ការប្រមូលឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានគ្រប់ភាគីទាំងអស់សួរដេញដោល ។ មេធាវីរបស់ជនជាប់ចោទ នួន ជា គឺលោក ហ្សាស្តី ប៉ោ បានសួរពីឯកសារដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រឹត្តិការណ៍កើតនៅក្នុងរបបសាធារណៈរដ្ឋខ្មែរ (របប លន់ នល់) ។ ជាក់ស្តែងមេធាវីបានលើកឡើងថា *“សម័យកម្ពុជាប្រជាធិបតេយ្យ គឺចោទប្រកាន់អំពីការស្លាប់មនុស្សជាច្រើននាក់ដូច្នេះហើយវាអាចមានមូលហេតុផ្សេងទៀត ដែលបណ្តាលឲ្យមនុស្សស្លាប់ដូច្នេះ ។ ដូច្នេះនៅក្នុងការស្រាវជ្រាវរបស់លោកដែលរកឃើញឯកសារណាមួយ ឬភ័ស្តុតាងណាមួយ ដែលអាចពន្យល់អំពីការស្លាប់របស់មនុស្សទាំងឡាយដែរឬទេ? ឧទាហរណ៍ ឯកសារនោះវាអាចពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែករបស់អាមេរិកកាំង ឬក៏ឯកសារដែលពាក់ព័ន្ធទៅនឹងការកាប់សម្លាប់សាហាវយោរយៅពីសម័យ លន់ នល់ តើធ្លាប់មានការជួបឯកសារប្រភេទហ្នឹងដែរឬទេ?”* ។ លោកមេធាវីបានធ្វើការសួរដេញដោលអំពីឯកសារដែលអាចរកបាននៅក្នុងបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា ទៀតផង ។

ឆ្លើយតបទៅនឹងសំណួរទាំងនេះ លោក ឆាំង យុ បានលើកឡើងថា មជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់ចុះធ្វើការសម្ភាសន៍ជាមួយប្រជាជនរស់នៅខេត្តស្វាយរៀងដែលជាដំបន់មួយទទួលរងការទម្លាក់គ្រាប់បែកច្រើនជាងគេរបស់សហរដ្ឋអាមេរិក ។ រាល់ការផ្តល់បទសម្ភាសន៍ គាត់អាចនិយាយរៀបរាប់ពីជីវិតរបស់គាត់ដែលខ្វះនិយាយតាំងពីឆ្នាំ១៩៥០-១៩៦០ ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងការរស់នៅក្នុងរបប ប៉ុល ពត ។ បទសម្ភាសន៍ទាំងនេះធ្លាប់ត្រូវបានសរសេរជាអត្ថបទដើម្បីបោះផ្សាយ នៅក្នុងទស្សនាវដ្តីស្វែងរកការពិត ។ ក្រៅពីឯកសារបទសម្ភាសន៍ មជ្ឈមណ្ឌលក៏ធ្លាប់ប្រទះឃើញបំណែកគ្រាប់ទាំងនោះនៅសេសសល់ និងធ្លាប់ទទួលបានព័ត៌មានអំពីប្រជាជនដែលបានស្លាប់ដោយសារការអត់ចំណីអាហារ ឬថ្នាំសង្កូវ ។ លោក ឆាំង យុ បញ្ជាក់យ៉ាងច្បាស់ថា *“រាល់ឯកសារដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនថា មួយឃ្លា ពីរឃ្លា ឬមួយសន្លឹក ហើយឯកសារនោះនិយាយល្អ ឬអាក្រក់អំពីរបបខ្មែរក្រហមនោះទេ ឲ្យតែជួបប្រទះ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការប្រមូលយកទាំងអស់ ។ ជាក់ស្តែងមជ្ឈមណ្ឌលបានប្រមូលចម្រៀងបដិវត្តន៍បានជាច្រើនដែលនិយាយល្អៗ ឬសមិទ្ធិផលដែលបានធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ”* ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា លោក ឆាំង យុ បានលើកឡើងថា នៅឆ្នាំ១៩៩៣ គណបក្សប្រជាជនមានបណ្ណសារដ្ឋានមួយមានឈ្មោះថា “គណៈកម្មាធិការប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តកម្ពុជា” ដែលមានកិច្ចសហការរវាង កម្ពុជា វៀតណាម និង ឡាវ ដោយមានការគាំទ្រពីសហភាពសូវៀត ។ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ប្រមូល ចងក្រង និងផ្លាស់ប្តូរឯកសាររវាងប្រទេសទាំងបី ដើម្បីសរសេរប្រវត្តិរបស់បក្សរួមគ្នា ។ ប៉ុន្តែបណ្ណសារដ្ឋាននេះត្រូវបានបិទបន្ទាប់ពីប្រទេសកម្ពុជាមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដោយសារមានការផ្លាស់ប្តូររបបនយោបាយ ។ លោក ឆាំង យុ បានបញ្ជាក់ថា ទោះបីបណ្ណសារដ្ឋាននេះត្រូវបានបិទ តែលោកបានព្យាយាមរកឯកសារទាំងនោះតាមរយៈការសាកសួរទៅលោក ជ័យ សុផុន ដែលធ្លាប់ជាប្រធានរបស់គណៈកម្មាធិការនេះ និងលោក សាយ ឈុំ ដែលជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា និង ថែមទាំងបានធ្វើដំណើរទៅកាន់ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីស្វែងរកឯកសារទាំងនោះ ។ បន្ថែមលើនេះលោកបានយកព័ត៌មានទាំងនោះមកធ្វើការផ្សព្វផ្សាយជាសាធារណៈ និងបានជូនដំណឹងទៅដល់តុលាការដើម្បីធ្វើការស្វែងរកបន្ថែម ។

### ២.១.១.២. ការផ្តល់ឯកសារ

ការផ្តល់ឯកសារដោយមជ្ឈមណ្ឌលឯកសារកម្ពុជាជូន

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺនៅតែជាមន្ទិលសង្ស័យសម្រាប់មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ។ លោកមេធាវី ហ្សាស្តេ ប៉ៅ បានចោទសួរថា តើរាល់ការផ្តល់ឯកសារជូនការិយាល័យសហព្រះរាជអាជ្ញាមានការពិភាក្សាគ្នាជាមុនរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យរបស់សហព្រះរាជអាជ្ញាដែរឬទេ មុននឹងការិយាល័យសហព្រះរាជអាជ្ញាធ្វើសំណើសុំឯកសារ? ឬនិយាយម្យ៉ាងទៀតថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានជូនដំណឹងជាមុនអំពីឯកសារណាមួយដល់ការិយាល័យសហព្រះរាជអាជ្ញាដែរឬទេ មុននឹងការិយាល័យនេះធ្វើសំណើសុំ? លោក ឆាំង យុ បានឆ្លើយតបដោយលើកឡើងថា គ្មានការពិភាក្សាលើឯកសារណាមួយរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយការិយាល័យណាមួយរបស់តុលាការ មុននឹងឯកសារនោះត្រូវបានស្នើសុំឡើយ ។ គ្រប់ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ជូនតុលាការ គឺត្រូវមានសំណើសុំជាមុន ដែលសំណើសុំនេះត្រូវតែកត់លេខឯកសារដែលឯកសារនេះអាចរកបាននៅក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

**១.១.១.៣. ការចាត់ថ្នាក់ឯកសារដែលផ្តល់ជូនតុលាការថាជាការសម្ងាត់**

ភាពចាប់អារម្មណ៍របស់លោកមេធាវី ហ្សាស្តេ ប៉ៅ ចំពោះឯកសារដែលបានផ្តល់ជូនតុលាការ គឺមជ្ឈមណ្ឌលបានប្រើពាក្យថា "ជាការសម្ងាត់" ។ លោកមេធាវីបានលើកយកឯកសារមួយដែលនិយាយពី គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនិស្តកម្ពុជា ដែលឯកសារនេះបានប្រើពាក្យ "ជាការសម្ងាត់" ។ ឆ្លើយតបចំពោះការលើកឡើងនេះ លោក ឆាំង យុ បំភ្លឺថាមូលហេតុដែលលោកប្រើពាក្យនេះ គឺដោយសារឯកសារដែលមជ្ឈមណ្ឌលបានផ្តល់ជូនតុលាការត្រូវបានអ្នកធ្វើការនៅទីនោះយកទៅប្រើប្រាស់ផ្ទាល់ខ្លួននៅក្រៅតុលាការ ។ ដូចនេះរាល់ឯកសារដែលមជ្ឈមណ្ឌលបានផ្តល់ជូនតុលាការ គឺជាទូទៅលោក


ទូរឯកសារនៅសារមន្ទីរទួលស្លែង

ប្រើពាក្យថា "ជាការសម្ងាត់" ដែលបញ្ហានេះលោកធ្លាប់បានប្រាប់ការិយាល័យនីមួយៗរបស់តុលាការរួចហើយ ។ ប៉ុន្តែលោក ឆាំង យុបញ្ជាក់ថាឯកសារទាំងនេះគឺមាននៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលសាធារណជនអាចធ្វើការសិក្សាស្រាវជ្រាវបាន ។

### ១.១.១.៤. អំពីការវិភាគ ឬវាយតម្លៃឯកសារ

សំណួរពាក់ព័ន្ធនឹងការវិភាគ ឬវាយតម្លៃលើឯកសារដែលថាឯកសារណាមួយមានតម្លៃដាក់បន្ទុក ឬដោះបន្ទុកនោះត្រូវបានមេធាវីការពារក្តីជនជាប់ចោទសួរម្តងហើយម្តងទៀត ពោលគឺមេធាវីធ្លាប់បានសួរលោក វ៉ាន់ថាន់ដារ៉ាពៅ អំពីបញ្ហានេះម្តងរួចហើយ ហើយសំណួរដដែលនេះត្រូវបាន យកមកសួរជាថ្មីម្តងទៀត ។ លោកឆាំងយុបញ្ជាក់ថាមជ្ឈមណ្ឌល ឯកសារកម្ពុជាមិនដែលវាយតម្លៃឯកសារណាមួយថា ជាឯកសារដាក់បន្ទុក ឬដោះបន្ទុកលើជនជាប់ចោទឡើយ ។ សម្រាប់រូបលោកផ្ទាល់ លោកមិនមែនជាមេធាវី ឬអ្នកច្បាប់ទេ ដូចនេះរាល់ការអានឯកសារលោកមិនចូលចិត្តធ្វើការវិភាគក្នុងន័យច្បាប់ឡើយ គឺចូលចិត្តអានក្នុងន័យប្រវត្តិសាស្ត្រជាង ។

ភ្ជាប់ទៅនឹងបញ្ហាខាងលើមេធាវី ហ្សាស្តេ ប៉ោ បានលើកឡើងអំពីពាក្យ "ភស្តុតាង" ដែលពាក្យនេះ ត្រូវបានប្រើនៅក្នុងឯកសារមួយចំនួន និងក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងការស្រាយបំភ្លឺពាក្យនេះ លោក ឆាំង យុ បានបកស្រាយថា ពាក្យ "ភ័ស្តុតាង" មិនត្រូវបានច្បាប់ចែង ឬកំណត់ឲ្យប្រើផ្តាច់មុខឡើយ ។ នៅក្នុងន័យនេះពាក្យ "ភស្តុតាង" អាចត្រូវបានប្រើដោយអ្នកសង្គមវិជ្ជា អ្នកប្រវត្តិសាស្ត្រ ដើម្បីបង្ហាញព្រឹត្តការណ៍ពិតណាមួយនៅក្នុងអតីតកាល ។ ដូចនេះអ្នកច្បាប់អាចប្រើពាក្យនេះក្នុងន័យច្បាប់ ហើយអ្នកសង្គមវិទ្យា និងអ្នកប្រវត្តិសាស្ត្រអាចប្រើពាក្យនេះក្នុងន័យប្រវត្តិសាស្ត្រ ។ ដូចនេះលោកបានប្រើពាក្យ "ភស្តុតាង" នេះដើម្បីបង្ហាញពីព្រឹត្តការណ៍ពិតកើតមានឡើងដែលនាំឲ្យមានការស្លាប់ប្រជាជនជាច្រើនលាននាក់ ។

### ១.១.២. សំណួរពាក់ព័ន្ធនឹងបញ្ហាជាក់លាក់

### ១.១.២.១. អំពីបុគ្គលជាក់លាក់ដែលត្រូវនាំមកជំនុំជម្រះទោស

សំណួរជាច្រើនត្រូវបានលើកឡើងដោយមេធាវី ហ្សាស្តេ ប៉ោ ពាក់ព័ន្ធនឹងបុគ្គលជាក់លាក់ដែលត្រូវនាំយកមកកាត់ទោសដើម្បីបញ្ជាក់ថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលបំណងឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមជាក់លាក់ណាមួយដែរឬទេ ។ លោកមេធាវីបានចោទ សួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបញ្ជីឈ្មោះមេដឹកនាំខ្មែរក្រហមដែលនឹងត្រូវនាំមកកាត់ទោសដែរឬទេក្នុងកំឡុងទសវត្សរ៍ឆ្នាំ៩០? ហើយបានធ្វើការប្រមូលឯកសារជាសំណុំសម្រាប់បុគ្គលជាក់លាក់ណាមួយដែរឬទេ?

ឆ្លើយតបទៅនឹងការចោទសួរទាំងនេះ លោក ឆាំង យុ បានលើកឡើងថា ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាស្ថាប័នតុលាការ ឬជាចៅក្រម ដូចនេះមជ្ឈមណ្ឌលមានតួនាទីត្រឹមតែជាអ្នកប្រមូលឯកសារដើម្បីបម្រើដល់សាធារណជន ឬតុលាការជាអ្នកធ្វើការវិនិច្ឆ័យដោយខ្លួនឯង ។ លោកបានបន្ថែមថា លោកមានបំណងឲ្យមានការនាំយកមេដឹកនាំខ្មែរក្រហមទាំងឡាយណាដែលទទួលខុសត្រូវចំពោះការសម្លាប់ប្រជាជនជាង២លាននាក់ ដែលគោលបំណងនេះលោកធ្លាប់បានថ្លែងជាសាធារណៈជាច្រើនដង ។

ចំពោះបញ្ជីឈ្មោះបុគ្គលដែលត្រូវនាំយកទៅកាត់ទោស លោក ឆាំង យុ បានលើកឡើងថា នៅឆ្នាំ១៩៩៥-១៩៩៦ មជ្ឈមណ្ឌលឯកសារកម្ពុជានៅត្រឹមតែជាការិយាល័យសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យយែល ដែលមានលោក ប៊ែន ឃៀរនិន ជាប្រធាន ។ ក្នុងកំឡុងពេលនោះការិយាល័យនេះ បានបោះផ្សាយជាសាធារណៈនូវសៀវភៅមួយនិពន្ធដោយលោក ប៊ែន ឃៀរនិន មានចំណងជើងថា "អំពើប្រល័យពូជសាសន៍នៅកម្ពុជា (Genocide in Cambodia)" ដែលក្នុងសៀវភៅនេះមានបញ្ជីឈ្មោះ មេដឹកនាំខ្មែរក្រហមមួយចំនួននៅទំព័រ១៣-១៤ ។ បន្ទាប់ពីមជ្ឈមណ្ឌលឯកសារកម្ពុជាឯករាជ្យពីសាកលវិទ្យាល័យយែល មជ្ឈមណ្ឌលបានធ្វើការសិក្សាស្រាវជ្រាវ និងបានប្រមូលចងក្រងឈ្មោះកម្មាភិបាលខ្មែរក្រហមបន្ថែមលើបញ្ជីឈ្មោះរបស់សាស្ត្រាចារ្យ ប៊ែន ឃៀរនិន ហើយបានដាក់ឈ្មោះថា "ប្រវត្តិរូបរបស់មេដឹកនាំខ្មែរក្រហម (Biography of the Khmer Rouge

Leaders)» ។ ការចងក្រងនេះធ្វើឡើងក្នុងគោលបំណងបម្រើដល់ការសិក្សាស្រាវជ្រាវ និងបន្ទាប់ពីមានសំណើសុំឯកសារដែលពាក់ព័ន្ធនឹងកម្មាភិបាលទាំងនោះ ។

ចំពោះការប្រមូលចងក្រងឯកសារសម្រាប់បុគ្គលជាក់លាក់ លោក ឆាំង យុ បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការប្រមូលចងក្រងឯកសារប្រភេទនេះជាច្រើន គឺតាមការស្នើសុំរបស់អ្នកសិក្សាស្រាវជ្រាវ ឬរបស់បុគ្គលណាដែលមានបំណងស្វែងរកគ្រួសារ ។ មជ្ឈមណ្ឌលធ្លាប់បានធ្វើការប្រមូលជាបណ្តុំឯកសារដូចជា ព័ត៌មានរបស់អ្នកស្លាប់ណាម្នាក់ មន្ត្រីសន្តិសុខ នានា កម្មាភិបាលខ្មែរក្រហម ថ្នាក់ក្រោម កម្មាភិបាលថ្នាក់កណ្តាល រហូតដល់កម្មាភិបាលស្ថិតក្នុងជួរថ្នាក់ដឹកនាំដូចជាទាក់ទងនឹងលោក អៀងសារី (ហៅ អ៊ីវ៉ាន់) លោក នួន ជា (ហៅ អ៊ីនួន) លោក ខៀវសំផន (ហៅ អ៊ីហែម) និងមានអ្នកផ្សេងៗទៀតជាច្រើន ។ ក្រៅពីឈ្មោះបុគ្គលជាក់លាក់មជ្ឈមណ្ឌលក៏បានប្រមូលឯកសារផ្សេងទៀត ដូចជាឯកសារ សាទូរលេខ ដែលឯកសារនេះត្រូវបានប្រមូលចងក្រង បានចំនួនពីរទូរតាមរយៈសំណើរបស់លោក ស្ទីវហេដឌ័រ (Steve Heder) ដើម្បីធ្វើការសិក្សាស្រាវជ្រាវដោយលោកបានសរសេរសៀវភៅមួយដែលមានចំណងជើងថា “SevenCandidates” ។ លោក ឆាំង យុ បានបញ្ជាក់ថា ឯកសារដែលត្រូវបានប្រមូលចងក្រងតាមសំណើសុំ គឺត្រូវបានថតចម្លងចេញពីឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានស្រាប់ហើយ គោលបំណងក្នុងការចងក្រង គឺដើម្បីមានភាពងាយស្រួលក្នុងការផ្តល់ឲ្យអ្នកសិក្សាស្រាវជ្រាវផ្សេងៗទៀត ក្នុងករណីមានសំណើសុំដូចគ្នានេះ ។

សំណួរមួយចំនួនត្រូវបានមេធាវីចោទសួរពាក់ព័ន្ធនឹងការកំណត់យុត្តាធិការបុគ្គល ដើម្បីឆ្លុះបញ្ចាំងពីការប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកមេធាវី ហ្សាស្ទើ ប៉ៅ បានសួរថា «តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានចូលរួមក្នុងការកំណត់យុត្តាធិការបុគ្គល (បុគ្គលដែលអាចនឹងត្រូវនាំមកកាត់ទោស) របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរឬទេ? មេធាវីបានពន្យល់ថាមូលហេតុដែលខ្លួនសួរសំណួរនេះ គឺដោយសារថា ក្នុងករណីមជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមកំណត់យុត្តាធិការបុគ្គលរបស់តុលាការ នោះមជ្ឈមណ្ឌលអាចសម្រេចចិត្តប្រមូល ឬមិនប្រមូលឯកសារជាក់លាក់ណាមួយដែលពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ សំណួរនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាធ្វើការជំទាស់ ហើយប្រធានអង្គជំនុំជម្រះសម្រេចមិនឲ្យសាក្សីឆ្លើយអំពីបញ្ហានេះឡើយ ដោយផ្តល់ហេតុផលដូចគ្នាថា «សំណួរនេះហួសពីវិសាលភាពដែលត្រូវសាកសួរសាក្សី» ។

### ៦.១.២.២. អំពី Manual (ក្បួនខ្នាត)

ទាក់ទងនឹងប្រអប់លេខ ៣១៧ លោក ឆាំង យុ បានលើកឡើងថា ប្រអប់នេះត្រូវបានប្រើដើម្បីកត់ត្រាអំពីប្រភពដើមនៃឯកសារដែលបានផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ រាល់ឯកសារ ដែលទទួលបានត្រូវកត់ត្រាពីប្រភពដើម ដើម្បីងាយស្រួលក្នុងការរក ។ តែឯកសារខ្លះមិនត្រូវបានកត់ត្រាប្រភពដើមនៅក្នុងប្រអប់នេះទេ តែត្រូវបានធ្វើកំណត់ហេតុបញ្ជាក់ពីប្រភពដែលបានឲ្យឯកសារនោះ មូលហេតុ ដោយសារអ្នកផ្តល់ឯកសារខ្លះមិនមានបំណងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដាក់ឈ្មោះរបស់ខ្លួននៅក្នុងប្រអប់ដែលបង្ហាញពីប្រភពដើមនៃឯកសារនោះ ។

នៅពេលបញ្ចប់នៃការសួរដេញដោលលើបញ្ហានេះ មេធាវី ហ្សាស្ទើ ប៉ៅ បានធ្វើការកត់សម្គាល់ថា ខ្លួននៅមានភាពមន្ទិលសង្ស័យជាច្រើនចំពោះប្រភពឯកសារដែលមាននៅក្នុងប្រអប់លេខ៣១៧ ដោយសារឯកសារមួយចំនួនមិនត្រូវបានបញ្ជាក់ពីប្រភពនៅក្នុងប្រអប់នោះឡើយ ។

### ៦.១.២.៣. អំពីការធ្វើកោសល្យវិច័យលើឯកសារ

ក្នុងការឆ្លើយថាភាពនៃឯកសារ មេធាវី ហ្សាស្ទើ ប៉ៅ បានចោទសំណួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកោសល្យវិច័យណាមួយលើឯកសារ ដើម្បីបញ្ជាក់ថាជាឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? លោក ឆាំង យុ បានបញ្ជាក់យ៉ាងច្បាស់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលធ្វើកោសល្យវិច័យលើឯកសារណាមួយដើម្បីកំណត់ថាឯកសារណាមួយមានអាយុកាលប៉ុន្មានឆ្នាំឡើយ ។ ប៉ុន្តែ ដើម្បីកំណត់ថាឯកសារណាមួយជាឯកសារដែលធ្វើឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺលោកធ្វើការ ពិនិត្យទៅលើពណ៌ និងទំហំរបស់ក្រដាស កាលបរិច្ឆេទ

របស់ឯកសារ ឈ្មោះអ្នកនិពន្ធ ការប្រើប្រាស់ពាក្យពេជន៍ មើលខ្លឹមសារទាំងស្រុងរបស់ឯកសារនោះ ដែលខ្លឹមសារទាំងនេះមានភាពប្រទាក់ក្រឡាគ្នាពីឯកសារមួយទៅឯកសារមួយទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានកិច្ចសហការជាមួយបណ្ណសារដ្ឋានជាតិ និងសារមន្ទីរទួលស្លែង ដែលអ្នកទាំងនោះបានធ្វើការជាច្រើនឆ្នាំមកហើយក្នុងការប្រមូលចងក្រងឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។

**ខ.១.២.៤. អំពីសៀវភៅខ្មៅ**


KAMPUCHEA DEMOCRATIQUE

LIVRE NOIR

FAITS ET PREUVES
DES ACTES D'AGRESSION ET D'ANNEXION
DU VIETNAM CONTRE LE KAMPUCHEA

PHNOM PENH SEPTEMBRE 1978

គម្របសៀវភៅខ្មៅដែលជាភាសាបារាំង

សំណួរទាក់ទងនឹងសៀវភៅខ្មៅត្រូវបានសួរម្តងរួចហើយទៅកាន់លោក វ៉ាន់ថាន់ ដាវ៉ាពៅ ជាថ្មីម្តងទៀត មេធាវី ហ្សាស្តើ ប៉ោ បានសួរពីប្រភព និងច្បាប់ដើមនៃសៀវភៅនេះ ។ បន្ថែមលើចម្លើយរបស់លោក ដាវ៉ាពៅ លោក ឆាំង យុ បានលើកឡើងថា សៀវភៅខ្មៅនេះមានច្បាប់ដើមជាភាសាបារាំង និងត្រូវបានបកប្រែជាភាសាអង់គ្លេស ហើយបានបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៧៨ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។ នៅទំព័រចុងក្រោយនៃសៀវភៅនេះគឺមានផែនទីមួយដែលធ្វើឡើងប្រហែលឆ្នាំ១៩៧២ ឬ១៩៧៣ ដោយក្រសួងព័ត៌មានរបស់របបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្ហាញពីសមត្ថភាពរបស់ខ្លួនដែលបានចាប់ផ្តើមគ្រប់គ្រងតំបន់ទាំងអស់មុនឆ្នាំ១៩៧៥ ។ លោកបានបន្ថែមថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានច្បាប់ដើមសៀវភៅនេះ ទាំងភាសាបារាំង និងភាសាអង់គ្លេស ហើយសៀវភៅនេះក៏អាចរកបានផងដែរ ដែលមាននៅជាមួយលោក ហ៊ុនណា ប៊ីយស្រ្តម (ជាសកម្មជនម្នាក់គាំទ្ររបបកម្ពុជាប្រជាធិបតេយ្យ) និងលោកស្រីសាស្ត្រាចារ្យ ឡូរ៉ា សាំម៉ឺ ។

**ខ.១.២.៥. អំពីការប្រមូលចងក្រងឯកសារ ដោយអ្នកជំនាញការវៀតណាម**

លោកមេធាវី ហ្សាស្តើ ប៉ោ បានចោទសំណួរជាច្រើនអំពីការប្រមូលឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩ ។ ជាក់ស្តែងមេធាវីបានចោទសួរថា តើវៀតណាមធ្វើការប្រមូលឯកសារដូចម្តេចដើម្បីធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ។ ឆ្លើយតបទៅនឹងសំណួរនេះ លោក ឆាំង យុ បានលើកឡើងថា លោកមិនបានដឹងថា វៀតណាមធ្វើការប្រមូលឯកសារ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដោយរបៀបណានោះឡើយ ដោយសារក្នុងកំឡុងពេលនោះ លោកមិនមានវត្តមាននៅប្រទេសកម្ពុជា ។ តែអ្វីដែលលោកបានដឹង គឺពិតជាមានអ្នកជំនាញការវៀតណាម នៅប្រចាំប្រទេសកម្ពុជា ដើម្បីធ្វើការរៀបចំចងក្រងឯកសារដែលមាននៅក្រសួងមហាផ្ទៃ ។

ក្នុងការចោទសំណួរពាក់ព័ន្ធនឹងបញ្ហានេះ លោកមេធាវីហ្សាស្តើបានស្នើឲ្យលោក ឆាំង យុ ធ្វើការបញ្ចេញមតិយោបល់ចំពោះការប្រមូលឯកសារដើម្បីកាត់ទោសក្នុងឆ្នាំ១៩៧៩ ដោយសារការកាត់ទោសពេលនោះត្រូវបានគេទទួលស្គាល់ថាមិនមានភាពយុត្តិធម៌ និងថាតើវៀតណាមធ្វើការប្រមូលឯកសារដោយធ្វើការដកចេញនូវឯកសារដោះបន្ទុកណាមួយលើជនជាប់ចោទដែរឬទេ? សំណួរទាំងនេះត្រូវបានជំទាស់ ដោយតំណាង

សហព្រះរាជអាជ្ញាអន្តរជាតិ ថាវីក ដោយលើកហេតុផលថាការស្នើសុំនេះគឺហួសពីសមត្ថភាព និងវិសាលភាពដែលនឹងត្រូវសួរដេញដោលលើសាក្សី ។ ការជំទាស់នេះត្រូវបានលោកប្រធានអង្គជំនុំជម្រះសម្រេចថាមានប្រសិទ្ធភាព និងបង្គាប់ឲ្យមេធាវីសួរសំណួរផ្សេងពីនេះ ។

សំណួរចុងក្រោយពាក់ព័ន្ធនឹងបញ្ហានេះ មេធាវីបានចោទសួរថា ក្នុងអំឡុងពេលវៀតណាមមកធ្វើជាអ្នកជំនាញការនៅកម្ពុជាក្រោយរបបខ្មែរក្រហមដួលរលំ តើឯកសារទាំងនោះអាចត្រូវបានបង្កើតឡើង ដោយវៀតណាមដែរឬទេ? លោក ឆាំង យុ បានលើកឡើងថា ប្រសិនប្រទេសវៀតណាមអាចធ្វើបានដូចនេះប្រាកដមែននោះវៀតណាមនឹងជាប្រទេសដ៏អស្ចារ្យបំផុតនៅក្នុងពិភពលោក ព្រោះឯកសារទាំងនោះ មានរាប់លានសាច់រឿងផ្សេងៗគ្នាដែលកើតនៅទូទាំងប្រទេស ដែលសាច់រឿងទាំងនោះមានភាពប្រទាក់ក្រឡាគ្នា ។ ម្យ៉ាងទៀត ពាក្យពេចន៍ដែលប្រើនៅក្នុងឯកសារទាំងនោះមានភាពលំបាក ដែលវៀតណាមប្រហែលជាមិនដឹងថាមានន័យដូចម្តេចផង ។ លោកបានបន្ថែមថា នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ការងារប្រមូលចងក្រងឯកសារ គឺមិនមែនសុទ្ធតែវៀតណាមទាំងអស់មកធ្វើការងារនេះឡើយ ពោលគឺប្រជាជនខ្មែរជាច្រើនបានចូលរួមក្នុងការធ្វើកិច្ចការនេះ ។

**១.១.២.៦. អំពីអត្ថបទ «Documenting the Crimes of Democratic Kampuchea»**

លោកមេធាវី ហ្សាស្តេ បានចោទសួរថា តើលោក ឆាំង យុ ពិតជាបាននិពន្ធអត្ថបទនេះជាមួយលោក ចន ឆរឆីអារី (John Ciorciari ) ដែរឬទេ? ឆ្លើយតបទៅនឹងសំណួរនេះ លោក ឆាំង យុ បានលើកឡើងថា នៅក្នុងអត្ថបទនេះប្រើពាក្យ "ជាមួយ" (John Ciorciari with Youk Chhang) មិនបានប្រើពាក្យ "និង" នោះទេ ។ ដូចនេះវាច្បាស់ណាស់ដែលលោកមិនមានចំណែកស្មើក្នុងការនិពន្ធអត្ថបទនេះ ពោលគឺលោក ចន ជាអ្នកសរសេរអត្ថបទនេះ ដោយយោងលើបទសម្ភាសន៍ដែលលោកបានផ្តល់ឲ្យ ហើយរាល់ការវិភាគ គឺជាគំនិតរបស់អ្នកនិពន្ធ ។ លោក ឆាំង យុ បន្ថែមថា វាជាការភ្ញាក់ផ្អើលមួយសម្រាប់រូបលោក ដោយសារឯកសារនេះត្រូវបាននិពន្ធ និងធ្វើការផ្សព្វផ្សាយតាំងពីឆ្នាំ២០០៤ ហើយភាគីមិនបានដឹង ។

លោកមេធាវីស្នើសុំឲ្យសាក្សីពន្យល់ឃ្លាមួយនៅក្នុងអត្ថបទនេះដែលនិយាយថា "ឯកសារជាច្រើនត្រូវបានបំផ្លាញចោលដោយសារមូលហេតុនយោបាយ" ។ លោក ឆាំង យុ បានបញ្ជាក់ថា បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ខ្មែរក្រហមបានបំផ្លាញឯកសាររបស់ខ្លួនចោលជាច្រើន ដើម្បីលាក់កំបាំងចំពោះអំពើដែលខ្លួនបានធ្វើក្នុងរបបនយោបាយរបស់ខ្លួន ។

**១.១.២.៧. អំពីគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ**

សំណួរជាច្រើនត្រូវបានមេធាវី ហ្សាស្តេ ប៉ៅ ចោទសួរពីគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្កើតគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ ។ ជាក់ស្តែងមេធាវីបានចោទសួរថា ហេតុអ្វីគម្រោងនេះធ្វើការសម្ភាសន៍ពីខ្សែចង្វាក់នៃការបញ្ជា? ហើយតើគម្រោងនេះជម្រុញឲ្យមានការកាត់ទោសជនជាប់ចោទដែលមាននៅក្នុងសំណុំរឿង០០២ ឬយ៉ាងណា? ឆ្លើយតបទៅនឹងការចោទសួរទាំងនេះ លោក ឆាំង យុ បានលើកឡើងថា គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីបង្ហាញឲ្យឃើញថា "អ្នកណាជាអ្នកបញ្ជា ដែលធ្វើឲ្យស្លាប់ប្រជាជនជាង២លាននាក់ ព្រោះរាល់ការសម្ភាសន៍ជាមួយកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម គឺតែងតែបដិសេធថាខ្លួនមិនបានសម្លាប់ ឬមិនមានសិទ្ធិបញ្ជាសម្លាប់មនុស្ស" ។ ដូចេ្នះ គម្រោងនេះ ត្រូវបានបង្កើតឡើងដើម្បីជំរុញឲ្យមេដឹកនាំខ្មែរក្រហមណា ដែលជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់ត្រូវបាននាំមកជំនុំជម្រះទោសនៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងជាពិសេសធ្វើឲ្យមានការផ្សះផ្សាជាតិមួយឲ្យបានពេញលេញ ។ លោក ឆាំង យុ បានបន្ថែមថា បទសម្ភាសន៍ទាំងនោះត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឲ្យសាធារណជនទូទៅធ្វើការសិក្សាស្រាវជ្រាវពីមូលហេតុ និងខ្សែសង្វាក់នៃការបញ្ជាសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងមានគោលបំណងផ្តល់ឲ្យតុលាការក្នុងមានគោលបំណងដើម្បីស្វែងរកយុត្តិធម៌ទៀតផង ។

ចំពោះកម្រងសំណួរដែលត្រូវបានប្រើសម្រាប់ធ្វើការសម្ភាសន៍ នៅក្នុងគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ ដែល

មេធាវី ហ្សាស្តេ ប៉ោ ធ្លាប់បានសួរលោក វ៉ាន់ថាន់ ដារ៉ាពៅ ថា "ហេតុអ្វីបានជាកម្រងសំណួរនេះធ្វើឡើង ហាក់ដូចជាដើម្បីទទួលបានចម្លើយ ដែលអាចយកមកធ្វើការចោទប្រកាន់នៅក្រោមច្បាប់ស្តីពីការបង្កើតតុលាការខ្មែរក្រហម?" ។ បន្ថែមលើចម្លើយរបស់លោក ដារ៉ាពៅ លោក ឆាំង យុ លើកឡើងថា កម្រងសំណួរនេះត្រូវបានរៀបចំឡើងដោយអ្នកប្រឹក្សាយោបល់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោក ចន ឆរឆីអារី បន្ទាប់ពីបានពិភាក្សាជាមួយនឹងមន្ត្រីសិទ្ធិមនុស្សអន្តរជាតិផ្សេងៗ គឺដើម្បីធានាថាអ្នកផ្តល់បទសម្ភាសន៍ ធ្វើការឆ្លើយសំណួរទាំងឡាយដោយមិនមានការដាក់បន្ទុក ឬកំហុសលើខ្លួនឯង ។

### ១.២. សហមេធាវីជាតិការពារក្តី នួន ជា

សំណួរចាប់ផ្តើមដំបូងដោយមេធាវីសុនអរុណគឺពាក់ព័ន្ធនឹងឯកសារ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីប្រភពនានា ប្រភេទឯកសារ និងទម្រង់បែបបទដែលផ្ញើឯកសារ ដូចជាការចុះហត្ថលេខា ឬបោះត្រាលើឯកសារដោយកម្មាភិបាលខ្មែរក្រហម ដើម្បីបញ្ជាក់ថាឯកសារទាំងនោះពិតជាធ្វើឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបទៅនឹងសំណួរមេធាវី សុន អារុណ លោក ឆាំង យុ បានលើឡើងថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារទាំងច្បាប់ដើម និងច្បាប់ថតចម្លង ។ ច្បាប់ថតចម្លងត្រូវបានចាត់ទុកថាជាច្បាប់ដើមក្នុងករណីច្បាប់ដើមមិនមាននៅក្នុងប្រទេសកម្ពុជា ។ ចំពោះចម្លើយ សារភាពភាគច្រើនគឺជាច្បាប់ដើម ដែលចម្លើយសារភាពទាំងនេះត្រូវបានប្រមូលមកពីមន្ទីរស-២១ បានចំនួនបួនពាន់ចម្លើយសារភាព និងមកពីក្រសួងមហាផ្ទៃបានចំនួនប្រហែលមួយពាន់ចម្លើយសារភាព ។ ក្រៅពីចម្លើយសារភាព មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានទទួលឯកសារមួយចំនួនទៀត ដូចជា ឯកសារប្រវត្តិរូប សៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមជាដើម ។

ពាក់ព័ន្ធនឹងការសួរដេញដោលលើឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីមន្ទីរស-២១ មេធាវី សុន អារុណ ហាក់ដូចជាមានការភាន់ច្រឡំមួយចំនួន ។ ជាក់ស្តែងមេធាវីបានចោទសួរថា "នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កន្លែងនីមួយៗអាចមានលទ្ធភាពដឹងតែការងារណាដែលខ្លួនទទួលបន្ទុកតែប៉ុណ្ណោះ ចុះហេតុអ្វីបានជានៅមន្ទីរស-២១ មានឯកសាររបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ជាច្រើននៅទីនោះ?" ។ លោក ឆាំង យុ បានបញ្ជាក់ថា ឯកសាររបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានប្រមូលមកពីមន្ទីរស-២១ឡើយ ឯកសារទាំង នេះត្រូវបានប្រមូលមកពីសាស្ត្រាចារ្យ ប៉ែន យៀរនិន ដែលឯកសារទាំងនេះពីដំបូងត្រូវបានលោក ខៀវ កាញារិទ្ធ ផ្តល់ឲ្យសាស្ត្រាចារ្យ ប៉ែន យៀរនិន ។


សុន អារុណ មេធាវីជាតិការពារក្តី នួន ជា

ពាក់ព័ន្ធនឹងឯកសារដែលមានចុះហត្ថលេខា ឬបោះត្រាដោយកម្មាភិបាលខ្មែរក្រហម លោកធ្លាប់បានប្រទះឃើញឯកសារមួយចំនួនដូចជា "ក្រម" មានចុះហត្ថលេខានិងបោះត្រាដោយ ខៀវ សំផន និងមួយចំនួនទៀតត្រូវបានចុះហត្ថលេខាដោយ ឌុច, ខៀវ ឬមានបោះត្រាដោយក្រសួងតែម្តង ដូចជាក្រសួងឧស្សាហកម្ម ។ លោកឆាំងយុ បានកត់សម្គាល់ថាក្នុងការអានឯកសារប្រភេទនេះ លោកមានការចាប់អារម្មណ៍ខ្លាំង

ព្រោះឯកសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកម្រមានចុះហត្ថលេខានិងបោះត្រាដាក់ស្ដែង លោកបានប្រើពាក្យថា "ឯកសារនេះពេលដែលខ្ញុំរក ដូចដែលខ្ញុំប្រាប់ពីថ្ងៃដំបូងអ៊ីចឹង ដូចរើសគ្រាប់បាយពីភក់នៅក្នុងសម័យខ្មែរក្រហមមកទទួលទានអ៊ីចឹង ខ្ញុំឃ្លានណាស់ ខ្ញុំឃ្លានយុត្តិធម៌ ដូចខ្ញុំឃ្លានបាយ សម័យអាពតអ៊ីចឹង..." ។

សំណួរមួយគួរឲ្យចាប់អារម្មណ៍ដែលមេធាវី សុន អារុណ បានសួរលោក វ៉ាន់ថា ដាវ៉ាពៅ ម្ដងរួចហើយ ហើយត្រូវបានលើកយកមកសួរលោក ឆាំង យុ ម្ដងទៀតនោះគឺថា "តើលោកមិនគិតថាជារឿងខុសច្បាប់ទេ ឬដែលមជ្ឈមណ្ឌលរបស់លោកបានផ្ដល់ឯកសារមកឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?" ។ លោក ឆាំង យុ បានលើកឡើងថា "ខ្ញុំមិនដែលគិតថា ការផ្ដល់ឯកសារជូនតុលាការជារឿងខុសច្បាប់នោះទេ ព្រោះតុលាការជាអ្នកស្នើសុំផ្ទាល់ ហើយតុលាការខ្លួនឯងជាអ្នកអនុវត្តច្បាប់" ។ តែទោះបីជាយ៉ាងណា មជ្ឈមណ្ឌលឯកសារកម្ពុជា បានស្នើសុំជាច្រើនលើកច្រើនសារឲ្យធ្វើអនុស្សរណៈរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងតុលាកាកាត់ទោសមេដឹកនាំខ្មែរក្រហមពាក់ព័ន្ធទៅនឹងការស្នើសុំ និងផ្ដល់ឯកសារទាំងនេះ ប៉ុន្តែអនុស្សរណៈនេះមិនត្រូវបានតុលាការសម្រេចទទួលយកឡើយ ។

ទាក់ទងនឹងទស្សនាវដ្ដីទង់បដិវត្ត លោក ឆាំង យុ បានលើកឡើងថាមជ្ឈមណ្ឌលឯកសារកម្ពុជាមានទស្សនាវដ្ដីនេះជាច្រើនច្បាប់ ដែលរួមមានទាំងទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត និងព្រឹត្តប័ត្រផ្សេងៗទៀតដែលបានបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា ។ ឯកសារទាំងនេះមានទាំងច្បាប់ដើមនិងច្បាប់ថតចម្លង ដែលមួយចំនួនទទួលបានមកពីមន្ទីរស-២១ និងមួយចំនួនទៀតទទួលបានមកពីបណ្ដាប្រទេសផ្សេងៗដូចជាប្រទេសបារាំងជាដើម ។

ពាក់ព័ន្ធនឹងទស្សនាវដ្ដីទង់បដិវត្ត មេធាវី សុន អារុណ បានស្នើឲ្យលោក ឆាំង យុ បានលើកឡើងថា "ទស្សនាវដ្ដីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមាន គឺត្រូវបានបោះជាអក្សរពុម្ពតែកូនក្ដីរបស់ខ្លួនបានបញ្ជាក់ថាទស្សនាវដ្ដីទង់បដិវត្តត្រូវបានសរសេរដោយដៃនៅលើក្រដាសក្រមួន" ។ ភ្លាមៗ ប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានធ្វើការបំភ្លឺទៅលោកមេធាវី សុន អរុណ ថា "អ្វីដែលជនជាប់ចោទ នួន ជា ធ្លាប់បានបញ្ជាក់នោះគឺការធ្វើទស្សនាវដ្ដីទង់បដិវត្ត ត្រូវបានបែងចែកជាពីរដំណាក់កាលខុសគ្នា ។ ដំណាក់កាលតស៊ូបដិវត្តន៍ក្នុងអំឡុងទសវត្សរ៍ឆ្នាំ៦០ ទស្សនាវដ្ដីនេះត្រូវបានសរសេរដោយដៃលើក្រដាស់ក្រមួន ហើយត្រូវបានចែកផ្សាយដោយសម្ងាត់ ។ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាដណ្ដើមកាន់កាប់បានទីក្រុងភ្នំពេញ បន្ទាប់មកនេះត្រូវបានបោះផ្សាយ ឡើងវិញជាអក្សរពុម្ពចាប់ពីខែសីហា ឆ្នាំ១៩៧៥ ហើយមូលហេតុដែលមានការខកខានបោះផ្សាយ ក្នុងចន្លោះខែមេសា ដល់ខែសីហា គឺដោយសារមានការខ្វះខាតអ្នកមានសមត្ថភាពក្នុងការបោះផ្សាយជាអក្សរពុម្ព" ។ គួររំលឹកថា ប្រធានអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ប្រាប់មេធាវី សុន អរុណ ម្ដងរួចទៅហើយអំពីបញ្ហានេះ នៅពេលដែលមេធាវីសួរសំណួរនេះទៅកាន់លោក វ៉ាន់ថាន់ដាវ៉ាពៅ ។

ចំណែកឯក្រុមមេធាវីការពារក្ដីរបស់ជនជាប់ចោទ អៀង សារី មិនបានប្រើប្រាស់សិទ្ធិក្នុងការសួរដេញដោលលោកឆាំងយុទេ ។ លោកមេធាវី ខាណា វ៉ាស បានលើកឡើងថា "ទាក់ទងទៅនឹងសំណួរដែលបានតាំងទៅសាក្សីរូបនេះ ដូចជាមានស្ដាប់ពីសក្ខីកម្មរបស់លោកឆាំងយុ នោះគឺដូច្នេះគឺថាគាត់មកបង្ហាញនូវភស្តុតាងហើយជាការសម្រេចរបស់យើងទាក់ទងទៅនឹងការទទួលយកនូវភស្តុតាងនេះ គឺហើយចង្អុលបង្ហាញថាមានសេចក្ដីសន្និដ្ឋានថាឯកសារទាំងអស់ពិនិត្យមើលទៅហើយអាចនឹងយកចិត្តទុកដាក់បាន ឬក៏អាចជឿជាក់បានដោយសហចៅក្រមស៊ើបអង្កេតនោះគឺថាវាទំនងជាករណីមួយ ប៉ុន្តែភាគីនៅតែមានសិទ្ធិក្នុងការដេញដោលឯកសារមួយៗនោះ ទាក់ទងនឹងយថាភាព ឬក៏ភាពពាក់ព័ន្ធនិងភាពអាចជឿជាក់បាន ។ ដូចនេះ ចំពោះខ្ញុំ ខ្ញុំមិនចង់តាំងសំណួរអ្វីតទៀតទៅលើលោក ឆាំង យុ នោះទេ ។ គឺថាយើងមិនអាចនឹងបានតម្លៃអ្វីបន្ថែមទេក្នុងការតាំងសំណួរទេ ដោយសារថាគាត់បានឆ្លើយមួយចំនួនច្រើនហើយ..." ។

ប៉ុន្តែទោះបីជាយ៉ាងណា ពេលវេលាសម្រាប់មេធាវីការពារក្ដីរបស់ជនជាប់ អៀង សារី ត្រូវបានអង្គជម្រះប្រគល់ឲ្យមេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា ។

# សវនាការសំណុំរឿង០០២ ៖ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

## ថ្ងៃទី៣០-៣១ ខែមករា និងថ្ងៃទី៨-៩, ១៣-១៥ ខែកុម្ភៈ ឆ្នាំ២០១២

### I. ការសួរដេញដោលជនជាប់ចោទ នួន ជា

នៅថ្ងៃទី៣០-៣១ ខែមករា និងថ្ងៃទី៨-៩ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តសវនាការសួរដេញដោលជនជាប់ចោទ នួន ជា ។ សវនាការសួរដេញដោលនេះ ធ្វើឡើងបានតែពេលព្រឹកប៉ុណ្ណោះ ដោយសារបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា មិនអាចធ្វើការឆ្លើយតបពេញមួយថ្ងៃបាន ។

### ១) សហព្រះរាជអាជ្ញាសួរដេញដោលជនជាប់ចោទ នួន ជា

នៅវេលាព្រឹកម៉ោង៩ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ សវនាការបានចាប់ផ្តើមដោយលោកប្រធានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រគល់វេទិការជូនលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិឌេលលីសាក់ ដើម្បីបន្តសំណួររបស់ខ្លួន ។ លោក ឌេលលី សាក់ បានផ្តើមសួរជនជាប់ចោទទាក់ទងនឹងការលុបបំបាត់ចោលនូវកម្មសិទ្ធិឯកជន ។ ជនជាប់ចោទ នួន ជា បានឆ្លើយតបថាតាមការចងចាំរបស់ខ្លួននៅក្នុងឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ មិនមានការលុបបំបាត់ចោលនូវកម្មសិទ្ធិឯកជនទេ មានតែបញ្ហាដីប៉ុណ្ណោះ ដែលត្រូវប្រមូលចូលសហករណ៍ ឯទ្រព្យសម្បត្តិគឺស្ថិតនៅឯកជនទាំងអស់ ។

#### ១.ក) ការបង្កើតសហករណ៍

នៅថ្ងៃនេះដដែល ក្នុងបន្ទប់សវនាការជនជាប់ចោទ នួន ជា បានបំភ្លឺជូនអង្គជំនុំជម្រះថាការបង្កើត សហករណ៍ គឺតាមសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្រោមការស្តាប់មតិថ្នាក់ក្រោមដែលចាប់ពីកសិករក្រកសិករកណ្តាលឡើងមក ។ វាមានន័យថា បើមហាជនយល់ព្រមហើយ ទើបមានការចាត់តាំងសហករណ៍ ។ ដំបូង គឺមានសមាគមស្រូវ សមាគមជួយឧបត្ថម្ភគ្នាពេលឈឺថ្កាត់ និងសមាគមជួយសង្គ្រោះគ្នា ក្រោយមកសមាគមទាំងនេះបានពង្រីកឡើងទៅជា "សហករណ៍ថ្នាក់ទាប" ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានរំឭកជនជាប់ចោទថាមានឯកសារបក្សជាច្រើនបានយោងថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ថាជាថ្ងៃចាប់ផ្តើមមានសហករណ៍ ។ លោក ឌេល លីសាក់ បានសួរថា តើលោកមានចាំអំពីថ្ងៃបង្កើតសហករណ៍ដែរឬទេ? ជនជាប់ចោទបានឆ្លើយតបថា ខ្លួនមិនបងចាំទេ ។ ចំពោះសំណួរបន្ទាប់ ជនជាប់ចោទក៏បានបញ្ជាក់ដែរ អំពីការករកើតសហករណ៍គឺមិនមែនចាត់តាំងនៅទូទាំងប្រទេសភ្លាមៗនោះទេ ។ កន្លែងដែលមានសមាគមស្រូវ សមាគមជួយសង្គ្រោះគ្នាជាដើម ដែលមានលក្ខណៈរឹងមាំហើយ ទើបចាត់តាំងកន្លែងទាំងនោះជាសហករណ៍បណ្តើរៗ ។ ការចាត់តាំងសហករណ៍ មិនមែនធ្វើឡើងព្រមគ្នាទេ ហើយមិនអាចកំណត់ឆ្នាំបានឡើយ ដោយសារសភាពការណ៍មានលក្ខណៈខុសគ្នាតាមកន្លែង ។ ចំណែកការចាត់តាំងនេះ គឺធ្វើឡើងពីចុងកាត់មាត់ញកមកមុនមិនមែនចាត់ពីទីប្រជុំជនមកមុននោះទេ ។ ជនជាប់ចោទបានបញ្ជាក់ទៀតថា មូលហេតុនៃការចាត់តាំងសហករណ៍


នួន ជា

ដំបូង គឺបង្កើតសហករណ៍ថ្នាក់ទាបសិន ដើម្បីប្រមូលកម្លាំងប្រជាជន។ បើកាលណាប្រជាជនធ្វើការមិនជុំគ្នាវានាំឲ្យខាតកម្លាំងច្រើន។ ចំពោះចំណុចនេះ នួន ជា បានលើកជាឧទាហរណ៍ថា "ឧបមាថា៥០គ្រួសារនេះ បើដាំបាយវាត្រូវខាត កម្លាំង៥០ទៅ៦០នាក់ទៅហើយ ។ ប៉ុន្តែបើចាត់តាំងសហករណ៍រួមគ្នា ធ្វើការងាររួមគ្នា ហូបបាយទៅចំណាយមនុស្សតិច ហើយចំណេញឲ្យធ្វើពលកម្មច្រើន" ។

ជនជាប់ចោទបានជម្រាបជូន អង្គជំនុំជម្រះថា ខ្លួនមិនធ្វើការអប់រំចំពោះការចាត់តាំងសហករណ៍ទេ ប៉ុន្តែខ្លួនបានអប់រំតែទៅលើការចាត់តាំងសមាគមស្រូវ សមាគមផ្សេងៗទៀត ។ ឯសហករណ៍ខាងផ្នែករដ្ឋបាល គឺរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាអ្នកចាត់តាំង ជាអ្នករៀបចំ ។

## ១.ខ) ព្រឹត្តិការណ៍ឆ្នាំ១៩៧៤

លោកសហព្រះរាជអាជ្ញា បានសួរដេញដោលជនជាប់ចោទ នួន ជា អំពីការរំដោះឧត្តុង្គក្នុងឆ្នាំ១៩៧៤ ។ លោកតំណាងសហព្រះរាជអាជ្ញា បានអានសេចក្តីសម្រង់ដែលនិយាយពីការកម្ទេចខ្មាំងក្នុងពេលរំដោះនោះ ដែលមានខ្មាំងប្រហែលប្រាំពាន់នាក់ត្រូវបានកម្ទេច ក្នុងនោះមានមួយពាន់ប្រាំរយនាក់ត្រូវបានចាប់ខ្លួន។ ឆ្លើយតបនឹងសេចក្តីសម្រង់នេះ ជនជាប់ចោទ នួន ជា បានឆ្លើយថា ខ្លួនមិនបានដឹងអំពីបញ្ហានេះទេ ហើយថាសំណួរនេះគួរតែសួរជនជាប់ចោទ ខៀវ សំផន វិញ ។ ជនជាប់ចោទ នួន ជា បានបំភ្លឺជូនអង្គជំនុំជម្រះថា តាមការទទួលដំណឹងនៅក្នុងអំឡុងឆ្នាំ១៩៧៤ ជនជាតិវៀតណាម បានចូលមករស់នៅប្រទេសកម្ពុជាប្រហែលពីរម៉ឺនប្រាំពាន់នាក់ ។ ជនជាប់ចោទបានបន្តទៀតថា អ្នកខ្លះនិយាយថា វៀតណាមមានសគុណមកលើប្រទេសកម្ពុជា ប៉ុន្តែការពិតកម្ពុជាទេដែលមានគុណលើវៀតណាម ដោយបានផ្តល់កន្លែងឲ្យជ្រកកោន ពីព្រោះនៅពេលនោះអាមេរិកបានទម្លាក់គ្រាប់បែកខ្លាំងណាស់នៅវៀតណាម ។ ជនជាតិវៀតណាមនៅពេលនោះ គ្មានកន្លែងរស់នៅទេ ។ នៅឆ្នាំនោះ លោកស្រីប្រធានកងទ័ពរណសិរ្សវៀតណាមឈ្មោះ ង្វៀន វ៉ាន់ឌិញ បានមកជួប សោ ភឹម នៅភូមិភាគបូព៌ាដើម្បីសុំកន្លែងឲ្យកងទ័ពស្នាក់នៅទៀតផង ។

## ១.គ) កំណត់ត្រាផ្ទាល់ខ្លួនពេលចូលបដិវត្តន៍

បន្ទាប់ពីលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ចប់ការតាំងសំណួររបស់ខ្លួន លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេងប៊ុនឃាង បានបន្តសួរដេញដោលជនជាប់ចោទ នួន ជា ទាក់ទងនឹងកំណត់ត្រាផ្ទាល់ខ្លួននៅក្នុងពេលចូលបដិវត្តន៍ ។ យោងតាមកំណត់ត្រានេះ ជនជាប់ចោទ នួន ជា ធ្លាប់ប្តូរឈ្មោះជាច្រើនដងមានដូចជា ឈ្មោះ ឡុង "សែឡុង" គឺមរន ឈ្មោះ ដែន ឈ្មោះ ជា ក្រោយមក គឺ ឈ្មោះ នួន ជា ។ ពេលដែលខ្លួនរស់នៅប្រទេសថៃ នួន ជា ធ្លាប់ប្រើឈ្មោះ រុងឡឹត ឡៅឌី ។

តាមរយៈការឆ្លើយតបនឹងសំណួរនៅក្នុងកំណត់ត្រានោះ បានរៀបរាប់អំពីកិច្ចប្រជុំមួយចំនួនដែលខ្លួនបានចូលរួម ដូចជានៅដងស៊ីងជីនិត (ភូមិភាគកណ្តាល) នៅខេត្ត រតនៈគិរី ជាដើម ។ កិច្ចប្រជុំទាំងនោះ គឺសម្រេចចាត់តាំងកម្មាភិបាលសំខាន់ៗនៅតាមភូមិភាគនីមួយៗ ដោយសារមានការចាត់តាំងកម្មាភិបាលគណៈមជ្ឈិមឲ្យទៅកាន់តាមភូមិភាគ ។ ជនជាប់ចោទក៏បានកត់ត្រាអំពីព្រឹត្តិការណ៍នៅពេលមានរដ្ឋប្រហារសម្តេចព្រះនរោត្តមសីហនុក្នុងឆ្នាំ១៩៧០ ដែលកាលនោះលោក ង្វៀន វ៉ាន់លិញ បានជ្រើសរើសទ័ពមួយចំនួនទៅអប់រំនៅប្រទេសវៀតណាម ។ លោក ង្វៀន វ៉ាន់លិញ បានប្រឌិតចំនួនជាតួលេខក្លែងក្លាយដោយប្រើឈ្មោះ នួន ជា ដើម្បីស្នើសុំ តាម៉ុក ឲ្យចាត់កងទ័ពមួយវរសេនាធំទៅវៀតណាម ។ ជនជាប់ចោទ នួន ជា ក៏បានកត់ត្រាទៀតថា នៅពេលនោះ កងទ័ពបដិវត្តន៍កម្ពុជាឡើង ដល់ពីរសែននាក់ ដែល លន់ នល់ មិនអាចកាន់កាប់បាន ។ សហព្រះរាជអាជ្ញាសួរដេញដោលមួយបន្ទាត់ម្តងៗរហូតដល់បន្ទាត់ទី១៥ នៃកំណត់ហេតុរបស់ នួន ជា ។ នៅបន្ទាត់នេះបានសរសេរថា "បញ្ហាសន្និបាត តាមសមមិត្ត ហែម គាត់ឲ្យដឹងគឺថា គាត់ចាំ គឺឆ្នាំ១៩៦០,១៩៦៣, ១៩៧១, និង ១៩៧៦ ដើម្បីរៀបចំគណៈអចិន្ត្រៃយ៍ថ្មី ហើយចាត់តាំងឆ្នាំ១៩៧៨ ចាត់តាំង អចិន្ត្រៃយ៍ថ្មី" ។ នៅក្នុងសៀវភៅកំណត់ហេតុ នួន ជា បានកត់ត្រាទុកនូវព្រឹត្តិការណ៍ខ្លះៗដែលកើតឡើងតាំងពីពេលខ្លួនចាប់ផ្តើម ចូលបដិវត្តមកម្ល៉េះ ។

## ១.ឃ) ការបង្កើតមាគ៌ាបក្ស

នៅមុនពេលបញ្ចប់សំណួររបស់ខ្លួន លោកតំណាងសហ

ព្រះរាជអាជ្ញា សេង ប៊ុនឃៀង បានសាកសួរ នួន ជា អំពីការធ្វើ



សេង ប៊ុនឃៀង
តំណាងសហព្រះរាជអាជ្ញាជាតិ

ដំណើរទៅកាន់ប្រទេសវៀតណាម នៅមុនពេលមហាសន្និបាតបក្សលើកទីមួយឆ្នាំ១៩៦០ ដើម្បីពន្យល់បក្សវៀតណាមអំពីមាគ៌ានយោបាយ ដែលខ្លួន និង ប៉ុល ពត បានរៀបចំ។ នួន ជា បានឆ្លើយតបថា ខ្លួនពិតជាបានទៅពន្យល់ដល់បក្សវៀតណាមមែន ប៉ុន្តែខ្លួនមិនចងចាំពីពេលវេលានោះទេ។ ជនជាប់ចោទបានបន្តទៀតថា នៅពេលនោះវៀតណាមមិនបានពេញចិត្តនឹងមាគ៌ានយោបាយ យុទ្ធសាស្ត្រ យុទ្ធវិធី នោះទេ។មាគ៌ានោះមានលើកឡើងអំពីការរួមផ្សំការតស៊ូនយោបាយជាមួយអាវុធ និងខកខានលើកឡើងអំពីសហព័ន្ធឥណ្ឌូចិន។ វៀតណាមចង់ឲ្យមានការសាមគ្គីរវាងកម្ពុជា វៀតណាម និងឡាវ ប៉ុន្តែ កម្ពុជានាពេលនោះក្រោមការសម្រេចរបស់ ប៉ុល ពត ទូ សាមុត និងនួន ជា នៅតែមិនព្រមធ្វើតាមវៀតណាម។ នួន ជា បានបន្ថែមទៀតថា ទាំងរូបខ្លួនផ្ទាល់ ប៉ុល ពត និងទូ សាមុត យល់ថាបក្សកម្ពុជាមានឯករាជ្យ មានអធិបតេយ្យ និងមានបូរណភាពរបស់ខ្លួន។ ដូចនេះកម្ពុជាគួរតែពឹងខ្លួនឯង ម្ចាស់ការ និងឯករាជ្យ ចំពោះវាសនារបស់ខ្លួន។

**២) មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោល នួន ជា**

នៅវេលាព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់វេទិកាសួរដេញ ដោលជនជាប់ចោទ នួន ជា ជូនក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានផ្ទេរសិទ្ធឲ្យលោកស្រី មេធាវី ស៊ីន សុវ៉ៃន សាកសួរជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងឯកសារ ដែលខ្លួនបានប្រើប្រាស់ក្នុងការដើរអប់រំប្រជាពលរដ្ឋ។ នួន ជា បានរៀបរាប់ថានៅពេលនោះ ការតស៊ូ គឺស្ថិតនៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមានវៀតណាមជាអ្នកត្រួតត្រា។ ដូច្នេះឯកសារអប់រំ គឺបកប្រែពីឯកសាររបស់វៀតណាម ដែលអប់រំអំពីបញ្ហាសាមគ្គីជាតិខ្មែរ វៀតណាម និងឡាវ ដើម្បីរំដោះឥណ្ឌូចិន។ លោកស្រីមេធាវីបានសួរជនជាប់ចោទអំពីការចោទប្រកាន់របស់ក្រុមប្រជាជនទាក់ទងនឹងការទទួលប្រាក់ពីប្រទេសវៀតណាម។ ឆ្លើយតបនឹងសំណួរនេះជនជាប់ចោទនួន ជាបានបដិសេធថា បក្សកុម្មុយនីស្តកម្ពុជាមិនដែលបានទទួលប្រាក់ពីប្រទេសវៀតណាមទេ។ បន្ទាប់មក លោកមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បាណាបេ ណេគ្រី បាន



បាណាបេ ណេគ្រី មេធាវីអន្តរជាតិ
តំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្តកិច្ចការពីសហភាតារបស់ខ្លួន ដោយសួរសំណួរមួយចំនួនទៅជនជាប់ចោទ ទាក់ទងការមករស់នៅរបស់ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា។ ជនជាប់ចោទនួនជាបានជម្រាបថា «ឆ្ងៀនវ៉ាន់លិញហើយ និងខ្ញុំនេះទៅពិភាក្សាគ្នាដើម្បីសម្រួល ព្រោះខ្មែរហ្នឹងមិនចូលចិត្តវៀតណាមទេ តាំងពីសម័យណាមក។ ទើបនឹងមកក្រោយទេ ដែលបក្សកុម្មុយនីស្តកម្ពុជាសម្រួលថា យើងកុំហៅវៀតណាមថា ជាសត្រូវស្ទួរពូជ យើងត្រូវហៅថាមិត្តមានទំនាស់អានេះជាមតិរបស់ ប៉ុល ពត។ ឯទំនាស់នេះ ទំនាស់ធំដែរ មិនមែនទំនាស់តូចទេ ក៏ប៉ុន្តែបើហៅសត្រូវស្ទួរពូជវាដូចជា ហួសពេក»។ ប្តូរពីលោកមេធាវីអន្តរជាតិ បាណាបេ ណេគ្រី លោកស្រីមេធាវី

ជាតិ ស៊ីន សុវ៉ិន បានបន្តសំណួរជាថ្មីម្តងទៀត ។ លោកស្រីបានសាកសួរអំពីការផ្ទុះអាវុធប្រឆាំងនឹងសម្តេច នរោត្តម សីហនុ ក្នុងឆ្នាំ ១៩៦៨ ដោយមានការមិនពេញចិត្តពីប្រទេសចិន និងវៀតណាម ។ លោកស្រីបានលើកឡើងដោយយោងតាមការពិភាក្សាមួយរវាងជនជាប់ចោទ នួន ជា ជាមួយលោក ខឹម ងុន ។ ឆ្លើយតបនឹងសំណួរនេះ ជនជាប់ចោទ នួន ជា បានលើកឡើងថាៈ

« សូមជម្រាបលោកប្រធាន មានតែវៀតណាមទេដែលប្រឆាំង ពីព្រោះវៀតណាមនេះពឹង លន់នល់ ដើម្បីដឹកអាវុធពីកំពង់សោម កាត់តាមប្រទេសកម្ពុជា យកមកវ៉ៃនៅ ភូមិភាគខាងត្បូង ។ ឯចិនបើតាមខ្ញុំចាំ គេគ្មានមតិអីទេ គេថារឿងហ្នឹងជារឿងផ្ទៃក្នុងរបស់ខ្មែរ » ។

### ៣) ក្រុមមេធាវីការពារក្តីសួរដេញដោល នួន ជា

បន្ទាប់ពីការសាកសួរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលជនជាប់ចោទ នួន ជា ជូនក្រុមមេធាវីការពារក្តីទាំងបីក្រុម ។ ប៉ុន្តែ ចំពោះក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី និងក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានបង្ហាញពីជំហររបស់ខ្លួនក្នុងការមិនតាំងសំណួរទៅកាន់ជនជាប់ចាទ នួន ជា ឡើយ ។

សំណួរដំបូងរបស់លោកមេធាវីអន្តរជាតិ ម៉ៃឃើល ផេស្តមេន គឺសួរទៅកូនក្តីរបស់ខ្លួនអំពីប្រវត្តិខ្លះៗរបស់ជនជាប់ចោទ នួន ជា ចាប់តាំងពីវ័យកុមារមុនពេលចាកចេញទៅសិក្សានៅប្រទេសថៃ ។ ឆ្លើយតបនឹងសំណួរនេះ នួន ជា បានរៀបរាប់ដោយសង្ខេបថា ខ្លួនកើតចេញពីគ្រួសារអ្នកជំនួញ ប៉ុន្តែមុខរបរនេះមិនទទួលបានជោគជ័យទេ ថែមទាំងជំពាក់បំណុលគេទៀតផង ។ កាលពីក្មេង នួន ជា តែងតែឃើញមានការទារបំណុលពីក្នុងគ្រួសាររបស់ខ្លួន ព្រមទាំងមើលឃើញការជិះជាន់វាយដំអ្នកតូចតាច ។ នួន ជា បានបន្ថែមថា ខ្លួនធ្លាប់បានបួសជាលោកនេនរយៈពេលប្រាំពីរថ្ងៃ ហើយក៏បានសឹកទៅវិញ ។ ពេលដែលទៅសិក្សានៅប្រទេសថៃ នួន ជា បានស្នាក់នៅវត្ត និងបានឃើញមានការជិះជាន់បាញ់សម្លាប់ដូចស្ថានភាពនៅស្រុកខ្មែរដែរ ។ ដោយសារមើលឃើញពីបញ្ហានេះ នួន ជា បានបញ្ឈប់ការសិក្សាផ្នែកច្បាប់របស់ខ្លួននៅសាលាធម្មសាស្ត្រ និងការងារនៅក្រសួងការបរទេស ហើយក៏ត្រឡប់មកខ្មែរវិញ ។ មកដល់ប្រទេសកម្ពុជាដំបូង នួន ជា បានចូលរួមតស៊ូដោយធ្វើការងារខាងឃោសនាអប់រំ និងទាក់ទងជាមួយលោក ហេង សំរិន ខាងភូមិភាគបូព៌ា ដែលជាអ្នកនាំផ្លូវខ្លួនទៅ ជួបលោក ង្វៀន វ៉ាន់លិញ នៅប្រទេសវៀតណាម ។ នួន ជា បានបញ្ជាក់ថា

« ហេង សំរិន ហ្នឹងគាត់ក្រទេ រកតែក្របីឃ្វាលគ្មានផង មានតែខោខ្លីមួយហ្នឹង ក៏ប៉ុន្តែគាត់ល្អណាស់ គុណធម៌ សីលធម៌ អីគាត់ ហើយហ៊ាន ក្លាហាន តស៊ូប្តូរផ្តាច់ ស៊ូលំបាក វេទនា ។ នេះជីវិតរបស់គាត់ វាអ៊ីចឹង ។ ហើយដល់មកក្រោយមកទៀត ដល់នេះទៅគាត់បានធ្វើជាមេទ័ពក្រោយរំដោះហ្នឹង ។ ដូច្នោះ គឺថាជីវិតខ្ញុំហើយនឹង លោក ហេង សំរិន ជាប់គ្នាណាស់ ខ្ទាំងវាដេញអីៗរត់ទៅហើយ ។ គាត់ហ្នឹងរកស្រែគ្មានទេ លំបាកវេទនាណាស់ » ។

ជនជាប់ចោទ នួន ជា ក៏បានលើកឡើងដែរថាលោក ជា ស៊ីម ក៏ធ្លាប់ជិតស្និត និងរៀនជាមួយខ្លួនដែរ ប៉ុន្តែក្រោយមកខ្លួនមិនដឹងថាលោក ជា ស៊ីម ធ្វើអ្វីនៅឯណាទេ ។ នួន ជា បាននិយាយ



ម៉ៃឃើល ផេស្តមេន
មេធាវីអន្តរជាតិការពារក្តី នួន ជា

ថា «ហើយមួយទៀតហ្នឹងគឺ ជា ស៊ីម ។ ជា ស៊ីម គាត់ធ្លាប់រៀនជាមួយខ្ញុំដែរ ។ ជា ស៊ីម ហ្នឹងកាលហ្នឹងធ្វើគណៈស្រុកត្បូងឃ្មុំ គាត់ក៏ក្រដែរ អ្នកស្រែកណ្ដាល ប៉ុន្តែពេលខ្លះក៏ខ្វះខាត ទៅខ្ចីបុលគេទៅ ។ ហើយក្រោយមកទៀត ខ្ញុំក៏មិនដឹងគាត់ធ្វើអីទេ ក្រោយរំដោះហើយតាំងពីនោះក៏មិនដែលបានជួបគ្នា» ។

មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ជនជាប់ចោទបានលើកឡើងថា «សព្វថ្ងៃនេះ ខ្ញុំជម្រាបត្រង់ហើយចំពោះខ្លួនខ្ញុំគុកប្រវាក់អីមិនព្រួយទេ ប៉ុន្តែព្រួយអារឿងប្រទេសជាតិនេះ អនាគតវាយ៉ាងម៉េចសម្រាប់យុវជនជំនាន់ក្រោយនេះ» ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះបានបន្តសវនាការសួរដេញដោលជនជាប់ចោទ នួន ជា ដោយក្រុមមេធាវីការពារជនជាប់ចោទផ្ទាល់ ។ លោកមេធាវី ម៉ៃឃើល ផេស្គមេន បានព្យាយាម លើកឡើងពីបញ្ហាទាក់ទងនឹងសេចក្ដីសម្រេច ដែលអង្គជំនុំជម្រះបានធ្វើកន្លងមកហើយ ដែលមិនពាក់ព័ន្ធនឹងកម្មវត្ថុសវនាការ ។ លោកប្រធានអង្គជំនុំជម្រះបានរំឭកដល់លោកមេធាវីថា អង្គជំនុំជម្រះមិនស្ដាប់បញ្ហា អ្វីដែលអង្គជំនុំជម្រះសម្រេចរួចហើយទេ ។ ការឆ្លើយឆ្លងទៅវិញទៅមករបៀបនេះចំណាយពេលប្រហែល១៥នាទី ទើបលោកប្រធានអង្គជំនុំជម្រះបំភ្លឺថា តាមរយៈកំណត់សម្គាល់របស់ខ្លួនអង្គជំនុំជម្រះសង្កេតឃើញ ថាលោកមេធាវីមានឥរិយាបថមិនគោរពដល់អង្គជំនុំជម្រះនិងមិនប្រើប្រាស់ពេលវេលានៅក្នុងការសួរកូនក្ដីរបស់ខ្លួនទេ ។ ភ្លាមៗលោកសហចៅក្រមអន្តរជាតិ ហ្សង់ម៉ាក ឡាវែញ បានធ្វើការតាំងសំណួរទៅជនជាប់ចោទ នួន ជា តែម្ដង ។ សំណួរដំបូងគឺទាក់ទងនឹងរូបិយប័ណ្ណ ។ ជនជាប់ចោទ នួន ជា បានឆ្លើយតបថា ក្រដាសប្រាក់បានបោះរួចហើយ ដើម្បីជំនួសក្រដាសប្រាក់នៃរបប លន់ ណល់ ក៏ប៉ុន្តែមិនមានពេលចាយវាទេ ដោយសារកាលណោះសភាពការណ៍នៅមានលក្ខណៈស្មុគស្មាញ ។ម្យ៉ាងទៀតគឺពុំមានការចាយប្រាក់កាសក្នុងការទិញដូរអាវុធយុទ្ធភ័ណ្ឌទេ គឺប្រទេសចិនជាអ្នកផ្ដល់ជូន ។ ចំណែកឯសម្ភារៈប្រើប្រាស់ គឺសហករណ៍ ជាអ្នកទិញពីប្រទេសថៃ ហើយយកមកដោះដូរជាមួយសមាជិក សហករណ៍ ដែលជាអ្នកបង្កបង្កើនផល ។ ជនជាប់ចោទបានលើកឡើងដែរថា បញ្ហានេះអនុវត្តតាមសភាពការណ៍នៅកន្លែងនីមួយៗ ។ ប្រសិនបើកន្លែង ណានៅជិតព្រំដែនថៃ កន្លែងនោះប្រើលុយបាតថៃ ដើម្បីដោះដូរនៅពេលនោះ ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ មុននឹងសម្រាកពិសារអាហារថ្ងៃត្រង់ លោកមេធាវីការពារក្ដីជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះ ដើម្បីអនុញ្ញាតបញ្ចប់សំណួររបស់ខ្លួន ក្នុងរយៈពេលប្រហែលកន្លះម៉ោងទៀត ។ លោកមេធាវីបានសួររំឭកឡើងវិញ ដើម្បីឲ្យជនជាប់ចោទបញ្ជាក់ឲ្យបានច្បាស់អំពីសំណួរដែលខ្លួនបានសួរកាលពីម្សិលមិញ ។ ចំពោះទំនាក់ទំនងរវាងជនជាប់ចោទ នួន ជា នឹងលោក ហេង សំរិន ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា លោក ហេង សំរិនគឺជាអតីតនីរសារបស់ សោ ភឹម ដែលកាលនោះ សោ ភឹម បានប្រគល់ភារកិច្ចឲ្យលោក ហេង សំរិន និងមនុស្សបី-បួននាក់ទៀតការពារ នួន ជា ធ្វើដំណើរទៅវៀតណាមដើម្បីជួបជាមួយលោក ង្វៀន វ៉ាន់លិញ ។ នួន ជា ជួបលោក ហេង សំរិន ក្នុងអំឡុងឆ្នាំប្រហែល១៩៥៩ ។ ជនជាប់ចោទបាននិយាយថា លោក ហេង សំរិន បានជូនដំណើរខ្លួនទៅប្រទេសវៀតណាមចុងក្រោយក្នុងអំឡុងឆ្នាំ១៩៧៥ ដែលពេលនោះលោក ហេង សំរិន បានធ្វើជាមេបញ្ជាការ កងទ័ពហើយ ។

## II. ការដាក់ឯកសារភស្តុតាងពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

បន្ទាប់ពីសវនាការសួរដេញដោលជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា បានប្រព្រឹត្តទៅចប់សព្វគ្រប់ ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានអនុញ្ញាតឲ្យលោក ចៅក្រម ហ្សង់ ម៉ាក ឡាវែញ និងលោកចៅក្រម យ៉ា សុខន ដាក់ឯកសារភស្តុតាងពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា នៅចំពោះមុខអង្គជំនុំជម្រះនិងភាគីផ្សេងៗទៀត ។ នៅក្នុងនីតិវិធីនេះ ចៅក្រមដែលបានដាក់ឯកសារត្រូវបានអនុញ្ញាតឲ្យអានខ្លឹមសារសំខាន់ៗនៃឯកសារដែលខ្លួនបានដាក់នោះនៅចំពោះមុខអង្គជំនុំជម្រះ ។ ភាគីផ្សេងៗទៀតរួមមាន តំណាងសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដីឲ្យជនជាប់ចោទ ក៏ត្រូវបានប្រធានអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើដូច្នេះដែរ ប្រសិនបើភាគីមានបំណងដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ។ បន្ថែមពីលើនេះទៀត ជនជាប់ចោទ

ទាំងបីរូប ក៏ត្រូវបានអនុញ្ញាតឲ្យធ្វើការជំទាស់ ឬកត់សម្គាល់លើខ្លឹមសារនៃឯកសារដែលចៅក្រម ឬភាគីណាមួយបានលើកឡើងដើម្បីជាប្រយោជន៍ក្នុងការការពារខ្លួនថែមទៀតផង ។

**១) ការបង្ហាញឯកសារភស្តុតាងដោយចៅក្រមជំនុំជម្រះ**

**ក) ការដាក់ឯកសាររបស់លោកចៅក្រមអន្តរជាតិ ហ្សង់ ម៉ាក ឡាវើញ**



ហ្សង់ ម៉ាកឡាវើញ
ចៅក្រមអន្តរជាតិ

លោកចៅក្រម ហ្សង់ ម៉ាក ឡាវើញ បានដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹងប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា ។ឯកសារទាំងនោះត្រូវបានលោកចៅក្រមអានខ្លឹមសារសំខាន់ៗដោយសង្ខេប និងអនុញ្ញាតឲ្យជនជាប់ចោទធ្វើការកត់សម្គាល់លើខ្លឹមសារទាំងនោះ ដើម្បីបង្ហាញមតិយល់ស្រប ឬជំទាស់ ។

ឯកសារទី១ ដែលលោកចៅក្រម ហ្សង់ ម៉ាកឡាវើញបានលើកឡើងគឺមានចំណងជើងថា «ជោគជ័យដ៏មហាធំធេងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដ៏ភ្លឺស្វាង» ។ ឯកសារនេះគឺជាសុន្ទរកថារបស់ ប៉ុល ពត ថ្លែងនៅក្នុងកិច្ចប្រជុំអបអរសាទរខួបលើកទី១៧នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងឱកាសនៃការប្រកាសបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការ ។ សុន្ទរកថានេះ និយាយពីទម្រង់ផ្សេងៗគ្នានៃការតស៊ូបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុម័តនៅក្នុងមហាសន្និបាតរបស់បក្សក្នុងទសវត្សរ៍៦០ ។ ខ្លឹមសារសំខាន់ៗដែលបក្សបានអនុម័តនៅក្នុងមហាសន្និបាតនោះត្រូវបានលោកចៅក្រម ឡាវើញ ដកស្រង់ចេញពីសុន្ទរកថានេះគឺថា «មហាសន្និបាតលើកទីមួយរបស់បក្ស គឺបានកំណត់អំពីទម្រង់នៃការតស៊ូបដិវត្តន៍ គឺទីមួយ) ការប្រើហិង្សាបដិវត្តន៍នយោបាយ និងហិង្សា បដិវត្តន៍ប្រដាប់អាវុធ ទីពីរ) ទម្រង់នៃការតស៊ូស្របច្បាប់ ពាក់កណ្តាលស្របច្បាប់ និងខុសច្បាប់ និងទីបី) ទម្រង់នៃការតស៊ូដោយចំហ ពាក់កណ្តាលចំហ និងលួចលាក់ ឬសម្ងាត់ ។ ដូច្នេះគឺបក្សបានយកចិត្តទុកដាក់ ក្នុងការបែងចែកការងារក្នុងចំណោមកម្មាភិបាល ថាតើសមមិត្តណាខ្លះដែលត្រូវបានផ្តល់ជូននូវការងារដោយចំហ? ហើយអ្នកខ្លះត្រូវមាននៅក្នុងឋានៈជាតំណាងរាស្ត្រ អ្នកខ្លះជាសមាជិករដ្ឋាភិបាលនៅក្រោមរបបចាស់ អ្នកខ្លះជាមន្ត្រីរដ្ឋការ ហើយអ្នកខ្លះធ្វើការនៅអង្គការមហាជន គឺការងារសារព័ត៌មាន ។ ដូច្នេះ ទាំងនេះគឺជាទម្រង់ផ្សេងៗគ្នាដែលត្រូវបានប្រើប្រាស់ក្នុងការធ្វើឲ្យមានការរំដើបរំជួលដល់មហាជន..» ។

ជាការឆ្លើយតប ជនជាប់ចោទ នួន ជា បានលើកឡើងថាបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ បក្សមានមនុស្សពីរក្រុមសម្រាប់ធ្វើការ គឺមួយក្រុមសម្រាប់ធ្វើការដោយចំហ ឬពាក់កណ្តាល ចំហ តាមរយៈការសរសេរ និងចេញកាសែតផ្សេងៗ ដោយមានការបញ្ចូលខ្លឹមសារបដិវត្តន៍នៅក្នុងនោះ និងមួយក្រុមទៀតគឺធ្វើការដោយសម្ងាត់ ដើម្បីធ្វើការងារកសាងបក្សជាសម្ងាត់ ។

ឯកសារទី២ គឺជាទស្សនាវដ្តីទង់បដិវត្តលេខពិសេស ចេញខែមករា ឆ្នាំ១៩៧៧ ចុះផ្សាយពីសុន្ទរកថា របស់តំណាងបក្សដែលបានថ្លែងនៅក្នុងពិធីប្រារព្ធខួបលើកទី៩នៃការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ។ ឯកសារនេះនិយាយពាក់ព័ន្ធនឹងការកៀរប្រមូលប្រជាជនពីតំបន់ប្រយុទ្ធ ឲ្យទៅតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។នៅក្នុងឯកសារនេះបានបញ្ជាក់ថា «មាគ៌ារបស់បក្សដែលប្រមូលប្រជាជនយកមកពីខ្មាំងគឺមានសារៈសំខាន់ណាស់ ដែលការធ្វើបែបនេះមិនដែលមានឡើយនៅក្នុងពិភពលោក ។ ប្រសិនបើខ្មាំងកាន់កាប់ប្រជាជន នោះពួកគេមានយោធាហើយពួកគេក៏មានសេដ្ឋកិច្ចផងដែរ ។ ផ្ទុយទៅវិញបើពួកគេគ្មានប្រជាជននៅក្នុងដៃនោះទេពួកគេគ្មានយោធា ហើយក៏មិនមានកម្លាំងសេដ្ឋកិច្ចដែរ ។...ប្រសិនបើប្រជាជននៅកន្លែងទីតាំងរបស់

យើងនោះ គឺយើងនឹងប្រើប្រាស់ពួកគាត់ ហើយប្រសិនបើប្រជាជននៅក្នុងដៃរបស់ខ្មាំង នោះពួកគេនឹងបម្រើខ្មាំង..." ។ ឆ្លើយតបនឹងខ្លឹមសារដែលបានលើកឡើងនេះ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា "គោលការណ៍សង្គ្រាម ប្រជាជននៅខាងណា ខាងនោះឈ្នះ ដូចនេះយើងត្រូវពង្រឹង (ធ្វើឲ្យអស់) ប្រជាជនពីខ្មាំងព្រោះប្រជាជននៅខាងយើងឧបត្ថម្ភយើង ប្រជាជននៅខាងខ្មាំងឧបត្ថម្ភខ្មាំង..." ។

ឯកសារទី៣ គឺជាសុន្ទរកថាដែលបានថ្លែងដោយ ខៀវ សំផន ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី នៅប្រទេសកូរ៉េខាងជើងនៅក្នុងដំណើរទស្សនៈកិច្ចរបស់រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិ ។ សុន្ទរកថានេះត្រូវបានថ្លែងនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៤ ដោយ ខៀវ សំផន ថា "នៅថ្ងៃទី១៨ ខែមីនា គឺកងកំលាំងរបស់យើងបានរំដោះទីក្រុងមួយទៀត គឺទីក្រុងឧដុង្គ ដោយបានកម្ទេចទាហានអាយ៉ងទាំងអស់ដែលមាននៅទីនោះ ហើយកងកម្លាំងជំនួយប្រហែលជា៥ពាន់នាក់ទៀតត្រូវបានកម្ទេច និងចាប់ខ្លួន..." ។ បន្ទាប់ពីអានសេចក្តីដកស្រង់នេះ លោក ចៅក្រម ឡាវីញ បានទុកឱកាសឲ្យជនជាប់ចោទ ខៀវ សំផន ដើម្បីធ្វើការជំទាស់ ឬកត់សម្គាល់លើខ្លឹមសារដែលបានលើកឡើងនេះ ។ ជាការឆ្លើយតប ជនជាប់ ចោទ ខៀវ សំផន បានលើកឡើងថា "ខ្ញុំសូមរក្សាសិទ្ធិនៅស្ងៀមស្ងាត់នៅពេលនេះ ហើយខ្ញុំនឹងមានមតិនៅពេលណាដែលមានភស្តុតាងគ្រប់គ្រាន់អាចធ្វើការចោទប្រកាន់មកលើខ្ញុំ..." ។

ឯកសារទី៤ គឺជាសារអបអរសាទរចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ ដែលបានធ្វើឡើងដោយ ខៀវ សំផន បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ។សារនេះត្រូវបានថ្លែងតាមវិទ្យុដោយមានខ្លឹមសារថា "អ៊ុល គឺសំដៅលើការជោគជ័យរបស់កងទ័ពបដិវត្តន៍កម្ពុជា ក្រោមមាគ៌ាដ៏ភ្លឺស្វាងរបស់ប្រជាជនយើងគឺកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា នៅក្រោមការដឹកនាំសង្គ្រាមប្រជាជនដ៏មហាខ្លាំងក្លា និងពុះជញ្ជ្រោលដែលវាយប្រហារសត្រូវគ្រប់វិស័យទាំងអស់រួមមាន ៖ វិស័យយោធា នយោបាយ សេដ្ឋកិច្ច និងតាមទស្សនវិស័យនៃការជម្លៀសប្រជាជនចេញពីមូលដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នរបស់សត្រូវ ។ យើងធ្វើឲ្យសត្រូវចាញ់ជាបន្តបន្ទាប់ និងឲ្យសត្រូវបាត់បង់កម្លាំងយោធា នយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងស្បៀង គឺថារហូតទាល់តែអស់រលីងតែម្តង..." ។ លោកចៅក្រមពុំ ទទួលបានការឆ្លើយតប ឬកត់សម្គាល់ពីជនជាប់ចោទណាម្នាក់ចំពោះខ្លឹមសារនេះឡើយ ។

ឯកសារទី៥ មានចំណងជើងថា "អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ" ដែលនិយាយទាក់ទងនឹងកម្មវិធីនយោបាយ និងសមាសភាពនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ឯកសារនេះគឺជាកម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា(ហ៊ុង) ហើយត្រូវបានរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា(ហ្គ្រុង) ធ្វើការផ្សព្វផ្សាយក្នុងឱកាសដំណើរទស្សនកិច្ចនៅទីក្រុងញូវយ៉ក ដើម្បីបង្ហាញថាខ្លួនជាអ្នកតំណាងស្របច្បាប់របស់ប្រទេសកម្ពុជា ក្នុងគោលបំណងទទួលបានអាសនៈនៅក្នុងអង្គការសហប្រជាជាតិ ។ ខ្លឹមសារដែលត្រូវបានលោកចៅក្រម ឡាវីញ ស្រង់ចេញពីឯកសារនេះរួមមាន "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដើរតាមនយោបាយដែលមានបង្ហាញនៅក្នុងកម្មវិធីនយោបាយរបស់ "ហ៊ុង" ដែលមានការធានានូវប្រជាធិបតេយ្យការបញ្ចេញមតិ និងជំនឿ ការគោរពសិទ្ធិ សិទ្ធិលើកម្មសិទ្ធិ សិទ្ធិលើកម្មសិទ្ធិឯកជន ហើយនយោបាយក្រៅប្រទេសគឺអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ ។រាជរដ្ឋាភិបាលនេះគឺថាមានកូនស្រីកូនប្រុសរបស់កម្ពុជាទទួលស្គាល់ថាមានស្មារតីស្នេហាជាតិ និងមានភក្តីចំពោះបុព្វហេតុនៃប្រជាជនហើយភាគច្រើន គឺមានចំណេះដឹងរឹងមាំនិងមានបទពិសោធន៍ទូលំទូលាយក្នុងការគ្រប់គ្រងកិច្ចការរដ្ឋ ដែលមុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពួកគាត់មានតំណែងខ្ពស់ៗ ដូចជាប្រធានគណៈរដ្ឋមន្ត្រីសភាជាតិ ឯកអគ្គរដ្ឋទូត... ។ រដ្ឋមន្ត្រី និងអនុរដ្ឋមន្ត្រី១១នាក់ ដែលជាអ្នកកាន់ក្រសួងសំខាន់ៗដូចជា ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាននិងឃោសនាការគឺពួកគាត់ទាំងអស់នេះគឺថាបំពេញតួនាទីនៅក្នុងប្រទេសកម្ពុជា ។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាធ្វើការត្រួតត្រាទៅលើទឹកដីជាតិ៩០ភាគរយ ដែលជាតំបន់រំដោះ និងដឹកនាំការតស៊ូរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ដែលត្រូវបានត្រួតត្រាជាបណ្តោះអាសន្នដោយក្រុមក្បត់នៅទីក្រុងភ្នំពេញ ។ នៅទីនេះ គឺថាពួកគេមានអំណាចពិតប្រាកដ

តាមរយៈការរៀបចំរដ្ឋបាល ដែលត្រូវបានរៀបចំរចនាសម្ព័ន្ធយ៉ាងត្រឹមត្រូវនៅក្នុងគ្រប់ថ្នាក់ទាំងអស់ដូចជា ថ្នាក់ភូមិ ឃុំ ស្រុក និងថ្នាក់ខេត្ត...» ។ លោកចៅក្រម ហ្សង់ម៉ាកឡាវ៉ែញបង្ហាញឈ្មោះបុគ្គលដែលជាសមាសភាពរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមួយចំនួនដូចជា លោក ប៉ែន នុត, ខៀវ សំផន, សារិន ឆាក, ហ៊ូយន់, ហ៊ូ នឹម, ចៅ សេង, ចាន់យូរ៉ាន់, ដួង សំអុល, ហួត សម្បត្តិ, ជា សាន, គាត ឈុន, ជួន ប្រសិទ្ធិ, ព្រះអង្គម្ចាស់នរោត្តម ភូរិស្សរា, គង់ សុផល...ដើម្បីសួរបញ្ជាក់ជនជាប់ចោទ នួន ជា តែបុគ្គលមួយចំនួនខាងលើនេះ មួយចំនួន នួន ជា បានស្គាល់ និងមួយចំនួនទៀតមិនបានស្គាល់ឡើយ ។

ឯកសារទី៦ គឺជាសេចក្តីថ្លែងការណ៍ដែលត្រូវបានអនុម័តជាឯកច្ឆន្ទដោយអ្នកចូលរួមក្នុងមហាសន្និបាតក្នុងអំឡុងថ្ងៃទី២៤-២៥ ខែកុម្ភៈឆ្នាំ១៩៧៥ ក្រោមអធិបតីភាពរបស់ ខៀវសំផន ។ សេចក្តី ថ្លែងការណ៍នេះត្រូវបាន សារិន ឆាក ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ផ្តល់ជូន និងចែកចាយដល់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ។ ខាងក្រោមនេះគឺជាខ្លឹមសារសំខាន់ៗ ៨ចំណុចពាក់ព័ន្ធនឹងមាគ៌ានយោបាយក្នុងប្រទេស និងក្រៅប្រទេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលបានកំណត់នៅក្នុងសេចក្តីថ្លែងការនេះ ៖

ចំណុចទី១) មហាជនក្បត់ទាំងប្រាំពីរនាក់ដូចជាលន់នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្តែន ហ្វែកណង់ដេស ត្រូវកាត់ទោសប្រហារជីវិត ។

ចំណុចទី២) បញ្ឈប់ចំពោះការជ្រៀតជ្រែក និងឈ្លានពានដោយផ្ទាល់ ឬដោយប្រយោលរបស់ចក្រពត្តិអាមេរិកប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ និងចាកចេញជាបន្ទាន់នូវទីប្រឹក្សាយោធារបស់អាមេរិក ។

ចំណុចទី៣) ពាក់ព័ន្ធទៅនឹងនយោបាយផ្ទៃក្នុងនយោបាយក្នុងប្រទេស ដែលបានបញ្ជាក់ថាគឺមានការធ្វើនយោបាយរួបរួមជាតិកម្ពុជាទាំងអស់ដោយមិនមានបែងចែកវណ្ណៈសង្គម មិនគិតអំពីនិន្នាការនយោបាយ ជំនឿ សាសនា ឬអតីតកាលរបស់បុគ្គលម្នាក់ៗឡើយ លើកលែងតែពួកជនក្បត់ទាំង៧នាក់ប៉ុណ្ណោះ ។ ចំពោះនយោបាយក្រៅប្រទេស គឺប្រកាន់នយោបាយអព្យាក្រឹត និងឯករាជ្យភាពដែលជាគោលនយោបាយ ដែលត្រូវអនុវត្ត ហើយមិនទទួលយកមូលដ្ឋានយោធាឈ្លានពានទាំងអស់នៅក្នុងទឹកដីកម្ពុជា ។

ចំណុចទី៤) អំពាវនាវឲ្យមានការងើបឡើងបះបោរសម្រាប់ប្រជាជនទាំងអស់នៅទីក្រុងភ្នំពេញ ដើម្បីឲ្យផ្តួលរំលំជនក្បត់ និងអំពើហិង្សាប្រឆាំងជនក្បត់ ។

ចំណុចទី៥) អំពាវនាវឲ្យបោះបង់ចោលប្រាក់រៀលដែលចេញឲ្យចាយដោយពួកក្បត់ គឺរបបលន់នល់ ព្រោះប្រាក់រៀលនោះគឺគ្មានតម្លៃទៀតឡើយ ដោយសារប្រាក់នេះត្រូវបានជំនួសដោយប្រាក់រៀលដែលបោះដោយរណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួម ជាតិ ។

ចំណុចទី៦) អំពាវនាវទៅដល់ស្ថានទូតនិងទីភ្នាក់ងារទាំងអស់ដែលប្រចាំនៅក្នុងរបបពួកក្បត់ដើម្បីឲ្យដកបុគ្គលិក និងគ្រួសាររបស់ពួកគេចេញជាបន្ទាន់ពីទីក្រុងភ្នំពេញ និងតំបន់ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មាំងជាបណ្តោះអាសន្ន ដើម្បីចៀសវាងគ្រោះ ថ្នាក់ដែលអាចកើតមានដាយថាហេតុ ។

ចំណុចទី៧) បង្ហាញនូវការដឹងគុណយ៉ាងជ្រាលជ្រៅរបស់រណសិរ្សរួបរួមជាតិ កម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទៅដល់ប្រជាជននៅលើពិភពលោកដែលបានផ្តល់នូវការគាំទ្រដល់កម្ពុជាប្រជាធិបតេយ្យក្នុងការតស៊ូរបស់ជាតិ ។

ចំណុចទី៨) អំពាវនាវទៅដល់កងទ័ពប្រជាជនរំដោះជាតិកម្ពុជាទាំងបីផ្នែកឲ្យបង្កើននូវការប្រយុទ្ធតស៊ូ វាយសម្រុកប្រឆាំងនឹងខ្មាំងឲ្យបានខ្លាំងក្លា ដើម្បីកម្ទេចខ្មាំង និងរំដោះប្រជាជន និងប្រជាជាតិឲ្យរួចផុតពីខ្មាំងសត្រូវ ។

លោកចៅក្រម ហ្សង់ ម៉ាក ឡាវ៉ែញ ទុកឱកាសឲ្យជនជាប់ចោទ ខៀវ សំផន ដើម្បីឆ្លើយតបនឹង ខ្លឹមសារនៃឯកសារនេះ ប៉ុន្តែជនជាប់ចោទមិនបានធ្វើអត្ថាធិប្បាយអ្វីទាំងអស់ ។

### ១) ការដាក់ឯកសាររបស់លោកចៅក្រមជាតិ យ៉ា សុខន

បន្ទាប់ពីលោកចៅក្រម ហ្សង់ ម៉ាក ឡាវ៉ែញ បានដាក់ឯកសារមួយចំនួនពាក់ព័ន្ធនឹងបរិបទនៃប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជាចប់សព្វគ្រប់ លោកប្រធានអង្គជំនុំជម្រះនិលណុនបានផ្តល់ភារៈនេះជូនលោក ចៅក្រម យ៉ា សុខន ដើម្បីដាក់ឯកសារភ័ស្តុតាង

មួយចំនួនទៀតនៅចំពោះមុខភាគី ។ លោកចៅក្រម យ៉ា សុខន បានបង្ហាញឯកសារមួយចំនួន ដោយលោកបានអានខ្លឹមសារជាសង្ខេបៗ ដែលមាននៅក្នុងឯកសារទាំងនោះ ដើម្បីទុកឱកាសឲ្យជនជាប់ចោទទាំងបីនាក់ធ្វើការជំទាស់ ឬកត់សម្គាល់លើខ្លឹមសារទាំងនោះ ។

ឯកសារទី១ ដែលលោកចៅក្រមបានលើកយកមកបង្ហាញ គឺពាក់ព័ន្ធនឹងជីវប្រវត្តិរបស់ជនជាប់ចោទ អៀង សារី ។ ខាងក្រោមនេះ គឺជាខ្លឹមសារសង្ខេបដែលត្រូវបានលោកចៅក្រមដកស្រង់ចេញពីជីវប្រវត្តិ ដែលសរសេរដោយជនជាប់ចោទ អៀង សារី ផ្ទាល់ ៖

«កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៣០ នៅបារាយ ខេត្តព្រៃវែង ប្រទេសកម្ពុជា ។ សិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិភ្នំពេញ ។ បន្ទាប់មកនៅប្រទេសបារាំង សាលាបណ្តុះបណ្តាលជាន់ខ្ពស់ ។ ឆ្នាំ១៩៥១ បានចូលរួមក្នុងមហោស្រពយុវជនអន្តរជាតិនៅទីក្រុងប៊ែរឡាំងខាងកើត ។ ឆ្នាំ១៩៥៣ ត្រូវបានកាត់ផ្តាច់អាហារូបករណ៍សិក្សានៅប្រទេសបារាំង ដោយមូលហេតុធ្វើសកម្មភាពនយោបាយ ។ ពីឆ្នាំ១៩៥៣-១៩៥៦ ប្រធានសម្ព័ន្ធទូទៅនិស្សិតខ្មែរប្រចាំនៅប្រទេសបារាំង ។ ឆ្នាំ១៩៥៨ សាស្ត្រាចារ្យនៅវិទ្យាល័យព្រះស៊ីសុវត្ថិភ្នំពេញ ។ ត្រូវបានចាត់ទុកជាកម្មាភិបាលកុម្មុយនីស្តទទួលបន្ទុកធ្វើសកម្មភាពក្នុងមជ្ឈដ្ឋានគ្រូបង្រៀនខ្មែរមានទំនាក់ទំនងស្និតរមួតជាមួយស្ថានទូតសូវៀត នៅភ្នំពេញ ។ ខែកក្កដា ឆ្នាំ១៩៦៣ បានចាកចេញពីភ្នំពេញចូលព្រៃម៉ាគីខ្មែរក្រហម ។ ឆ្នាំ១៩៧១ ដល់ ១៩៧៣ តំណាងចលនាតស៊ូផ្ទៃក្នុងប្រទេស ប្រចាំរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅប៉េកាំង ។ ចាប់តាំងពីចុងឆ្នាំ១៩៧៣ ទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំតំបន់រំដោះ ។ ធ្វើដំណើរជាញឹកញាប់ទៅកាន់ប្រទេសចិន និងវៀតណាមខាងជើង» ។

លោកចៅក្រម យ៉ា សុខន បានស្នើឲ្យជនជាប់ចោទ អៀង សារី ធ្វើអត្ថាធិប្បាយបញ្ជាក់បន្ថែមលើជីវប្រវត្តិនេះ ។ ឆ្លើយតបនឹងសំណើនេះ លោកមេធាវីអន្តរជាតិ ម៉ៃឃើល ខាណាវ៉ាស



ម៉ៃឃើល ខាណាវ៉ាស
មេធាវីការពារក្តី អៀង សារី

បានលើកឡើងថា «ក្នុងរយៈពេលបួនឆ្នាំកន្លងមក នៅក្នុងសាលាក្តីអន្តរជាតិដែលនឹងត្រូវអនុវត្តនូវស្តង់ដាអន្តរជាតិ ខ្ញុំមិនដឹងថាមានតុលាការអន្តរជាតិ ឬតុលាការជាតិណាមួយដែលទទួលបានមូលនិធិពីអង្គការសហប្រជាជាតិដែលទទួច ហើយតាំងសំណួរទៅជនជាប់ចោទ ទោះបីជាជនជាប់ចោទនោះបានចង្អុលបង្ហាញយ៉ាងច្បាស់ថាខ្លួនរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ ។ ដូច្នេះខ្ញុំគិតថា នេះជាការបំពានដំណើរការនីតិវិធី ។ លោក អៀង សារី បង្ហាញថា គាត់មិនឆ្លើយសំណួរអ្វីទេ ការស្នើសុំឲ្យគាត់បញ្ជាក់យោបល់មិនខុសអ្វីពីការសួរឲ្យគាត់ឆ្លើយនោះទេ ដែលការធ្វើបែបនេះគឺជាទម្រង់នៃការបង្ខិតបង្ខំគាត់...» ។ ភ្លាមនោះ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា «កិច្ចនីតិវិធីដែលអង្គជំនុំជម្រះធ្វើដូច្នេះ ក្នុងន័យគោរពសិទ្ធិជនជាប់ចោទនៅក្នុងការធ្វើការកត់សម្គាល់ ធ្វើអត្ថាធិប្បាយ ឯកសារពាក់ព័ន្ធ ឯកសារភស្តុតាងពាក់ព័ន្ធនឹងខ្លួនដែលត្រូវប្រឈមនឹងការចោទប្រកាន់ ។

អង្គជំនុំជម្រះមិនបានដាក់កាតព្វកិច្ចឲ្យ អៀង សារី ទេ គឺក្នុងន័យផ្តល់ឱកាសឲ្យគាត់ប៉ុណ្ណោះ ។ ការធ្វើដូច្នេះមិនមានហេតុផលណាមួយដែលអង្គជំនុំជម្រះដាក់សម្ពាធ ឬគាបសង្កត់បង្ខំជនជាប់ចោទនោះឡើយ...» ។ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជូនលោកចៅក្រម យ៉ា សុខន ថារាល់ការ ដកស្រង់ខ្លឹមសារនៃឯកសារដែល

ខ្លួនចង់បង្ហាញ គឺមិនចាំបាច់ស្នើសុំ ឬសួរទៅជនជាប់ចោទឲ្យធ្វើការបញ្ជាក់បន្ថែមឡើយ លើកលែងតែជនជាប់ចោទខ្លួនឯងមានបំណងធ្វើដូច្នេះ ។

ឯកសារទី២ គឺជាសារាចររបស់បក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧១ ដែលមានចំណងជើងថា "ខួបឆ្នាំទី៣នៃការចាត់តាំងសហករណ៍" ដែលក្នុងសារាចរនេះបានលើកឡើងថា ៖

*"សហករណ៍ជំរុញចលនាឲ្យវាយសម្រុកខ្លាំងនៅសមរភូមិមុខ ទាំងយោធា ទាំងនយោបាយ ទាំងសេដ្ឋកិច្ច ។ បក្សបំផុសចលនាសមូហភាវូបនីយកម្ម ជនបទឆ្នាំ១៩៧៣ ។ ឆ្នាំ១៩៧៣ជាឆ្នាំវាយសង្គ្រាមអាកាសដ៏សាហាវឃោរឃៅព្រៃផ្សៃរបស់ចក្រពត្តិអាមេរិក ។ យើងវាយឈ្នះទាំងសង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិកទាំងកងទ័ពពួកអាក្បត់ហើយចូលកៀកដល់ទីក្រុងភ្នំពេញធ្វើឲ្យស្ថានការណ៍ខ្លាំងប្រែប្រួលយ៉ាងខ្លាំង ទាំងនយោបាយ ទាំងយោធា ទាំងសេដ្ឋកិច្ច ។ ឆ្នាំ១៩៧៤ ជាការវាយសម្រុកភ្នំពេញ និងជុំវិញភ្នំពេញរយៈកាលទីមួយ ។ ឆ្នាំ១៩៧៥ ជាការវាយសម្រុកផ្តាច់ព្រ័ត្រ នេះជាលទ្ធផលជាក់ស្តែងនៃការសម្រេចរបស់បក្ស ។ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ចាត់តាំងសហករណ៍កសិករទូទាំងប្រទេស បើគ្មានសហករណ៍ទប់ទល់សង្គ្រាមអាកាសរបស់ចក្រពត្តិអាមេរិកក៏មិនបានវាយផ្តាច់ខ្លាំងក៏មិនដាច់..." ។*

ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើ លោកចៅក្រម យ៉ា សុខន បានដាក់ឯកសារមួយចំនួនទៀត ដូចជាបទសម្ភាសន៍របស់ អេលីហ្សាប៊ែត បេកយ័រ ជាមួយ អៀង សារី នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៨១ នៅទីក្រុងញូវយ៉ក ។ កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ អៀង សារី នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ សេចក្តីថ្លែងការណ៍របស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានអនុម័តនៅក្នុងមហាសន្និបាតបក្សលើកទី១ ។ បទសម្ភាសន៍របស់ ខឹម ផុន ជាមួយ នួន ជា ។ល ។ ប៉ុន្តែខ្លឹមសាររបស់ឯកសារទាំងនេះ មិនត្រូវបានលោកចៅក្រម យ៉ា សុខន ដកស្រង់លម្អិតឡើយ គឺលោកធ្វើការដកស្រង់តិចតួចក្នុងការបង្ហាញដល់ភាគី និងសាធារណជន ។

## ២) ការបង្ហាញឯកសារភស្តុតាងដោយតំណាងសហព្រះរាជអាជ្ញា

បន្ទាប់ពីលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ និងលោកចៅក្រម យ៉ា សុខន បានដាក់បង្ហាញឯកសាររួច ប្រធានអង្គជំនុំជម្រះបានផ្តល់ឱកាសជូនសហព្រះរាជអាជ្ញាដើម្បីបង្ហាញឯកសារជាភស្តុតាងមួយចំនួន ពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានៅចំពោះមុខភាគីទាំងអស់ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ឌេល លីសាក់ បានលើកយកឯកសារមួយចំនួនមកបង្ហាញដូចជា៖ សុន្ទរកថារបស់ នួន ជា ថ្លែងក្នុងឋានៈជាប្រធានសភាតំណាងប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីស្តីទី ក្នុងការប្រជុំកត់សម្គាល់នូវខួបកំណើតលើកទី៩ នៃកងទ័ពបដិវត្តន៍កម្ពុជា ដែលត្រូវបានចុះផ្សាយ នៅក្នុងវិទ្យុផ្សាយសម្លេងភ្នំពេញក្នុងកម្មវិធីព័ត៌មានអន្តរជាតិនិងត្រូវបានចុះផ្សាយដោយសង្ខេបដោយវិទ្យុប៊ី.ប៊ី.ស៊ី ។ នៅក្នុងសុន្ទរកថានេះ ជនជាប់ចោទ នួន ជា បានថ្លែងថា

*"...នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៧ យើងបានរៀបចំអង្គភាព និងបង្គាប់ឲ្យអង្គការបដិវត្តន៍ វាយប្រហារទីតាំងខ្មាំងនៅស្ទឹងសង្កែ និងនៅបាយដំរាំ ដោយបានបំផ្លាញទីតាំងមូលដ្ឋាននោះ ហើយបានចាប់ខ្មាំងនិងអាវុធនោះផងដែរ ។ នេះគឺជាការទទួលបានអាវុធពីខ្មាំង ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ គឺជាការតស៊ូប្រដាប់អាវុធលើកទីមួយប្រឆាំងនឹងពួកប្រតិកិរិយាផ្ទៃក្នុង គឺជាសង្គ្រាមប្រឆាំងនឹងខ្មាំង ។ នេះគឺជាកំណើតនៃកងទ័ពបដិវត្តន៍កម្ពុជា ។ ការចាប់ផ្តើមការតស៊ូប្រដាប់អាវុធនៅថ្ងៃទី១៧ ខែមករានោះ មិនមែនជាការចៃដន្យទេ ។ ថ្ងៃនេះបានឃើញការចាប់ផ្តើមចលនាបដិវត្តន៍បង្កើតយុទ្ធសាស្ត្រយុទ្ធវិធី ដើម្បីអនុវត្តតទៅមុខ ។ យើងទទួលស្គាល់ថាចក្រពត្តិអាមេរិក បរិវារ វណ្ណៈជិះជាន់ពួកផ្តាច់ការ*

ប៉ុនប៉ងនិងបំភិតបំភ័យប្រជាជនយើង ។ យើងប្រកាន់ជំហរដោយច្បាស់ដើម្បីកម្ទេចពួកអាមេរិកនិងបរិវារ ហើយនិងវណ្ណៈផ្សេងៗទៀត ។ នយោបាយតែឯងមិនជោគជ័យទេ ខ្មាំងប្រើប្រាស់អាវុធនិងឧបករណ៍ផ្តាច់ការ ដើម្បីគាបសង្កត់និងសម្លាប់ប្រជាជនយើង ។ ដោយហេតុនេះហើយ បន្ទាប់ពីឆ្នាំ ១៩៦០ អង្គការបដិវត្តន៍របស់យើងបានសម្រេចច្បាស់ថា ការតស៊ូនយោបាយ និងអាវុធត្រូវប្រើរួមគ្នា» ។

បន្ទាប់ពីអានខ្លឹមសារដកស្រង់នេះរួចហើយ តំណាងសហព្រះរាជអាជ្ញាបានផ្តល់ឱកាសដល់ជនជាប់ចោទ នួន ជា ធ្វើការកត់សម្គាល់ដោយសង្ខេប ដើម្បីបង្ហាញពីការជំទាស់ ឬយល់ស្របលើខ្លឹមសារនេះ ។ ភ្លាមៗនោះជនជាប់ចោទនួន ជា បានធ្វើការបដិសេធលើខ្លឹមសារដកស្រង់នោះទាំងស្រុងដោយបានអះអាងថា ខ្លួនមិនដែលធ្វើជានាយករដ្ឋមន្ត្រីស្តីទីឡើយ ហើយក៏មិនដែលធ្វើសុន្ទរកថាពាក់ព័ន្ធនឹងផ្នែកយោធាដែរ ។ នួន ជា បានទាមទារឲ្យបង្ហាញសំឡេងដែលត្រូវបានថតចម្លងនោះមកស្តាប់ ដើម្បីឲ្យប្រាកដថាពិតជាសំឡេងរបស់ខ្លួន ។

មានឯកសារមួយចំនួនទៀតដែលលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ បានដាក់បង្ហាញនៅចំពោះភាគីរួមមាន ៖ ឯកសារទស្សនាវដ្តីទង់បដិវត្តចុះខែធ្នូឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧, ទស្សនាវដ្តីទង់បដិវត្តចុះខែសីហា ឆ្នាំ១៩៧៧ ដែលបានចុះផ្សាយសុន្ទរកថាមួយ មានចំណងជើងថា «បទឧទ្ទេសនាមរបស់តំណាងអង្គការបក្សស្តីពីមតិណែនាំមួយចំនួនក្នុងការកសាង ពង្រឹង ពង្រីកបក្សដឹកនាំ ក្នុងឱកាសសន្និបាតកម្មាភិបាលភូមិភាគបស្ចិម ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧» ។ នៅមុនពេលបញ្ចប់កិច្ច ដំណើរការសវនាការ លោកតំណាងសហព្រះរាជអាជ្ញា លីសាក់ បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនមានបំណងបង្ហាញឯកសារភស្តុតាងផ្សេងទៀតទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសវនាការនៅថ្ងៃទី១៣-១៥ ខែកុម្ភៈ ឆ្នាំ២០១២ ដែលជាសវនាការសម្រាប់ផ្តល់ឱកាសឲ្យភាគីបង្ហាញឯកសារស្តីអំពីប្រវត្តិ បក្សកុម្មុយនីស្តកម្ពុជា ។

## III. ការបង្ហាញឯកសារនានាពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

នៅថ្ងៃទី១៣-១៥ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តបើកសវនាការ ដើម្បីផ្តល់ឱកាសឲ្យភាគីបង្ហាញឯកសារមួយចំនួនដែលខ្លួនយល់ថាពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ។ សវនាការនេះធ្វើឡើងក្នុងគោលបំណងផ្តល់ឱកាសឲ្យសាធារណៈជនទទួលបានព័ត៌មានកាន់តែទូលំទូលាយស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងឲ្យជនជាប់ចោទមានសិទ្ធិអាចធ្វើអត្ថាធិប្បាយលើឯកសារទាំងនោះ ។ អង្គជំនុំជម្រះបានផ្តល់ពេលវេលាចំនួន២ថ្ងៃកន្លះជូនសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើការបង្ហាញឯកសារដែលពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ។ រីឯភាគីក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ គឺមានតែក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទនួន ជា ប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឱកាសឲ្យធ្វើការឆ្លើយតបទៅនឹងការបង្ហាញឯកសារ ។

### ១) កំណត់សម្គាល់មុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធី

មុនពេលបន្តកិច្ចដំណើរការនីតិវិធី លោកប្រធានអង្គជំនុំជម្រះបានជម្រាបភាគីអំពីការអវត្តមានរបស់លោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ ដោយសារបញ្ហាសុខភាព និងត្រូវបានជំនួសដោយលោកស្រីចៅក្រម ក្លោឌៀ ហ្វេន រហូតដល់ពេលមានវត្តមានរបស់លោកស្រីចៅក្រម ខាតវ្រ៉ាយត៍ វិញ ។ បន្ទាប់មកក្រឡាបញ្ជីបានធ្វើការកត់សម្គាល់អំពីវត្តមានរបស់លោកស្រី អង់តា ហ្គិសេ ដែលជាមេធាវីការពារក្តីថ្មីមួយរូបទៀតរបស់ជនជាប់ចោទ ខៀវ សំផន ។ លោកចៅក្រម និល ណុន បានធ្វើការបញ្ជាក់លោកស្រីមេធាវីអំពីលទ្ធភាពរបស់លោកស្រីដែលអាចគ្រាន់តែតាមដានស្តាប់កិច្ចដំណើរការនីតិវិធី ដោយមិនមានសិទ្ធិបញ្ចេញយោបល់អ្វីទាំងអស់ដោយហេតុថាលោកស្រីមិនទាន់បានស្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៅឡើយ ។ ភ្លាមៗនោះ លោកមេធាវីម៉ៃឃើល ផេស្តមេន ក៏បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការថតចម្លងឯកសារដែលភាគីនឹងត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះដើម្បីឲ្យកូនក្តីរបស់ខ្លួនអាចអានបាន ។ លោកមេធាវីបាន លើកឡើងពីអ្វីដែលលោកប្រធានអង្គជំនុំជម្រះបានប្រើប្រាស់ពាក្យថា «អ្នកឯង» នៅក្នុងសវនាការកាលពីសវនាការលើកមុន ដោយលោក

អះអាងថាវាគឺជាពាក្យដែលមិនសមរម្យនឹងប្រើនៅក្នុងតុលាការ និងថាធ្វើបែបនេះវាជាការលម្មៀងប្រឆាំងនឹងកូនក្តីរបស់ខ្លួន ។

ចំណែកឯមេធាវីជាតិការពារក្តីឲ្យ ខៀវ សំផន គឺលោក គង់ សំអុន បានស្នើសុំឲ្យអង្គជំនុំជម្រះ ធ្វើការកម្រិតចំពោះការដាក់ឯកសាររបស់សហព្រះរាជអាជ្ញាដោយអះអាងថាឯកសារមួយចំនួនមិនជាប់ពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងតំណាក់កាលទី១ ដោយសារវាជាបញ្ជីឯកសារថ្មី ហើយការដែលដាក់បញ្ជីឯកសារថ្មីបែបនេះនឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ។ ឆ្លើយតបនឹងបញ្ហានេះ លោក វ៉ាំងសង់ វ៉ាយ៍ ដេស្មាឯល តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា ឯកសារដែលបានបង្ហាញនោះមិនមែនជាឯកសារថ្មីទេដោយសារតែឯកសារទាំងនោះមានជាប់ពាក់ព័ន្ធនឹងការជំនុំជម្រះក្នុងដំណាក់កាលទីមួយ ។ លោកមេធាវី គង់សំអុន បានឆ្លើយតបទៅវិញដោយបានរៀបរាប់ពីឯកសារដែលមិនទាក់ទង គឺមានចំនួន២៤ ឯកសារ ។ លោកចៅក្រម និល ណុន បន្តាប់ឲ្យមេធាវីការពារក្តីធ្វើការបញ្ជាក់ឲ្យបានច្បាស់ថាតើឯកសារនោះថ្មីដោយសារវាខុសពីសំណុំរឿងឬយ៉ាងណា? ចំពោះភាពពាក់ព័ន្ធនោះគឺមានតែអង្គជំនុំជម្រះប៉ុណ្ណោះជាអ្នកពិចារណា ។ លោកមេធាវី គង់ សំអុន ឆ្លើយតបថាឯកសារទាំងនោះមិនទាន់ត្រូវបានដាក់ឲ្យដេញដោលកាលពីសវនាការមុននៅឡើយទេ ហើយអង្គជំនុំជម្រះ មិនទាន់បានធ្វើចំណាត់ថ្នាក់ជាឯកសារ E3 ថែមទៀតផង ។

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី គឺលោក ខាណាវ៉ាស បានស្នើសុំឲ្យសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារដែលខ្លួនដាក់ជូនអង្គជំនុំជម្រះឲ្យបានច្បាស់អំពីភាពពាក់ព័ន្ធនឹងសវនាការនៅក្នុងដំណាក់កាលទី១ ដើម្បីចៀសវាងការឆ្លៀតឱកាសក្នុងការដាក់ឯកសារផ្សេងដែលមិនពាក់ព័ន្ធ ។ ឆ្លើយតបទៅនឹងការលើកឡើងនេះ សហព្រះរាជអាជ្ញាបានអះអាងថា ឯកសារដែលខ្លួនដាក់ គឺមួយចំនួនមិនស្ថិតក្នុងប្រភេទឯកសារ E3 ទេ ប៉ុន្តែវាសុទ្ធសឹងតែជាឯកសារដែលគាំទ្រប្រភេទឯកសារ E3 ដែលពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងការជម្លៀសប្រជាជនជាដើម ។ បន្ទាប់មកលោកចៅក្រម និល ណុន បានផ្តល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីធ្វើការបង្ហាញឯកសារដែលខ្លួនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។

## ២) សហព្រះរាជអាជ្ញាបង្ហាញឯកសារទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

### *ក) ឯកសារពាក់ព័ន្ធនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា*

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក វ៉ាំងសង់ វ៉ាយ៍ ដេស្មាឯល បានបង្ហាញឯកសារចំនួន១២ ដែលសហព្រះរាជ



វ៉ាំងសង់ វ៉ាយ៍ ដេស្មាឯល
តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

អាជ្ញាយល់ថាមានការជាប់ទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ។ ឯកសារដំបូង គឺជាសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមដែលមានចំណងជើងថា "ប្រវត្តិបក្ស" ដែលមានខ្លឹមសារពាក់ព័ន្ធនឹងការកំណត់យកឆ្នាំ១៩៦០ជាឆ្នាំកំណើតរបស់បក្ស ។ នៅក្នុងឯកសារនេះ មានកំណត់អំពីព្រឹត្តការណ៍សំខាន់ៗមួយចំនួនទៀតដូចជា ការបង្កើតសហករណ៍ ការបើកការវាយប្រហារលើកទីមួយរបស់បក្ស និងការប្រារព្ធពិធីប្រវត្តិផ្សេងៗជាដើម ។

ឯកសារទី២ គឺទស្សនាវដ្តីទង់បដិវត្តលេខពិសេសចុះ

ខែកញ្ញាក្នុងឆ្នាំ១៩៧៧ ឯកសារនេះមាន និយាយអំពីសន្ទរកថារបស់ ប៉ុល ពត ដែលបានកំណត់កាលបរិច្ឆេទសំខាន់ៗរបស់បក្ស មាគ៌ាយុទ្ធសាស្ត្ររបស់បក្ស និងជោគវាសនារបស់ខ្មាំងបដិវត្តន៍ ។ ចំពោះខ្លឹមសារនៅក្នុងឯកសារនោះគឺ មានដូចជា *“សហករណ៍គឺជាប្រភពចម្បង ដើម្បីធ្វើការផ្គត់ផ្គង់សេដ្ឋកិច្ចកំលាំងរបស់ខ្មែរក្រហម ។ ចំពោះការកំណត់ខ្មាំងគឺគេមើលទៅលើទិដ្ឋភាពរបស់សង្គមនៅពេលនោះ”* ។ ប៉ុល ពត បានលើកឡើងថា នៅក្នុងរបបសក្តិភូមិ មានវណ្ណៈជិះជាន់ និងអ្នកដែលត្រូវគេជិះជាន់ ដែលមិនអាចធ្វើការផ្សះផ្សារគ្នាបាន ហើយជាសត្រូវស្លាប់រស់នឹងគ្នា ។

ឯកសារទី៣ គឺជាឯកសារទស្សនាវដ្តីទង់បដិវត្តលេខ៨ ចុះផ្សាយនៅខែសីហា ឆ្នាំ១៩៧៥ ។ ឯកសារនេះមានអត្ថបទសំខាន់ៗចំនួនបួន ដែលមានរៀបរាប់អំពីផលប៉ះពាល់ដល់បដិវត្តន៍ដោយសារ ការកម្ទេចខ្មាំង ការពន្យល់អំពីស្ថានភាពសេដ្ឋកិច្ចរបស់បក្សទាក់ទងនឹងកសិកម្ម សិប្បកម្ម ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ និងគោលជំហររបស់បក្សក្នុងការវាយយកទីក្រុងភ្នំពេញ ។ ក្នុងឯកសារនោះ ប៉ុល ពត បានលើកឡើងថា នៅក្នុងកិច្ចប្រជុំរបស់បក្សបានសម្រេចត្រូវវាយយកទីក្រុងភ្នំពេញក្នុងពាក់កណ្តាលឆ្នាំ១៩៧៤ ។

ឯកសារទី៤ ជាឯកសារដែលបក្សបានបោះពុម្ពផ្សាយមានចំណងជើងថា *“ការប្រារព្ធខួបលើកទីបីក្នុងការបង្កើតសហករណ៍”* ។ ឯកសារនោះ មាននិយាយអំពីតួនាទីរបស់សហករណ៍ក្នុងការគ្រប់គ្រងផ្នែកសេដ្ឋកិច្ចដែលដណ្តើមបានពីខ្មាំងដូចជាពួកសក្តិភូមិ និងម្ចាស់ដីជាដើម ហើយមាននិយាយពីអ្វីដែលនឹងកើតឡើងក្រោយថ្ងៃ១៧ មេសា ១៩៧៥ ។

នៅក្នុងឯកសារនោះបាននិយាយថាបក្សបានរៀបចំសហករណ៍ដើម្បីអាចប្រមូលប្រជាជនដើម្បីកម្ទេចរបបកម្មសិទ្ធិឯកជន អាចកម្ចាត់ខ្មាំង អាចលុបបំបាត់ការធ្វើពាណិជ្ជកម្មដែលនៅសល់ពីរបបចាស់ ហើយពួកខ្មាំងត្រូវបានកម្ទេចជាបណ្តើរៗតាមរយៈការបង្កើតសហករណ៍នេះ ។

ឯកសារទី៥ គឺទស្សនាវដ្តីទង់បដិវត្តដែលចុះផ្សាយនៅខែតុលា ឆ្នាំ១៩៧៦ ដែលមានជាសេចក្តីថ្លែងរបស់ ប៉ុល ពត ក្នុងឱកាសខួបទី១៧នៃមហាជោគជ័យនៃបក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងនោះមានចំណុចសំខាន់ៗពីរ គឺការសម្រេចបិទផ្សារនៅឆ្នាំ១៩៧២ និងការជម្លៀសប្រជាជនចេញពីទីក្រុង ។ ខ្លឹមសារនៅក្នុងឯកសារនោះបានបញ្ជាក់ថាការសម្រេចលុបបំបាត់ផ្សារគឺជាបញ្ហាចម្បងដែលត្រូវអនុវត្ត បើមិនដូច្នោះទេទិន្នផលមួយចំនួនធំនឹងធ្លាក់ទៅក្នុងដៃរបស់ខ្មាំង ។ ចំពោះការជម្លៀសប្រជាជនវិញគឺជាការតស៊ូវណ្ណៈព្រោះបក្សអាចធ្វើការបំបែកកម្លាំងរបស់ខ្មាំងបាន ។

ឯកសារទី៦ គឺទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តដែលត្រូវបានសរសេរដោយដៃ ហើយមានអត្ថបទសំខាន់ចំនួនប្រាំ ។ នៅក្នុងនោះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក ដេស្មាឯល បានលើកឡើងពីអត្ថបទមួយដែលសរសេរនៅឆ្នាំ១៩៧៤អំពីវណ្ណៈទាំង៥ នៅក្នុងប្រទេសកម្ពុជា ហើយក្រោយមក ប៉ុល ពត បានពណ៌នាពីវណ្ណៈទាំងនោះនៅក្នុងឱកាសប្រារព្ធខួបកំណើតបក្សនៅឆ្នាំ ១៩៧៧ ។



ទីមួយ វណ្ណៈសក្តិភូមិដែលមានវណ្ណៈសក្តិភូមិ អារីស្តូក្រាត និងសក្តិភូមិម្ចាស់ដី ។

ទីពីរ គឺវណ្ណៈមូលធន ដែលមានមូលធននិយមកំប្រាឌ័រ និងមូលធននិយមជាតិ ។

ទីបី គឺវណ្ណៈគហបតី ។

ទីបួន គឺវណ្ណៈកសិករ ដែលមានកសិករ មាន កណ្តាល និងក្រនិង

ទីប្រាំ គឺវណ្ណៈកម្មករ ដែលមានកម្មករដែលខំធ្វើការ កម្មករនៅកំពង់ផែ កម្មករអ្នកធាក់ស៊ីក្លូ ជាដើម ។

នៅក្នុងឯកសារនោះក៏មានការចុះផ្សាយអត្ថបទដែលធ្វើការអប់រំនយោបាយដើម្បីលុបបំបាត់វណ្ណៈនៅក្នុងប្រទេសកម្ពុជាទៀតផង ។

ឯកសារទី៧គឺជាឯកសារបោះពុម្ពផ្សាយដែលនិយាយពី "ការសិក្សាពីប្រវត្តិនៃចលនាបដិវត្តន៍ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា" ។ ឯកសារនេះ និយាយពីនយោបាយរបស់បក្ស ការធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យដែលការធ្វើបដិវត្តន៍នេះត្រូវធ្វើការវិភាគលើស្ថានភាពរបស់សង្គម ។ នៅក្នុងអត្ថបទនេះក៏មាននិយាយពី ស៊ីវ និង យ៉ា ដែលត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាអ្នកដែលមិនគាំទ្រការវិភាគរបស់បក្ស ។

ឯកសារទី៨ ទស្សនាវដ្តីទង់បដិវត្តចេញផ្សាយនៅខែកញ្ញា ឆ្នាំ១៩៧៨ ដែលនិយាយពីការជ្រៀតជ្រែករបស់វៀតណាមមកលើកម្ពុជា ។

ឯកសារទី៩ គឺជាឯកសារដែលនិយាយពីការប្រឆាំងរបស់ប្រជាជនទៅនឹងពួកចក្រពត្តិអាមេរិក ក្នុងឆ្នាំ១៩៧៣ ដល់ ១៩៧៥ ការប្រឆាំងជាមួយបរិវាររបស់ លន់ នល់ និងការប្រឆាំងនឹងវៀតណាម ។ ខ្លឹមសារនៅក្នុងឯកសារនេះក៏មាននិយាយពីគោលបំណងដែលវៀតណាមចង់លេបយកទឹកដីរបស់កម្ពុជាក្នុងរូបភាពជាការបញ្ចូលប្រទេសកម្ពុជាឲ្យទៅក្នុងសហគមន៍ឥណ្ឌូចិន ។ ចំពោះលក្ខន្តិកៈរបស់បក្សដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៦០ ក៏មាននិយាយពីគោលការណ៍របស់បក្សដែលត្រូវអនុវត្តន៍ដូចជាការរាយការណ៍ និងការសម្រេចនៅក្នុងបក្សជាដើម ។

ឯកសារទី១០ មានចំណងជើងថា "កសាង និងអប់រំតាមទស្សនៈរបស់ម៉ាក្សឡេនីន" ដែលបង្ហាញយ៉ាងច្បាស់ពីគោលនយោបាយរបស់បក្ស ដោយអនុលោមតាមទ្រឹស្តីរបស់ម៉ាក្សលេនីន និងកំណត់ពីវណ្ណៈរបស់សង្គមយ៉ាងជាក់លាក់ ។ ខ្លឹមសារនៅក្នុងឯកសារនេះក៏មាននិយាយអំពីឥទ្ធិពលរបស់សមរភូមិក្រោយទៅលើសមរភូមិមុខ មានន័យថាបើសមរភូមិក្រោយខ្លាំងនិងមានការសាមគ្គីគ្នានោះ សមរភូមិមុខក៏ខ្លាំងដែរ ។

ឯកសារទី១១ មានចំណងជើងថា "ខ្មាំងវាយពីក្រោយ" ដែលនៅក្នុងនោះមាននិយាយអំពីការប្រមូលផ្តុំកំលាំងរបស់ខ្មាំងដើម្បីបំបែកកម្លាំងរបស់បដិវត្តន៍ ការបញ្ចូលកងកុម្ម៉ង់ដូទៅក្នុងតំបន់រំដោះ ដើម្បីដណ្តើមប្រជាជន និងសេដ្ឋកិច្ចដែលអាចធ្វើឲ្យបក្សរលាយ ។

ឯកសារទី១២ គឺជាទស្សនាវដ្តីទង់បដិវត្តលេខពិសេសដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងខែធ្នូ ឆ្នាំ១៩៧២ ដើម្បីធ្វើការណែនាំអំពីមនោគមន៍វិជ្ជារបស់បក្ស និងបញ្ជាក់ពីការធ្វើទំនាក់ទំនងរាយការណ៍ទៅថ្នាក់លើ ការជ្រៀតជ្រែករបស់ខ្មាំងដែលមានបំណងបំផ្លាញបដិវត្តន៍ជាដើម ។

ក្រោយពីបានបញ្ចប់ការបង្ហាញឯកសារទាំង១២ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់វេទិកាទៅសហភាគារបស់ខ្លួនដើម្បីធ្វើការបង្ហាញឯកសារចំនួនបីទៀតទាក់ទងនឹងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកសហព្រះរាជអាជ្ញារងជាតិ ច័ន្ទ តារាវស្មី បានបង្ហាញមួយចំនួនទៀតដូចជា៖

ឯកសារទី១ ដែលជាអត្ថបទទាក់ទងនឹងគោលនយោបាយក្នុងការកម្ទេចសត្រូវការត្រួតពិនិត្យ ប្រជាជនស៊ីវិល និងតួនាទីរបស់សហករណ៍ និងការផ្តល់និយមន័យលើពាក្យ "សត្រូវ" ។

ឯកសារទីពីរ ជាអត្ថបទដែលចេញផ្សាយនៅក្នុងទង់បដវត្តន៍លេខពិសេសនៅឆ្នាំ១៩៧២ ដែលពាក់ព័ន្ធនឹងគោលនយោបាយមនោគមន៍វិជ្ជា និងការចេញសេចក្តីសម្រេចនានារបស់បក្ស ។ ខ្លឹមសារនៅក្នុងឯកសារនោះ បានលើកឡើងថា បក្សមិនត្រូវធ្វើការចេញសារាចរណែនាំណាមួយដែលធ្វើឲ្យប្រជាជនមិនពេញចិត្តបែរមកប្រឆាំងនឹងបដិវត្តន៍វិញ ។ការចេញសារាចរណាមួយត្រូវមានការប្រជុំដើម្បីធ្វើឲ្យបានសមស្រប ពោលគឺត្រូវអនុវត្ត

ការផ្សារឲ្យច្បាស់លាស់ និងម៉ឺងម៉ាត់ ដូចជាការរាយការណ៍អំពីខ្លាំង អំពីប្រជាជន ដើម្បីឲ្យថ្នាក់លើអាចក្តាប់សភាពការណ៍ និងមានដំណោះស្រាយទាន់ពេលវេលា ។

ឯកសារទី៣ គឺទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តដែលនិយាយពីទស្សនៈពាក់ពន្ធ័នឹងការកសាងគ្រួសារ ។ ខ្លឹមសារដកស្រង់ "ពួកចក្រពត្តិសក្តិភូមិ តែងតែគិតពីភាពមានបានស្តុកស្តម្ភ ទើបគ្រួសាររបស់គេមានសេចក្តីសុខ ហើយពួកគេគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនដោយមិនបានគិតពីផលប្រយោជន៍ជាតិ..." ។ "រីឯពួកយុវជន យុវនារីបដិវត្តបានយកគ្រួសារមកផ្សារភ្ជាប់នឹងផលប្រយោជន៍ប្រទេសជាតិ" ។ "ចំពោះការកសាងគ្រួសារយុវជន យុវនារី ត្រូវសួរយោបល់របស់អង្គការព្រោះមានតែអង្គការទេដែលអាចធ្វើការពិនិត្យបានគ្រប់ជ្រុងជ្រោយដែលមិនមានជាប់ជំពាក់ជំពិនជាមួយខ្សែរបស់ខ្មាំងដូចនេះ យុវជន យុវនារី មិនត្រូវជ្រើសរើសដោយអត្តនោម័តបានទេ" ។

**១) ឯកសារពាក់ពន្ធ័នឹងសកម្មភាព និងតួនាទីរបស់ ខៀវ សំផន**

តំណាងសហព្រះរាជអាជ្ញាជាតិ លោក វេង ហ៊ិត បានធ្វើការបង្ហាញឯកសារដែលពាក់ព័ន្ធ នឹងប្រវត្តិ និងតួនាទីរបស់ ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ លោក វេង ហ៊ិតបានបញ្ជាក់ ថាឯកសារទាំងនោះឆ្លុះបញ្ចាំងពីតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន ដែលមានតួនាទីសំខាន់ៗមួយចំនួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏បង្ហាញពីការយល់ដឹងរបស់ជនជាប់ចោទរូបនេះចំពោះ ឧក្រិដ្ឋកម្មដែលបានកើតក្នុងរបបខ្មែរក្រហម ។ នៅក្នុងឯកសារនោះ ខៀវ សំផន ធ្លាប់បានធ្វើសេចក្តីថ្លែងសុន្ទរកថាអំពីភាពជោគជ័យរបស់កងទ័ពបដិវត្តន៍ និងពេលកំពុងវាយលុកចូលនៅទីក្រុងភ្នំពេញ ។ ក្រៅពីនោះ ខៀវ សំផន ក៏បានធ្វើសុន្ទរកថាទៅកាន់កងទ័ពអំពីការកាត់ផ្តាច់ផ្លូវដឹកជញ្ជូនស្បៀងឲ្យប្រជាជននៅទីក្រុងភ្នំពេញដែលបានផ្តល់ឲ្យដោយអាមេរិក និងធ្លាប់បានធ្វើសេចក្តីថ្លែងការណ៍ក្នុងការសម្លាប់ជនក្បត់ទាំង៧រូបនៃរបបសាធារណៈរដ្ឋខ្មែរដោយលើកឡើងថាមេក្បត់ទាំង៧នាក់ត្រូវតែកម្ចាត់ចោលទោះបីចំណាយអស់ប៉ុន្មានក៏ដោយ ។ ជាងនេះទៅទៀត ខៀវ សំផន ក៏បានធ្វើការអំពាវនាវឲ្យប្រជាជនចូលរួមក្នុងចលនារបស់ខ្មែរក្រហមដើម្បីផ្តួលរំលំរបប លន់ នល់ ។ នៅថ្ងៃបញ្ចប់នៃសង្គ្រាមស៊ីវិល ខៀវ សំផន បានធ្វើសេចក្តីអំពាវនាវថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៥ ហើយដោយយោងតាមសេចក្តីអំពាវនាវទាំងអស់នេះ គឺឆ្លុះបញ្ចាំងឲ្យឃើញថាជនជាប់ចោទពិតជាមានការយល់ដឹងច្បាស់លាស់ចំពោះសភាពការណ៍ដែលកើតនៅក្នុងពេលនោះ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានធ្វើការបង្ហាញឯកសារមួយចំនួនទៀត មានដូចជា៖

ឯកសារទី១ គឺសៀវភៅដែលត្រូវបានបោះពុម្ពផ្សាយដោយ ខៀវ សំផន ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រថ្មីៗនៅកម្ពុជា" សៀវភៅនេះនិយាយពីជីវិតរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានរត់ចូលព្រៃក្នុងឆ្នាំ១៩៦៧ ដោយសារខ្លួនមានឈ្មោះនៅក្នុងចំណោមមនុស្សទាំង៣៦នាក់ ដែលត្រូវចាប់ខ្លួន និងចំណាប់អារម្មណ៍របស់ ខៀវ សំផន ដែលបានចូលរួមក្នុងចលនាខ្មែរក្រហម ។

ឯកសារទី២ ឯកសារដែលត្រូវបានផ្សព្វផ្សាយដោយកាសែតញូវយ៉កថែមដែល ខៀវ សំផន ទទួលស្គាល់ថា ខ្លួនបានចូលរួមនៅក្នុងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយធ្វើការអំពាវនាវដល់ប្រជាជន និងព្រះសង្ឃឲ្យក្រោកឡើងក្នុងការវាយកម្ទេចខ្មាំង ។

ឯកសារទី៣ គឺជាឯកសារដែលត្រូវបានធ្វើឡើងដោយ ខៀវ សំផន នៅប្រហែលឆ្នាំ១៩៧៣ ដោយលើកឡើងថា កងទ័ពរបស់ខ្មែរក្រហមបានសម្លាប់កងទ័ពរបស់ខ្មាំងអស់ជាច្រើនម៉ឺននាក់ និងការវាយកាត់ផ្តាច់ស្ពាន ផ្លូវ ដែលជាប្រភពនាំស្បៀងឲ្យ លន់ នល់ ។

ឯកសារទី៤ គឺជាឯកសារដែល ខៀវ សំផន ធ្វើសេចក្តីថ្លែងការណ៍នៅប្រទេសកូរ៉េខាងជើងពីស្ថានភាពនៅប្រទេសកម្ពុជា ហើយតាមរយៈនៃឯកសារនេះបង្ហាញឲ្យឃើញថា ខៀវ សំផន បានដឹងពីឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងប្រទេសកម្ពុជា ។

ឯកសារទី៦ ជាឯកសារបទសម្ភាសន៍ជាមួយជនជាប់ចោទ ខៀវ សំផន ដោយលោក អៀ ម៉េងទ្រី ទាក់ទងនឹងគណៈមជ្ឈិម

របស់បក្ស និងការវិលត្រឡប់របស់ ខៀវ សំផន មកប្រទេសកម្ពុជា ក្រោយពីបានទៅរៀននៅប្រទេសបារាំង ។

ឯកសារទី៧ និយាយអំពីមន្ទីរ១០០ដែលមានទីតាំងនៅជាប់ប្រទេសវៀតណាម និងព្រឹត្តិការណ៍ នៅខែមីនាឆ្នាំ១៩៧០ ដែលជនជាប់ចោទនិយាយថា មានការទាក់ទងគ្នារវាងសម្ដេចសីហនុនិង ប៉ុល ពត ដោយមានការសម្របសម្រួលពីលោក ជូ អេនឡាយ ។

ឯកសារទី៨ គឺកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតជាមួយជនជាប់ចោទ ខៀវ សំផន ដែលទទួលស្គាល់ថាខ្លួនពិតជាបានរស់នៅជាមួយមេដឹកនាំខ្មែរក្រហម ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក ថារីក អាប់ឌុលហាក់ បានបង្ហាញនូវឯកសារខ្សែវីដេអូចំនួនពីរដែលខ្សែវីដេអូ


ថារីក អាប់ឌុលហាក់
តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

ទីមួយនិយាយអំពីការធ្វើទស្សនកិច្ចរបស់ ខៀវ សំផន នៅទីក្រុងហាណូយ នៅឆ្នាំ១៩៧៤ ។ ឯកសារវីដេអូនោះ បានបង្ហាញនូវការទទួលស្វាគមន៍ពីសំណាក់គណៈប្រតិភូវៀតណាម នៅក្នុងនោះក៏មានវត្តមានរបស់ អៀង សារី ដែរ ។ រីឯខ្សែវីដេអូទីពីរ គឺជាឯកសារបទសម្ភាសន៍ជាមួយ ខៀវ សំផន នៅឆ្នាំ២០០៦ ដែលនៅក្នុងវីដេអូនោះជនជាប់ចោទបានរៀបរាប់អំពីសកម្មភាពដែលបានចូលរួមក្នុងបក្សកុម្មុយនីស្តនៅពេលខ្លួនសិក្សានៅប្រទេសបារាំង និងការចូលរួមជាមួយខ្មែរក្រហម ។ នៅក្នុងវីដេអូនោះ ខៀវ សំផន បានពន្យល់ថា ខ្លួនត្រូវបានជ្រើសរើសឲ្យធ្វើជាតស្សូរជនខ្មែរក្រហម ដោយសារតែខ្លួនត្រូវបានទទួលស្គាល់ថាជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ ។ តំណាងសហព្រះរាជអាជ្ញាអះអាងថានៅក្នុងខ្សែវីដេអូនោះបានបង្ហាញឲ្យឃើញថា ខៀវ សំផន ពិតជាបានដើរតួរយ៉ាងសកម្មក្នុងឋានៈជាមេដឹកនាំខ្មែរក្រហមនៅពេលដែល ប៉ុល ពត កំពុងតែកាន់អំណាចដោយកំបាំងមុខនោះ ។ ខៀវ សំផន បានបញ្ជាក់នៅក្នុងបទសម្ភាសន៍នោះថា "ប៉ុល ពត គឺជាជនស្នេហាជាតិដែលបានរំដោះប្រទេស និងប្រជាជនចេញពីភាពក្រីក្រ ទោះបីជាកិច្ចការនោះត្រូវទទួលបរាជ័យក៏ដោយ" ។

**ក) ឯកសារពាក់ព័ន្ធនឹងសកម្មភាព និងតួនាទីរបស់ អៀង សារី**

លោកសហព្រះរាជអាជ្ញារងជាតិ ច័ន្ទ តារាវស្នី បានបង្ហាញឯកសារមួយចំនួនទាក់ទងនឹងជនជាប់ចោទ អៀង សារី ដោយកត់សម្គាល់នូវតម្លៃជាភស្តុតាងចំពោះឯកសារដែលជាសេចក្ដីថ្លែងការណ៍ និងសន្ទរកថារបស់ជនជាប់ចោទរូបនេះ ។ លោក តារាវស្នី បានរៀបរាប់ពីសកម្មភាពចូលរួមនិងតួនាទីរបស់ អៀង សារី នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ ភ្លាមៗនោះ មេធាវីអន្តរជាតិការពារក្ដីឲ្យ អៀង សារី គឺលោក ខាណារ៉ាស បានក្រោកឈរនិងធ្វើការកត់សម្គាល់ថាសហព្រះរាជអាជ្ញាកំពុងតែធ្វើ សេចក្ដីថ្លែងបើកដោយមិនបានបង្ហាញឯកសារនោះទេ ។ ទាក់ទងនឹងបញ្ហានេះលោកប្រធានអង្គជំនុំជម្រះ បានបង្គាប់ឲ្យសហព្រះរាជអាជ្ញាបន្តការធ្វើការបង្ហាញពីឯកសារ និងរំឭកទៅដល់គ្រប់ភាគីឲ្យគោរពតាម គោលបំណងរបស់សវនាការ ។ បន្ទាប់មកលោក តារាវស្នី បានលើកឡើងនូវឯកសារបទសម្ភាសន៍ជាមួយ អៀង សារី ដែលធ្វើឡើងដោយបុគ្គលម្នាក់នៃគណៈប្រតិភូអាមេរិកដែលមកធ្វើទស្សនកិច្ចនៅកម្ពុជាក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ បទសម្ភាសន៍នោះ រៀបរាប់អំពី អៀង សារី គឺជាបុគ្គលមួយរូបដែលមានភាពរួសរាយ និងជាអ្នកដែលបានចូលរួមបង្កើតចលនាកុម្មុយនីស្ត ។ នៅក្នុងបទសម្ភាសន៍ នោះក៏បានបង្ហាញឲ្យឃើញពីភាពលំបាកក្នុងការធ្វើទំនាក់ទំនងគ្នារវាងចលនាកុម្មុយនីស្តកម្ពុជា និងប្រទេសវៀតណាមនៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ ដល់ ១៩៧៥ ។ អៀង សារី បានលើកឡើងថាសត្រូវផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា រួមមាន ពួក សេ.អ៊ី.អា (C.I.A) កា.ហ្សេ.បេ (K.G.B) និងវៀតណាមដែលចង់

បង្ហាញ និងគ្រប់គ្រងបក្សកុម្មុយនីស្តកម្ពុជា ។ ការបង្ហាញនេះមិនមានការឆ្លើយតបពីសំណាក់ជនជាប់ចោទទេ ។ បន្ទាប់ពីបញ្ចប់ការបង្ហាញឯកសារនេះរួចមក លោក ច័ន្ទ តាការស្មី បានផ្ទេរវេទិកាឲ្យសហភាគរបស់ខ្លួន គឺលោក វីល្លៀម ស្មីត ដើម្បីលើកឡើងពីឯកសារជាក់លាក់ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី បន្តទៀត ។ លោក ស្មីត បានកត់សម្គាល់ថា អៀង សារី បានផ្តល់បទសម្ភាសន៍ជាច្រើនសារ ប៉ុន្តែលោកនឹងមិនលើកឡើងនូវបទសម្ភាសន៍ទាំងអស់នោះទេ គឺលោកនឹងបង្ហាញតែបទសម្ភាសន៍ណាដែលជាក់លាក់តែប៉ុណ្ណោះ ។ លោកបានបង្ហាញវីដេអូមួយដែលនិយាយអំពីកិច្ចប្រជុំរវាងសម្តេចសីហនុជាមួយមេដឹកនាំខ្មែរក្រហមនៅដើមឆ្នាំ១៩៧០ ។បន្ទាប់មក លោកបានបង្ហាញ ពីបទសម្ភាសន៍របស់ជនជាប់ចោទរូបនេះជាមួយលោក ស្ទីវ ហេដឌ័រ ដែល អៀង សារី បាននិយាយថា ខ្លួនគឺជាអ្នកទាក់ទងរវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សប្រជាធិបតេយ្យក្នុងការនាំប្រជាជនឲ្យចូលរួមក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ។ លោក ស្មីត ក៏បានបង្ហាញបទសម្ភាសន៍នោះជូនអង្គជំនុំជម្រះដោយ អៀង សារី បាននិយាយថាខ្លួនបានទៅចូលរួមប្រជុំជាមួយ ប៉ុល ពត នៅក្នុងប្រទេសចិននៅឆ្នាំ១៩៧៤ និងបានពិភាក្សាគ្នាជាមួយលោក ជូ អេនឡាយ អំពីគម្រោងរំដោះទីក្រុងភ្នំពេញ ។ អៀង សារី បាននិយាយថា នៅក្នុងកិច្ចប្រជុំនោះបានបង្កើតគម្រោងជម្លៀសប្រជាជនចេញពីទីក្រុង ប៉ុន្តែគម្រោងនោះ នៅមិនទាន់ច្បាស់នៅឡើយទេ ។ លោក ស្មីត បានធ្វើការប្រៀបធៀបបទសម្ភាសន៍នេះ ជាមួយនឹងបទសម្ភាសន៍មួយទៀតដែល អៀង សារី បានធ្វើជាមួយទីភ្នាក់ងារព័ត៌មាន អេ.ប៊ី.ស៊ី (A.B.C) ដោយជនជាប់ចោទអៀងសារីបាននិយាយថាខ្លួនបានផ្តល់យោបល់ដល់ ប៉ុល ពត ថាគួរតែមានការរៀបចំមុនពេលធ្វើការជម្លៀសប្រជាជន ។ ឯកសារចុងក្រោយដែលលើកឡើងដោយលោក ស្មីត គឺបង្ហាញអំពីទស្សនៈកិច្ចរបស់ អៀង សារី ទៅកាន់ប្រទេសចិននៅឆ្នាំ១៩៧៤ ដើម្បីសុំជំនួយ ។ នៅក្នុងឯកសារនោះ មាននិយាយអំពីការលើកឡើងរបស់គណៈប្រតិភូខ្មែរក្រហមពីគម្រោងសម្លាប់ជនក្បត់ទាំង៧រូបនៃរបប លន់ នល់ ។ លោកបានលើកឡើងពីឯកសារបទសម្ភាសន៍ដែល អៀង សារី បានធ្វើជាមួយគណៈប្រតិភូប្រទេសន័រវេ (Norway) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកលោកបានអានឯកសារបទសម្ភាសន៍របស់ អៀង សារី ជាមួយកាសែត ឡឺម៉ុង (Le Monde) នៅឆ្នាំ១៩៧២ ។ លោក ស្មីត បានបញ្ជាក់ថា អៀង សារី ពិតជាមានតួនាទីខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ ។

**ឃ) ឯកសារពាក់ព័ន្ធនឹងសកម្មភាព និងតួនាទីរបស់ នួន ជា**

លោកសហព្រះរាជអាជ្ញារងជាតិ ចាន់ តាការស្មី បានបង្ហាញឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា ដោយលើកឡើងនូវសេចក្តីថ្លែងការណ៍របស់ នួន ជា ក្នុងអំឡុងពេលសវនាការលើកមុន និងធ្វើការប្រៀបធៀបជាមួយសេចក្តីថ្លែងការណ៍ដែលជនជាប់ចោទរូបនេះបានធ្វើជាមួយសហចៅក្រមស៊ើបអង្កេត ។បន្ទាប់មក លោក ខែល លីសាក់ បង្ហាញឯកសារជារូបថតចំពោះមុខអង្គជំនុំជម្រះ ។ លោក លីសាក់ បានចាប់ផ្តើមដោយធ្វើការបង្ហាញឯកសារបីដែលថតក្នុងទិកាសមហាសន្និបាតរបស់បក្សនៅឆ្នាំ១៩៧១ ដែលរូបថតនីមួយៗបង្ហាញពីឥស្សរជនសំខាន់ៗរបស់បក្សដោយលោកបានផ្តល់ឯកសារទាំងនោះដល់ក្រុមមេធាវីការពារក្តី នួន ជា ដើម្បីឲ្យជនជាប់ចោទអាចធ្វើអត្ថាធិប្បាយទៅលើឯកសារនោះបាន ។ លោកមេធាវីអន្តរជាតិ អេនឌ្រូ អ៊ីនូហ្វី បានបញ្ជាក់ថាខ្លួនបានទទួលរូបថតដោយមិនធ្វើអត្ថាធិប្បាយ អ្វីឡើយ ។

**៣) ការបង្ហាញឯកសារដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា**

មុនពេលនៃការចាប់ផ្តើមបង្ហាញឯកសារដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក គង់ សំអុន មេធាវីការពារក្តី ខៀវ សំផន បានបដិសេធឯកសារដែលនឹងធ្វើការបង្ហាញដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែឯកសារទាំងនោះមិនទាន់ត្រូវបានអង្គជំនុំជម្រះទទួលស្គាល់ ហើយឯកសារខ្លះមិនទាន់ត្រូវបានបកប្រែគ្រប់ភាសានៅឡើយ ។ ពាក់ព័ន្ធនឹងបញ្ហានេះលោកប្រធានអង្គជំនុំជម្រះបានប្រកាសថាអង្គជំនុំជម្រះនឹងធ្វើការសម្រេចលើការជំទាស់នេះនៅពេលក្រោយ ។

លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុណូហ្គ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវឯកសារ

ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៤ដោយអះអាងថាឯកសារទាំងនោះមានសារសំខាន់ពីព្រោះវាពាក់ព័ន្ធនឹងប្រវត្តិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកស្រីក៏បានបញ្ជាក់ផងដែរថាឯកសារទាំងនោះត្រូវបានបកប្រែរួចហើយ ប៉ុន្តែលោកស្រីស្នើសុំឲ្យមានការបកប្រែផ្ទាល់មាត់ចំពោះឯកសារដកស្រង់ខ្លីៗ ដែលនឹងត្រូវអាននៅពេលកិច្ចដំណើរការសវនាការ ។ លោក អូលីវីយេ បាហ៊ូន (Olivier Bahougne) មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្តការដាក់ឯកសារបន្ទាប់ពីការលើកឡើងរបស់លោកស្រីអេលីហ្សាប៊ែត ដោយបានបង្ហាញឯកសារជាសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ដែលបាននិយាយថា ខ្លួនមិនជឿថានៅលើពិភពលោកនេះមានយុត្តិធម៌ទេ ពីព្រោះមនុស្សម្នាក់ៗសុទ្ធតែចង់ឈ្នះ ។ ប្រសិនបើពិភពលោកមានយុត្តិធម៌ ខ្លួនមិនត្រូវបាននាំមកកាត់ទោសនោះទេ ព្រោះអ្វីដែលខ្លួនបានធ្វើគឺដើម្បីប្រទេសជាតិ ហើយខ្លួនមិនដែលបានទទួលលុយ ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាម្តងណាឡើយ ។ លោកមេធាវីក៏បានអានឯកសារប្រតិចារិកនៅចំណុចដែល ខៀវ សំផន បាននិយាយពីកាសែត ឡុបសែវ៉ាទ័រ (L’Observateur) ។ លោកបានបញ្ជាក់ថា តាមរយៈឯកសារទាំងនេះ គឺបង្ហាញឲ្យឃើញថា ខៀវ សំផន មានទំនាក់ទំនងជាមួយចលនាខ្មែរក្រហមតាំងពីយូរមកហើយ ។ បន្ទាប់មក លោកបានលើកឡើងពីនិក្ខេបបទថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចរបស់ ខៀវ សំផន ដោយអះអាងថា ជនជាប់ចោទរូបនេះមានការពេញចិត្តចង់ឃើញទ្រឹស្តីរបស់ខ្លួនត្រូវបានយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជា ។ លោកមេធាវីបានលើកឡើងពីបទសម្ភាសន៍ខ្លីៗរបស់ ខៀវ សំផន នៅក្នុងឆ្នាំ២០០៦ ដែលនៅក្នុងបទសម្ភាសន៍នោះ ខៀវ សំផន បាននិយាយថា “ខ្ញុំមិនដែលនិយាយថាធ្វើស្រែបីតោនក្នុងមួយហិចតានោះទេ ខ្ញុំគ្រាន់តែដឹងថាស្រូវមួយតោនក្នុងមួយហិតតាមិនអាចផ្គត់ផ្គង់ប្រជាជនគ្រប់ឡើយ” ។ ឯកសារបន្ទាប់ គឺសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ទាក់ទងនឹងការអំពាវនាវឲ្យមានការធ្វើជាតូបនីយកម្មសេដ្ឋកិច្ចដើម្បីបង្កើនផលនាំចេញ ។ ឯកសារវីដេអូបន្ទាប់ទៀត គឺបង្ហាញអំពីភាពសប្បាយរីករាយរបស់ ខៀវ សំផន ចំពោះសមត្ថភាពរបស់ ប៉ុល ពត ក្នុងនាមជាមេដឹកនាំខ្មែរក្រហម ។ លោកមេធាវី បានអានឯកសារផ្សេងទៀតដែលនិយាយពីសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថ្លែងពីអំពើឃោរឃៅរបស់កម្មាភិបាលខ្មែរក្រហមនៅតំបន់រំដោះមុនឆ្នាំ១៩៧៥ និងវីដេអូមួយទៀតដែល ខៀវ សំផន បាននិយាយថា ខ្លួនដើរតាម ប៉ុល ពត ដូចជាស្រមោលដើម្បីរៀនសូត្រតាម ។ លោកមេធាវីបានបញ្ចប់ការលើកឡើងរបស់ខ្លួនដោយផ្ទេរវេទិកាទៅលោកមេធាវី សំ សុគង់ ដើម្បីធ្វើការបង្ហាញបន្តទៀត ។

លោក សុគង់ បានចាប់ផ្តើមអានឯកសារពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅក្នុងនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីបទពិសោធន៍របស់ខ្លួនក្នុងពេលជម្លៀស ការផ្តល់អាហារមិនគ្រប់គ្រាន់ ការបង្ខំឲ្យចូលធ្វើកងទ័ពក្នុងអំឡុងពេលសង្គ្រាមឆ្នាំ១៩៧០ដល់១៩៧៥ ។

## ៤) ការឆ្លើយតបរបស់មេធាវីការពារក្តី នួន ជា

លោកមេធាវី ផេស្តមេន បានចាប់ផ្តើមដោយលើកឡើងអំពីបណ្តឹងជំទាស់លើកទីបីដែលទាក់ទងនឹងលោកស្រីចៅក្រមខាតព្រ៉ាយ៍ ដោយអះអាងថា ក្រុមរបស់ខ្លួនមិនអាចធ្វើការកត់សម្គាល់អ្វីទាំងអស់លុះត្រាតែបញ្ហានេះត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះ ។ បន្ទាប់មក ខ្លួនក៏បានផ្ទេរវេទិកាបន្តទៅលោកមេធាវី ហ្សាស្កើ ប៉ោ ដើម្បីកត់សម្គាល់បន្ថែមទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្ត ។

លោក ហ្សាស្កើ ប៉ោ បានស្នើសុំដាក់ឯកសារបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងបរិបទមុនឆ្នាំ១៩៧៥ និងព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា ដោយខ្លួនយល់ថា ការពិភាក្សាលើបញ្ហានេះមានសារសំខាន់ដើម្បីឲ្យសាធារណជនបានដឹង ។ ភ្លាមៗនោះ លោកចៅក្រម និល ណុន បានបញ្ជាក់ថា អង្គជំនុំជម្រះបានសម្រេចលើបញ្ហានេះរួចហើយ ដោយបង្គាប់ឲ្យក្រុមមេធាវីធ្វើសំណើជាលាយលក្ខណ៍អក្សរ ម្យ៉ាងវិញទៀតអង្គជំនុំជម្រះក៏បានសម្រេចផ្អាកសវនាការនេះរួចហើយ ។

មុនពេលបញ្ចប់កិច្ចដំណើរការសវនាការ លោកប្រធានអង្គជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យភាគីធ្វើការដេញដោលទៅលើបញ្ជីឯកសារដែលពាក់ព័ន្ធសវនាការដំណាក់កាលទី២ នៅសវនាការថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ។

# សវនាការសំណុំរឿង០០២ ៖ ការដេញដោលបញ្ជីឯកសារភស្តុតាងសម្រាប់សវនាការដំណាក់កាលទី២

## ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

### សេចក្តីផ្តើម

*នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តសវនាការសួរដេញដោលអំពីបញ្ជីឯកសារភស្តុតាងដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងសម្រាប់សវនាការដំណាក់កាលទី២នៃសំណុំរឿង០០២ ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងាររបស់របបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការនេះ ធ្វើឡើងក្នុងគោលបំណងផ្តល់ឱកាសឲ្យជនជាប់ចោទ និងក្រុមមេធាវីការពាររបស់ជនជាប់ចោទលើកឡើងនូវការជំទាស់របស់ខ្លួនចំពោះឯកសារចំនួន៩៥ ដែលដាក់ជូនដោយសហព្រះរាជអាជ្ញាដើម្បីធ្វើជាឯកសារភស្តុតាង និងស្តាប់ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងការជំទាស់ទាំងអស់ដោយក្រុមមេធាវីការពារក្តី ។*

### ១) នួន ជា ស្នើសុំធ្វើសេចក្តីថ្លែងការណ៍

*នៅពេលចាប់ផ្តើមដំណើរការនីតិវិធីជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះឡើងធ្វើសេចក្តីថ្លែងការណ៍ និងធ្វើកំណត់សម្គាល់ទាក់ទងនឹងឯកសារដែលបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនាពេលកន្លងទៅ ។ ប្រធានអង្គជំនុំជម្រះលោកចៅ ក្រុម និល ណុន បានអនុញ្ញាតចំពោះសំណើសុំខាងលើ និងអនុញ្ញាត*



ទិដ្ឋភាពក្នុងបន្ទប់សវនាការ

ឲ្យជនជាប់ចោទអង្គុយអានសេចក្តីថ្លែងការណ៍របស់ខ្លួនពីកន្លែងអង្គុយតែម្តងដោយមិនចាំបាច់ឡើងមកអង្គុយនៅក្នុងរង្វង់ក្រចកសេះទេ ។ នួន ជា បានចំណាយពេលប្រមាណ២០នាទី ដើម្បីអានសេចក្តីថ្លែងការណ៍ ។ ខាងក្រោមនេះ គឺជាសេចក្តីថ្លែងការណ៍ទាំងស្រុងរបស់ជនជាប់ចោទ នួន ជា ។

"សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រមជាទីគោរព! ជាដំបូងខ្ញុំសូមគោរពលោកប្រធានថា ខ្ញុំពិតជាមានការលំបាកក្នុងការអានឯកសារទាំងអស់ឲ្យមានប្រសិទ្ធភាពណាស់ ដោយសារតែវ័យចាស់ជរារបស់ខ្ញុំ ។ ជាពិសេសគឺការផ្តង់អារម្មណ៍ក្នុងការអានឲ្យបានយល់ដឹងពេញលេញ ហើយការចងចាំរបស់ខ្ញុំក៏កាន់តែថមថយទៀត ។ ពិតមែនតែខ្ញុំមានក្រុមមេធាវីតំណាងក្នុងការជួយខ្ញុំក៏ដោយ ក៏ខ្ញុំគិតថា ខ្ញុំចាំបាច់ក្នុងការយល់ដឹងនូវរាល់ឯកសារភស្តុតាងដែលដាក់ដោយភាគី ក្នុងការចោទប្រកាន់របស់ខ្លួនលើរូបខ្ញុំដែរ ។

ដូចដែលមេធាវីរបស់ខ្ញុំបានលើកឡើងរួចមកហើយថា ដើម្បីឲ្យខ្ញុំឆ្លើយតបដោយមានប្រសិទ្ធភាពនោះ ខ្ញុំសូមស្នើឲ្យភាគីមេត្តាដាក់ជូននូវបញ្ជីឯកសារមកក្រុមយើងខ្ញុំឲ្យបានរយៈពេលវែង មុននឹងធ្វើការដេញដោលមកលើរូបខ្ញុំ ។ ខាងក្រោមនេះគឺជាការឆ្លើយតបរបស់ខ្ញុំចំពោះឯកសារដែលលើកឡើងដោយសហព្រះរាជអាជ្ញា ។

ដំបូង ខ្ញុំសូមលើកឡើងយ៉ាងខ្លីទាក់ទងនឹងឯកសារ IS9.1 ជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំសូមលើកឡើងជាការកត់សម្គាល់ជូនអង្គជំនុំជម្រះថា មាត្រាទី៧(១) បាននិយាយយ៉ាងច្បាស់នូវអង្គការដែលមានអំណាចខ្ពស់បំផុតដូចខាងក្រោម៖

"អង្គការរបស់បក្សមានសិទ្ធិអំណាចធំជាងគេ បំផុតសម្រាប់ទូទាំងប្រទេស គឺមហាសន្និបាតតំណាងទូទាំងប្រទេស" ។ ចប់ការដកស្រង់ ។ នេះជាឯកសារផ្លូវការរបស់បក្សតែមួយគត់ក្នុងការបញ្ជាក់ពីអង្គការលេខរបស់បក្ស ។

ដូចនេះការដែលរៀបរាប់ពីគណៈយោធាក្តី គណៈអចិន្ត្រៃយ៍ក្តី ដែលយកចេញពីបុគ្គលមួយចំនួននោះគឺមិនត្រឹមត្រូវទេ ។ ចំណែកបទសម្ភាសន៍ផ្សេងៗជាមួយរូបខ្ញុំ គឺជាការចាំបាច់ត្រូវតែស្តាប់ខ្សែអាត់ដែលបានថតនោះដើម្បីឲ្យដឹងថា ជាសម្តីរបស់ខ្ញុំមែនដែរឬទេ? ដោយឡែកចំពោះឯកសារ IS20.34 ព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារដើមជាភាសាអង់គ្លេស ។ នេះបញ្ជាក់ឲ្យឃើញថា បទសម្ភាសន៍នោះធ្វើឡើងជាភាសាអង់គ្លេស ។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំជាជាតិខ្មែរខំតស៊ូលះបង់ជីវិតសុខស្រួលគ្រប់បែបយ៉ាងគឺដើម្បីថែរក្សាជាតិឲ្យគង់វង្សនោះតើមានបំណងអ្វីក្នុងការនិយាយភាសាបរទេស ដែលមិនមែនជាភាសាកំណើតរបស់ខ្ញុំនោះ ។ និយាយឲ្យខ្លីទៅ ខ្ញុំមិនដែលផ្តល់បទសម្ភាសន៍ជាភាសាអង់គ្លេសទេ ។ ខ្ញុំគិតថា ខ្ញុំមិនបានផ្តល់ការសម្ភាសបែបនេះទេ ហើយប្រសិនបើមានមែន តាមការពិនិត្យឈ្មោះដែលសម្ភាសខ្ញុំគឺជាជនជាតិខ្មែរ ។ ដូចនេះច្បាប់ដើមត្រូវតែជាភាសាខ្មែរ ។ ក្នុងចំណោមអ្នកសម្ភាសន៍នោះ មានលោក អៀ ម៉េងទ្រី ដែលបានសរសេរសៀវភៅពីរក្បាល ដែលមានចេតនាអាក្រក់មកលើរូបខ្ញុំមកលើរបបកម្ពុជាប្រជាធិបតេយ្យ ហើយកាន់តែអាក្រក់ទៅទៀតនោះ គឺគាត់មានគ្រាមួយនោះបានបម្រើការងារសម្រាប់ការិយាល័យសហព្រះរាជអាជ្ញា ដែលជាការិយាល័យធ្វើការសម្រាប់តែការដាក់បន្ទុកមកលើរូបខ្ញុំតែប៉ុណ្ណោះ ។

ចំពោះឯកសារដែលនៅសល់ ឬក៏រួមទាំងទស្សនាវដ្តីទង់បដិវត្តផងដែរនោះ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំពិតជាមិនអាចធ្វើអត្ថាធិប្បាយ និងឆ្លើយតបដោយមានប្រសិទ្ធភាពនោះបានទេដរាបណាយថាភាពរបស់វាមិនទាន់ត្រូវបានសម្រេចគិតគូរនៅឡើយនោះ ។ សំណើរបស់ខ្ញុំលើបញ្ហានេះគឺងាយស្រួលទេ ដោយសារក្រោយពីស្តាប់សក្ខីកម្មសាក្សីពីររូបមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយជាពិសេសលោក ឆាំង យុ ដែលមានបំណងល្អក្នុងការសហការជាមួយតុលាការក្នុងការផ្ទៀងផ្ទាត់ពិនិត្យពិច័យជាមួយឯកសារដើមដែលគាត់អះអាងថា កំពុងតែរក្សាទុកនៅមជ្ឈមណ្ឌលឯកសាររបស់លោកនោះ ។

ខ្ញុំសូមទទូចស្នើដល់តុលាការថា គ្រប់ឯកសារដែលផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានដាក់ ហើយនឹងត្រូវបានដាក់នៅពេលខាងមុខក្នុងការចោទប្រកាន់មកលើរូបខ្ញុំដោយភាគីនានា គឺចាំបាច់ត្រូវតែយកឯកសារដើមមកផ្ទៀងផ្ទាត់ ពិនិត្យពិច័យពីយថាភាពរបស់វាក្នុងតុលាការនេះជាមុនសិន ។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាវាជាសំណើធំពេកនោះ ខ្ញុំសូមឲ្យ

មានការផ្ទៀងផ្ទាត់ពិនិត្យពិច័យជាមួយឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះសិនចុះ ។

ជាការពិត សហព្រះរាជអាជ្ញាគាត់មានអំណាចក្នុងការស៊ើបអង្កេតបឋមក្នុងការដាក់បន្ទុកមកលើរូបខ្ញុំ ។ ផ្ទុយពីភាគីខ្ញុំដែលពឹងផ្អែកលើការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានភាពលម្អៀង និងមិនគួរឲ្យទុកចិត្តបាន ។ បើគិតៗទៅការិយាល័យមួយនេះដើរតួសឹងតែដូចគ្នានឹងការិយាល័យសហព្រះរាជអាជ្ញាដែរ ។

លោកស្រីចៅក្រមនិងអង្គសវនាការ ប្រហែលជាបានដឹងហើយអំពីសេចក្តីថ្លែងការណ៍របស់អតីតមន្ត្រីជាន់ខ្ពស់របស់ការិយាល័យនេះអំពីការលម្អៀងក្នុងការស៊ើបអង្កេត ។ ដូចនេះខ្ញុំមិនចាំបាច់លើកឡើងទៀតទេ ។

អាស្រ័យហេតុនេះ វាគ្មានមន្ទិលសង្ស័យទេដែលថាឯកសារដែលសហព្រះរាជអាជ្ញាទទួលមក គឺគាត់ប្រកាសថាជាឯកសារត្រឹមត្រូវពិតប្រាកដ តាមច្បាប់ដើមសម្រាប់តែខ្លួនឯង ហើយខ្ញុំគិតថាភាគីផ្សេងទៀត រួមទាំងអង្គជំនុំជម្រះផង ប្រហែលជាមិនដែលបានឃើញឯកសារដើមដែរ ។

ខ្ញុំយល់ឃើញថា មានតែអង្គជំនុំជម្រះទេដែលមានអំណាចសមស្របបំផុតក្នុងការផ្តល់ជូនខ្ញុំនូវសំណើនេះ ដើម្បីបម្រើដល់ដំណើរការនីតិវិធីមួយដែលបម្រើដល់ការពិតមានប្រយោជន៍ និងយុត្តិធម៌សម្រាប់គ្រប់ភាគីទាំងអស់ ។

ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងពិចារណាលើសំណើដែលសមស្របរបស់ខ្ញុំនេះ គឺដើម្បីផ្តល់លទ្ធភាពឲ្យខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងការស្វែងរកការពិតជូនប្រជាជាតិទាំងមូល ។ ខ្ញុំគិតថានេះជាសំណើស្របច្បាប់ និងសមស្របបំផុត និងពុំមានឧបសគ្គអ្វីមករារាំងនោះទេ បើយើងពិចារណាទៅ គោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ ។

ខ្ញុំក៏សូមជូនជាការកត់សម្គាល់សម្រាប់អង្គជំនុំជម្រះថា ខ្ញុំជឿជាក់ថា តាមច្បាប់កម្ពុជាគឺខ្ញុំមានសិទ្ធិដាក់ឯកសារភស្តុតាងថ្មីៗបានគ្រប់ពេលរហូតដល់ចប់ដំណើរការក្តី ។ ដូចនេះខ្ញុំសង្ឃឹមថាអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យខ្ញុំអនុវត្តសិទ្ធិនេះដោយមានប្រសិទ្ធភាពតាមច្បាប់កំណត់ ។

រឿងមួយវិញទៀតនោះ ខ្ញុំយល់ឃើញថា សាក្សីដែលឡើងមកផ្តល់សក្ខីកម្មកន្លងមកនេះ គឺមិនគ្រប់គ្រាន់ទេក្នុងការបញ្ជាក់អំពីប្រវត្តិបក្សនៅមុនឆ្នាំ១៩៧៥ ។ ដោយសារតែសាក្សីទាំងនោះគឺជាសាក្សីដែលភាគច្រើនស្នើដោយសហព្រះរាជអាជ្ញា ហើយតាមការអង្កេត គាត់ដូចជាមិនបានបង្ហាញការសហការជាដុំកំភួនអីទេ ។ ចំណែកឯសាក្សីដែលស្នើដោយខ្ញុំ ដើម្បីឲ្យចូលមកផ្តល់សក្ខីកម្មពីបរិបទនេះ ដូចជាមិនទាន់ចូលខ្លួនសោះ ។ ហើយចំណែកឯអ្នកជំនាញវិញ គឺមិនទាន់មានអ្នកណាម្នាក់អាចមកចូលខ្លួនបានឡើយ ។

ដូច្នេះបញ្ហាក្នុងបរិបទនេះនៅមានច្រើន និងមិនជ្រះស្រឡះសម្រាប់ប្រជាជាតិទាំងមូលក្នុងការយល់ដឹងឲ្យស៊ីជម្រៅចំពោះរឿងរ៉ាវដែលបានកើតឡើងនោះទេ ។ ម៉្យាងវិញទៀតបើតាមការកំណត់ដំណាក់កាលនៃការជំនុំជម្រះ ខ្ញុំគិតថា នេះប្រហែលជាឱកាសចុងក្រោយរបស់ខ្ញុំក្នុងការដេញដោលក្នុងបរិបទនៅមុនឆ្នាំ១៩៧៥ដែលជាបច្ច័យរបស់រឿងរ៉ាវ និយាយឲ្យចំទៅ គឺក្បាលក្រពើនោះឯង ។

តើគោលនយោបាយឈ្លានពាន ទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដ៏ប្រល័យមកលើប្រជាជនកម្ពុជាមិនមានអ្វីដែលគួរឲ្យយើងពិភាក្សាមែនទេឬ? ហើយតើមូលហេតុអ្វីបានជាឯកសារដែលទាក់ទងនឹងការទម្លាក់គ្រាប់បែក និងមហិច្ឆតាលោកលន់ បំបាត់ពូជសាសន៍ លេបទឹកដីរបស់ប្រទេសជិតខាងតែងតែត្រូវបានរារាំង ។ បញ្ហានោះមើលទៅឃើញយ៉ាងសាមញ្ញបំផុតគឺភាគីខាងព្រះរាជអាជ្ញាចង់បានប្រវត្តិសាស្ត្រដែលមិនពេញលេញមួយតែប៉ុណ្ណោះ ។ តែខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហាទាំងនេះប្រកបដោយតស្សូរយស ។

ជាថ្មីម្តងទៀត ខ្ញុំសូមឲ្យអង្គជនុំជម្រះមេត្តាសម្រេចតាមសំណើរបស់ខ្ញុំនេះដើម្បីផ្តល់ដល់រូបខ្ញុំនូវឱកាសមួយដែលអាចឲ្យខ្ញុំមានទំនុកចិត្តខ្លះៗលើអង្គជំនុំជម្រះក្នុងការស្វែងរកការពិតមានប្រយោជន៍និងយុត្តិធម៌សម្រាប់ភាគីទាំងអស់ ។ សូមអរគុណ ។

គួរកត់សម្គាល់ថាជនជាប់ចោទ នួន ជា ធ្លាប់បានលើកឡើងពីបរិបទប្រវត្តិសាស្ត្រមុនឆ្នាំ១៩៧៥ ដែលខ្លួនចាត់ទុកថាជា បរិបទក្បាលក្រពើ ក្នុងសវនាការលើអង្គសេចក្តីនៅថ្ងៃទី២២ ខែវិច្ឆកា ឆ្នាំ២០១១ ម្តងរួចមកហើយ ។ ដោយអះអាងថានៅពេលនោះថា

តុលាការនេះមិនមានភាពយុត្តិធម៌សម្រាប់ខ្លួនឡើយ ព្រោះលើកយកតែហេតុការណ៍ដែលបានកើតឡើងក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ប៉ុណ្ណោះ ដោយមិនព្រមពិភាក្សាអំពីប្រវត្តិ និងបច្ច័យដែលបានកើតឡើងមុន និងក្រោយរយៈពេលនេះទេ និងបានបន្ថែមទៀតថា *"ក្រពើមួយទាំងមូលគេយកតែខ្លួនមកនិយាយដោយមិនបានពិភាក្សាអំពីក្បាល និងកន្ទុយដែលជាផ្នែកបម្រើដល់សកម្មភាពប្រចាំថ្ងៃរបស់វាឡើយ"* ។

បន្ទាប់ពីការបញ្ចប់សេចក្តីថ្លែងរបស់ជនជាប់ចោទ នួន ជា ជនជាប់ចោទ អៀង សារី និង ខៀវ សំផន មិនបានធ្វើការកត់សម្គាល់ ឬធ្វើសេចក្តីថ្លែងការណ៍ណាមួយនៅក្នុងសវនាការទេ ។

## ២) ការជំទាស់របស់ក្រុមមេធាវីការពារក្តី

បន្ទាប់ពីការធ្វើសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីឡើងបង្ហាញពីការជំទាស់របស់ខ្លួនទៅនឹងឯកសារចំនួន៩៥ ដែលមាននៅក្នុងបញ្ជីឯកសារភស្តុតាងទាក់ទងនឹងសវនាការដំណាក់កាលទី២ ។ ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ត្រូវបានផ្តល់ឱកាសឲ្យលើកឡើងនូវការជំទាស់មុនដំបូងគេ បន្ទាប់មកបន្តទៅក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី និងចុងក្រោយគឺត្រូវផ្តល់ទៅក្រុមមេធាវីការពារក្តី ខៀវ សំផន ។

### ក) ក្រុមមេធាវីការពារក្តី នួន ជា

នៅមុនពេលចាប់ផ្តើម លោកប្រធានអង្គជំនុំជម្រះបានជូនដំណឹងទៅក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ឲ្យលើកឡើងនូវការជំទាស់ដែលស្ថិតនៅក្នុងវង្វង់នៃអង្គហេតុទាក់ទងនឹងសវនាការនៅដំណាក់កាលទី២តែប៉ុណ្ណោះ និងមិនអនុញ្ញាតឲ្យក្រុមមេធាវីឆ្លៀតយកឱកាសនេះលើកឡើងពីបញ្ហាផ្សេងក្រៅពីការកំណត់របស់អង្គជំនុំជម្រះឡើយ ។ នៅពេលចាប់ផ្តើម មេធាវីអន្តរជាតិរបស់ នួន ជា គឺលោក ហ្សាស្តេ ប៉ៅ បានព្យាយាមលើកឡើងពីការដាក់ឯកសារបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែការលើកឡើងនេះត្រូវបានបដិសេធដោយប្រធានអង្គជំនុំជម្រះ ។ បន្ទាប់មកលោកមេធាវី ហ្សាស្តេ ក៏បានប្រគល់វេទិកាឲ្យសមាជិកក្រុមរបស់ខ្លួនម្នាក់ទៀត គឺលោកមេធាវី អេនឌ្រូ អ៊ីនូហ៊្វ ។ លោកមេធាវី អ៊ីនូហ៊្វ បានលើកឡើងពីសេចក្តីថ្លែងដែលធ្វើឡើងរបស់លោក មាស មុត អតីតមេបញ្ជាការកងទ័ពជើងទឹករបស់ខ្មែរក្រហមដែលត្រូវបានគេស្គាល់ថា ជាជនសង្ស័យនៅក្នុងសំណុំរឿង០០៣ ។ ភ្លាមៗនោះ តំណាងសហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងការលើកឡើងនេះ ។ ប៉ុន្តែលោកមេធាវីបានអះអាងថា សេចក្តីថ្លែងរបស់ មាស មុត គឺស្ថិតនៅក្នុងបញ្ជីឯកសារដែលខ្លួនទទួលបានពីអង្គជំនុំជម្រះដែលបានប្រគល់ឲ្យខ្លួននាពេលកន្លងមក ។ ទាក់ទងនឹងបញ្ហានេះហាក់ បីដូចជាមានការយល់ច្រឡំគ្នារវាងក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញាទាក់ទងនឹងបញ្ជីឯកសារដែលអង្គជំនុំជម្រះបានផ្តល់ជូន ។ ដើម្បីដោះស្រាយបញ្ហានេះ អង្គជំនុំជម្រះបានប្រកាសផ្អាកដំណើរការនីតិវិធីរយៈពេល៤០នាទី ដើម្បីធ្វើការពិភាក្សា ។ បន្ទាប់ពីការពិភាក្សា លោកប្រធានអង្គជំនុំជម្រះបានប្រគល់វេទិការទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវើញ ដើម្បីធ្វើការពន្យល់ពីបញ្ហាដែលភាគីបានលើកឡើង ។ លោកចៅក្រម ឡាវើញ បានបញ្ជាក់ថាបញ្ជីឯកសារដែលនឹងត្រូវប្រើនៅក្នុងសវនាការគឺបញ្ជីដែលមានឯកសារចំនួន៩៥ ដែលអង្គជំនុំជម្រះបានផ្តល់ជូនភាគីនាពេលកន្លងទៅ ។ លោកចៅក្រមក៏បានស្នើឲ្យភាគីលើកឡើងតែពីអ្វីដែលអង្គជំនុំជម្រះអនុញ្ញាត និងកំហិតឲ្យភាគីអាចលើកឡើងតែពីបញ្ហាយថាភាពនិងភាពអាចជឿជាក់បាននៃឯកសារដែលមាននៅក្នុងបញ្ជីឯកសារទាំងនោះតែប៉ុណ្ណោះ ។ បន្ទាប់មកលោកចៅក្រមក៏បានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីដើម្បីបន្តការជំទាស់របស់ខ្លួន ។

លោកមេធាវីការពារក្តី អ៊ីនូហ៊្វ បានបង្ហាញពីការជំទាស់របស់ខ្លួនចំពោះឯកសារជាក់លាក់ចំនួន៦ ដែលនៅក្នុងនោះមានដូចជា ១) ឯកសារចម្លើយរបស់លោក មាស មុត ដែលជាមេបញ្ជាការកងទ័ពជើងទឹក ២) លិខិតឆ្លើយតបរបស់លោក ស្ទីវ ហេដឌើ ទាក់ទងនឹងលោក អ៊ុក ប៊ុនឈឿន និងលោក ស៊ុម កា ៣) ប្រតិចារិកនៃបទសម្ភាសន៍ដែលធ្វើឡើងដោយលោក ស្ទីវ ហេដឌើ ជាមួយនឹងលោក អ៊ុកប៊ុនឈឿន ៤) អត្ថបទបកប្រែជាភាសាអង់គ្លេសដែលសរសេរដោយដៃទាក់ទងនឹងបទសម្ភាសន៍ធ្វើឡើងដោយលោក ប៉ែន ឃៀរនិន ជាមួយនឹងលោក អ៊ុក ប៊ុនឈឿន ៥) ប្រភេទនៃអត្ថបទដែលដូចគ្នានឹងបទសម្ភាសន៍ធ្វើឡើងជាមួយនឹងលោក

អ៊ុក ប៊ុនឈឿន និងទី៦) អត្ថបទសម្ភាសន៍ ដែលធ្វើឡើងជាមួយ លោក ជា ស៊ីម និង លោក ហេង សំរិនពីខែធ្នូ ឆ្នាំ១៩៩១ ។

លោកមេធាវីអ៊ីទូហ្ស៊ី បានបញ្ជាក់ថាការដែលខ្លួនជំទាស់ទៅនឹងឯកសារទាំងអស់នេះគឺដោយសារតែមិនមាននរណាម្នាក់ក្នុងចំណោមអ្នកដែលផ្តល់បទសម្ភាសន៍ទាំងអស់នេះត្រូវបានកោះហៅមកធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ។ មេធាវីបានកត់សម្គាល់ថា បុគ្គលចំនួនប្រាំរូប ក្នុងចំណោមបុគ្គលទាំងអស់ខាងលើ បានធ្វើព្រងើយកន្តើយចំពោះដីកាកោះរបស់អង្គជំនុំជម្រះឲ្យចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ លើកលែងតែលោកមាសមុតម្នាក់គត់ដែលទទួលដីកាកោះឲ្យចូលខ្លួន ។ លោកមេធាវីបានបន្ថែមថាក្រុមមេធាវីការពារ នួន ជា នឹងដាក់ជូនពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះទាក់ទងនឹងការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លើសារព័ត៌មានរបស់ប្រទេសវៀតណាមថាកូនក្តីរបស់ខ្លួន គឺជា "ឃាតករ និងជាចារីនៃបទប្រល័យពូជសាសន៍" ។ ប៉ុន្តែការលើកឡើងនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះ និល ណុល បានច្រានចោល ដោយអះអាងថា អង្គជំនុំជម្រះបានសម្រេចលើបញ្ហានេះរួចហើយ និងណែនាំឲ្យលោកមេធាវីមើលលើសេចក្តីសម្រេចនោះសារជាថ្មីម្តងទៀត ។

លោកមេធាវី អ៊ីទូហ្ស៊ី បានស្នើឲ្យអង្គជំនុំជម្រះពិចារណាពីលទ្ធភាពក្នុងការកោះហៅលោក ហេនរី ឃីស៊ីងជឺរ (Henry Kissinger) ដែលជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៣ រហូតដល់ខែមករា ឆ្នាំ១៩៧៧ ចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខសវនាការ ។ លោកមេធាវីបានផ្តល់ហេតុផលថា ដោយសារតែរយៈពេលប៉ុន្មានខែខាងមុខ លោក ឃីស៊ីងជឺរ នឹងធ្វើដំណើរទស្សនកិច្ចមកក្នុងតំបន់នេះ ។ ប៉ុន្តែសំណើនេះត្រូវបានអង្គជំនុំជម្រះបដិសេធ ដោយហេតុថាការលើកឡើងរបស់លោកមេធាវីពុំមានជាប់ទាក់ទងនឹងគោលបំណងរបស់សវនាការដែលអង្គជំនុំជម្រះបានកំណត់ ។

### ខ) ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិការពារក្តី អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស បានធ្វើការជំទាស់នឹងឯកសារមួយចំនួនក្នុងចំណោមឯកសារទាំង៩៥ នៃបញ្ជីឯកសារដែលអង្គជំនុំជម្រះដាក់ឲ្យធ្វើការដេញដោល ។ លោក មេធាវី ខាណាវ៉ាស បានលើកឡើងថា អង្គជំនុំ



ជម្រះគប្បីត្រូវកោះហៅអ្នកសរសេរអត្ថបទមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ប្រសិនបើអត្ថបទរបស់អ្នកទាំងនោះត្រូវបានប្រើប្រាស់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ មេធាវីបានជំទាស់នឹងរាល់ឯកសារទាំងឡាយរបស់លោក ស៊ីវ ហេងឌើ ដោយសារតែលោកស៊ីវធ្លាប់ធ្វើការជាអ្នកចោទប្រកាន់មកលើកូនក្តីរបស់ខ្លួននៅការិយាល័យសហព្រះរាជអាជ្ញា មុននឹងផ្លាស់ទៅបំពេញភារកិច្ចនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ម្យ៉ាងវិញទៀត មានឯកសារខ្លះក្នុងចំណោមឯកសារដែលធ្វើដោយលោក ស៊ីវ មានបញ្ហាក្នុងការបកប្រែ ដែលឯកសារទាំងនោះធ្លាប់ត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន កាលពីពេលមុនរួចហើយ ។ លោកមេធាវីខាណាវ៉ាស ក៏បានធ្វើការជំទាស់នឹងការប្រើប្រាស់ឯកសារទាក់ទងនឹងសំណុំរឿង០០១ និងការធ្វើសេចក្តីថ្លែងការណ៍របស់ ឌុច នៅអំឡុងពេលសវនាការ ដោយសារតែចម្លើយទាំងអស់របស់ ឌុច គឺគ្រាន់តែជាការសារភាពដើម្បីទទួលបានការសម្រាលទោសតែប៉ុណ្ណោះ ។ លោកមេធាវីបានបញ្ជាក់ថាប្រសិនបើអង្គជំនុំជម្រះនឹងយកឯកសារទាក់ទងនឹងសំណុំរឿង០០១មកប្រើប្រាស់នៅក្នុងសំណុំរឿង០០២ តុលាការត្រូវតែកោះហៅ ឌុច មកស្បថដើម្បីធ្វើជាសាក្សីដើម្បីធ្វើការសួរដេញដោលនៅក្នុងសវនាការ ។ លោកបានលើកឡើងការមិនយល់ស្របក្នុងការប្រើប្រាស់ឯកសារចម្លើយសារភាពរបស់ជនរងគ្រោះនៅគុកទួលស្លែង ដែលធ្វើឡើងដោយមានទារុណកម្ម និងថាអង្គជំនុំជម្រះត្រូវតែប្រើប្រាស់ឯកសារទាំងនោះដោយប្រុងប្រយ័ត្ន ។ បន្ទាប់មក លោកមេធាវីក៏បានធ្វើការជំទាស់នឹងការប្រើប្រាស់ឯកសារបទសម្ភាសន៍ជាមួយសាក្សីដែលមិនត្រូវបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ព្រោះបុគ្គលដែលធ្វើការសម្ភាសន៍ជាមួយសាក្សីដែលមិនមែនជាបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតគឺមិនមានគុណសម្បត្តិគ្រប់គ្រាន់ជាអ្នកស៊ើបអង្កេតឡើយ ។ ប៉ុន្តែប្រសិនបើ អង្គជំនុំជម្រះប្រើប្រាស់បទសម្ភាសន៍សាក្សីដែលធ្វើឡើងដោយបុគ្គលដែលមិនមែនជាបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះត្រូវតែកោះហៅបុគ្គលទាំងនោះមកសាកសួរដេញដោលនៅក្នុងសវនាការ ។ លោកមេធាវី ខាណាវ៉ាស បានជំទាស់ទាក់ទងនឹងប្រភេទឯកសារដែលជាសេវាផ្សព្វផ្សាយព័ត៌មានបរទេស ដោយសារតែឯកសារទាំងនោះគឺធ្វើឡើងដោយទីភ្នាក់ងារស៊ើបការណ៍សហព័ន្ធរបស់សហរដ្ឋអាមេរិក ដែលហៅកាត់ថា សេ.អ៊ី.អា ។ ចំពោះការប្រើប្រាស់ឯកសារទស្សនាវដ្តីទង់បដិវត្ត ក្រុមមេធាវីការពារ អៀង សារី មិនជំទាស់នឹងការប្រើប្រាស់ឯកសារថតចម្លងនោះទេ ប៉ុន្តែលោកគ្រាន់តែស្នើសុំឲ្យតុលាការធ្វើការផ្ទៀងផ្ទាត់បរិបទនៃឯកសារនោះជាមួយនឹងភ័ស្តុតាងដទៃទៀតឲ្យបានច្បាស់លាស់ ។

លោកមេធាវីបានបន្តធ្វើការជំទាស់នឹងឯកសារមួយចំនួនផ្សេងទៀត ដូចជាឯកសារសរសេរដោយដៃជាភាសាអាល្លឺម៉ង់, ឯកសារកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា, ឯកសារសុន្ទរកថានៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ, ឯកសារសេចក្តីថ្លែងការណ៍ផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបាយការណ៍ដែលធ្វើឡើងដោយរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន


អ្នកភូមិដើរចូលបន្ទប់សវនាការ

បរទេស ។ ជាចុងក្រោយលោកមេធាវីបានលើកឡើងថា ឯកសារទាំងអស់ខាងលើភាគច្រើនគ្រាន់តែជាពាក្យចចាមអារ៉ាម និងចាំបាច់ត្រូវតែមានការផ្ទៀងផ្ទាត់ដោយឯករាជ្យ មុនពេលដែលអង្គជំនុំជម្រះយកឯកសារទាំងនោះមកប្រើប្រាស់ ។

**គ) ក្រុមមេធាវីការពារក្តី ខៀវ សំផន**

ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាឲ្យឡើងបង្ហាញពីការជំទាស់នឹងឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះចំនួនទាំង៩៥ ។ មេធាវីជាតិការពារក្តីឲ្យ ខៀវ សំផន គឺលោក គង់ សំអុន បានធ្វើការបង្ហាញពីឯកសារដាក់លាក់ដែលលោកជំទាស់ ដោយបានលើកឡើងនូវឈ្មោះឯកសារ និងបញ្ជាក់ពីហេតុផលដែលនាំឲ្យមានការជំទាស់ ។ លោកមេធាវីបានលើកឡើងពីអ្នកធ្វើបទសម្ភាសន៍ដែលអង្គជំនុំជម្រះបានប្រើប្រាស់អត្ថបទសម្ភាសន៍របស់អ្នកទាំងនោះមកធ្វើជាឯកសារភស្តុតាង ។ លោកមេធាវីបានស្នើឲ្យអង្គជំនុំជម្រះកោះហៅអ្នកដែលបានធ្វើសម្ភាសន៍ទាំងនោះមកសវនាការដើម្បីតទល់ជាមួយនឹងកូនក្តីរបស់ខ្លួនដើម្បីបញ្ជាក់ពីភាពគួរឲ្យទុកចិត្តបាននៃឯកសារ និងដើម្បីជាការធានាថា បរិបទនៃឯកសារទាំង



សិស្សានុសិស្សតម្រង់ជួរចូលបន្ទប់សវនាការ



អ្នកភូមិចូលរួមសវនាការ

បង្ហាញពីភាពមិនយល់ស្របនឹងការទទួលយកឯកសារជាច្រើនពីសំណាក់សហព្រះរាជអាជ្ញាដោយអង្គជំនុំជម្រះ ។ លោកមេធាវីបានលើកឡើងថា អង្គជំនុំជម្រះបានទទួលយកឯកសារជាច្រើនដោយមិនត្រឹមត្រូវ ហើយភាគច្រើននៃឯកសារទាំងអស់នោះគឺមិនមានមូលដ្ឋានគ្រប់គ្រាន់ និងមិនមានតម្លៃគួរឲ្យជឿជាក់បាន ។ លោកបានលើកឡើងថាដំណើរការនៃការប្រមូលចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពលម្អៀង គឺស្វែងរកតែឯកសារដើម្បីដាក់បន្ទុកមកលើកូនក្តីរបស់ខ្លួន ដូច្នេះលោកសុំធ្វើការជំទាស់នឹងរាល់ឯកសារទាំងឡាយដែលទទួលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកមេធាវី គង់ សំអុន បានធ្វើការ... 

នោះ គឺធ្វើឡើងដោយមានការពិនិត្យពិច័យឲ្យបាន ត្រឹមត្រូវ ។

**៣) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅក្រុមមេធាវីការពារក្តី**

តំណាងសហព្រះរាជអាជ្ញាជាតិ លោក សេង ប៊ុនឃាង បានឆ្លើយតបទៅក្រុមមេធាវីការពារក្តីទាំងបីក្រុម ដោយព្យាយាមបញ្ជាក់ពីភាពគួរឲ្យជឿជាក់បាន និងភាពត្រឹមត្រូវនៃឯកសារ ។ ប៉ុន្តែលោកតំណាងសហព្រះរាជអាជ្ញា ហាក់បីដូចជាពុំបានឆ្លើយតបចំៗទៅនឹងឯកសារជាក់លាក់ដែលក្រុមមេធាវីការពារទាំងបីក្រុមបានលើកឡើងនៅអំឡុងពេលសវនាការឡើយ ។ នៅពេលចាប់ផ្តើមលោកតំណាងសហព្រះរាជអាជ្ញា ប៊ុនឃាង បានលើកយករចនា

សម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើការបង្ហាញ ដោយយោងលើសក្ខីកម្មរបស់សាក្សីដែលធ្លាប់បានធ្វើកាលពីសវនាការនាពេលកន្លងទៅ ។ ប៉ុន្តែភ្លាមៗនោះមេធាវីការពារក្តីអន្តរជាតិខណារ៉ាវ៉ាស បានងើបឈរឡើងជំទាស់ដោយអះអាងថា ការឆ្លើយតបរបស់លោកតំណាងសហព្រះរាជអាជ្ញាជាតិ គឺស្ថិតនៅក្រៅវង្វង់នៃឯកសារទាំង៩៥ដែលកំពុងដាក់ឲ្យសួរដេញដោលនៅចំពោះអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះបានយល់ស្របនឹងការជំទាស់របស់លោកមេធាវីខណារ៉ាវ៉ាស និងបានស្នើឲ្យតំណាងសហព្រះរាជអាជ្ញាជាតិ កំហិតការលើកឡើងរបស់ខ្លួនមកត្រឹមតែអង្គហេតុវត្តមានអ្នកធ្វើសម្ភាសន៍នៅចំពោះមុខអង្គជំនុំជម្រះទេ ។ លោកស្រីបានលើកឡើងទាក់ទងនឹងឯកសារពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ និងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាដែលពិពណ៌នាពីការចាប់ខ្លួនរបស់ ហ៊ូ នឹម ហើយបន្ទាប់មកបញ្ជូនទៅធ្វើទារុណកម្ម និងសម្លាប់នៅគុកទួលស្លែង ។ លោកស្រីបានអះអាងថា ឯកសារទាំងអស់នោះគឺជាឯកសារត្រឹមត្រូវ និងគួរឲ្យជឿជាក់បាន ដោយលោកស្រីបង្ហាញពីការវិភាគចម្លើយសារភាពដែលត្រូវបានសរសេរដោយកម្មាភិបាលមួយរូបនៃមន្ទីរសន្តិសុខស-២១ ដែលមានឈ្មោះថា ប៉ន ។ ទាក់ទងនឹងឯកសារដែលទទួល





អ្នកភូមិចាកចេញពីបន្ទប់សវនាការ

ដែលពាក់ព័ន្ធនឹងឯកសារទាំង៩៥ដែលមាននៅក្នុងបញ្ជីឯកសារ ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាជាតិបន្តបង្ហាញពីភាពត្រឹមត្រូវនៃខ្សែភាពយន្តវីដេអូ ដោយអះអាងថា ខ្សែភាពយន្តនីមួយៗសុទ្ធតែបានបង្ហាញពីព័ត៌មានសំខាន់និងអាចគួរឲ្យជឿជាក់បាន ។ រីឯតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោកស្រី ហ្វាល់ហ្គុនី ដេបណាត (Falguni DEBNAT) ឆ្លើយតបនឹងក្រុមមេធាវីការពារក្តីទាំងបីក្រុម ។ លោកស្រី ហ្វាល់ហ្គុនី ដេបណាត បានអះអាងថា សំណើនេះ គឺលើសពីអ្វីដែលចាំបាច់ ព្រោះការទទួលយកឯកសារបទសម្ភាសន៍មួយមិនចាំបាច់ទាល់តែមានបានពីលោក ស៊ីវ ហេដឌ័រ លោកស្រីបានអះអាងថា គឺមានភាពសមស្របអាចទទួលយកបានដោយសារតែលោក ស៊ីវ ហេដឌ័របានចាកចេញពីការិយាល័យសហព្រះរាជអាជ្ញាទៅការិយាល័យសហចៅក្រមស៊ើបអង្កេត មុនពេលដែលការិយាល័យសហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានចោទប្រកាន់ ។ ហេតុនេះ លោកមិនមានពេលគ្រប់គ្រាន់ដើម្បីធ្វើសេចក្តីព្រាងសន្និដ្ឋានចោទប្រកាន់ឡើយ ។ លោកស្រីបានលើកឡើងថា រាល់ឯកសារទាំងឡាយដែលក្រុមមេធាវីការពារក្តីបានជំទាស់គឺសុទ្ធតែជាឯកសារដែលត្រឹមត្រូវ និងគួរឲ្យជឿទុកចិត្តបាន ហេតុនេះអង្គជំនុំជម្រះគួរតែប្រាន

បោលការជំទាស់របស់ក្រុមមេធាវីការពារក្តី ។

**៤) ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅក្រុមមេធាវីការពារក្តី**

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត បានអះអាងថាក្រុមមេធាវីការពារក្តីបានច្រានចោលឯកសារទាំងឡាយដែលធ្លាប់ត្រូវបានពិនិត្យពិច័យយ៉ាងយកចិត្តទុកដាក់ដោយចៅក្រមដែលមានវិជ្ជាជីវៈត្រឹមត្រូវ ។ ហេតុនេះឯកសារទាំងនោះគួរតែត្រូវបានសន្មតថាអាចទទួលយកបាន ។ លោកស្រីមេធាវីក៏បានកត់សម្គាល់ដែរថាការជំទាស់របស់ក្រុមមេធាវីការពារក្តីក្នុងសវនាការនាពេលនេះគឺធ្លាប់បានលើកឡើងជាច្រើនដងរួចមកហើយក្នុងសវនាការលើកមុន ហើយអង្គជំនុំជម្រះធ្លាប់បានដោះស្រាយទាំងអស់នោះរួចហើយ ។ មុនពេលបញ្ចប់ លោកស្រីមេធាវីបានផ្តល់យោបល់ថា អង្គជំនុំជម្រះគួរតែអនុវត្តន៍នូវអនុសញ្ញាស្តីពីការប្រឆាំងនឹងអំពើទារុណកម្មឲ្យបានមឹងម៉ាត់ ដើម្បីធានាថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមិនធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តអនុសញ្ញានេះ ។ មុនបញ្ចប់កិច្ចដំណើរការនីតិវិធី ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះមួយនាទីដើម្បីធ្វើការឆ្លើយតបនឹងសហព្រះរាជអាជ្ញា និងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សំណើនេះត្រូវបានអង្គជំនុំជម្រះអនុញ្ញាត ។ លោកមេធាវី អ៊ីនូហ្ស៊ី បានលើកឡើងថាក្រុមមេធាវីការពារក្តី នួន ជា គ្រាន់តែជំទាស់នឹងការប្រើប្រាស់សេចក្តីថ្លែងដែលបន្ទាញពីសកម្មភាព ឬការប្រព្រឹត្តរបស់ជនជាប់ចោទ ឬបញ្ហាការសម្ងាត់ដែលមាននៅក្នុងសំណុំរឿងដោយមិនមានការសួរដេញដោលបុគ្គលដែលជាអ្នកសរសេរអត្ថបទទាំងនោះតែប៉ុណ្ណោះ ។ មុនពេលប្រកាសផ្អាកកិច្ចដំណើរការនីតិវិធី លោកប្រធានអង្គជំនុំជម្រះ និល ណុន បានជូនដំណឹង ដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងផ្អាកកិច្ចដំណើរការសវនាការមួយរយៈពេលខ្លីរហូតដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ ។

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ខ៊ាន់ថាន់ ពៅដារ៉ា**



អ្នកភូមិកំពុងមើលផ្សាយបន្តផ្ទាល់សវនាការនៅខាងក្នុងបរិវេណអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា

*ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥*

*ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨*

*អ៊ីម៉ែល : dccam@online.com.kh*

*គេហទំព័រ : www.dccam.org ឬ www.cambodiatribunal.org*



*គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ*

*John D. and Catherine T. MacArthur Foundation and British Embassy-Cambodia ។*




***ឆាយ ឈុនលី***

***ឈុនលី*** *ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។*



***ឌី សុជាតា***

***សុជាតា*** *ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។*



***លឹម ជ័យទ័ត្ត***

***ជ័យទ័ត្ត*** *ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។*



***ចាន ប្រាថ្នា***

***ប្រាថ្នា*** *ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។*



អៀង សារី ក្នុងបន្ទប់សវនាការ ឆ្នាំ២០១២ (រូបថត : អ.វ.ត.ក)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមីនា ឆ្នាំ២០១២